**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩

| |
|---|
| **ឯកសារបកប្រែ** |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 12-Jul-2019, 08:00 |
| CMS/CFO: Sann Rada |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សម្ងាត់/Confidential

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយរបស់ មាស មុត តបទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ**

---

**ដាក់ដោយ÷**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន÷**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

# មាតិកា

I. **និដ្ឋភាពទូទៅ** ..... 1

II. **បញ្ហាបឋម** ..... 3

ក. ទឡ្ហីករណ៍មួយចំនួនធំរបស់ ស.ព.អ. សមនឹងទទួលបានការច្រានចោលភ្លាមៗ ..... 3

ខ. ការពឹងផ្អែករបស់ ស.ព.អ. ទៅលើកត្តាបញ្ជូនមិនពាក់ព័ន្ធរបស់សាលាក្តី ICTY ក្នុងការកំណត់អ្នកទទួលខុសត្រូវបំផុតនោះ គឺមិនត្រឹមត្រូវ ..... 6

III. **ចម្លើយតបផ្នែក ៥ - សំណើទាក់ទងនឹងដីកាដំណោះស្រាយផ្ទុយគ្នា** ..... 14

IV. **ចម្លើយតបនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍** ..... 19

ក. ចម្លើយតបនឹងមូលដ្ឋាន "ខ"៖ ស.ច.ស.ជ. មិនមានកំហុសផ្នែកច្បាប់ ក្នុងការមិនពិចារណាទៅលើភស្តុតាងដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ..... 19

ខ. ការឆ្លើយតបទៅនឹងមូលដ្ឋាន "គ" (ផ្នែកខ្លះ)៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់នៅពេលពិចារណា និង ចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ នៅក្នុងវិសាលភាពនៃរឿងក្តី ០០៣ ..... 38

គ. ចម្លើយតបទៅនឹងមូលដ្ឋាន "ក" និង "គ" (មួយផ្នែក)៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់នៅក្នុងការផ្តល់សំអាងហេតុលើដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសារការខកខានមិនបានធ្វើសេចក្តីសម្រេចដែលតម្រូវឱ្យមាន និង មិនបានកំណត់ប្រភេទបទចោទតាមច្បាប់ ..... 42

ឃ. ចម្លើយតបទៅនឹងមូលដ្ឋាន "ឃ"៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់ ឬ អង្គហេតុ នៅពេលពិចារណាលើការបង្ខិតបង្ខំ ការគៀបសង្កត់ និង បញ្ជាថ្នាក់លើ ក្នុងការសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ..... 48

ង. ចម្លើយតបនឹងមូលដ្ឋាន "ង"៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់ ឬ អង្គហេតុ នៅពេលពិចារណាលើការចូលរួមផ្ទាល់របស់ មាស មុត នៅក្នុង និង កៀកកិតនឹងឧក្រិដ្ឋកម្ម នៅក្នុងការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវ ..... 56

ច. ចម្លើយតបទៅនឹងមូលដ្ឋាន "ច"៖ ស.ច.ស.ជ. មិនបានធ្វើសេចក្តីសម្រេចលើអង្គហេតុដោយមានកំហុស ដែលមានឥទ្ធិពលជាកត្តាកំណត់លើបញ្ហាយុត្តាធិការបុគ្គល ..... 60

ឆ. ចម្លើយតបទៅនឹងមូលដ្ឋាន "ឆ"៖ ស.ច.ស.ជ. មិនមានកំហុសអង្គហេតុនៅក្នុងការពិចារណារបស់ខ្លួនលើជនរងគ្រោះ ..... 70

ជ. ចម្លើយតបទៅនឹងមូលដ្ឋាន "ជ"៖ ស.ច.ស.ជ. មិនបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ........75

**V. សេចក្តីសន្និដ្ឋាន** ........ 77

# I. និដ្ឋភាពរួម

១. នៅពីខាងក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") ដែលមានកម្រាស់ ១០០ ទំព័រ[1] មានការចោទប្រកាន់ដែលមានលក្ខណៈបង្កាច់បង្ខូច និង មិនអាចឱ្យយល់ព្រមតាមបាន ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ.") យូ ប៊ុនឡេង និង ការអះអាងដ៏ល្ងង់ខ្លៅ ដែលថា រឿងក្តីរបស់លោក មាស មុត ត្រូវតែបន្តទៅជំនុំជម្រះនៅក្នុងសវនាការ ផ្អែកតាម "គោលនយោបាយ" បែបស្រមើស្រមៃ។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ក៏ដូចជារឿងក្តីរបស់លោក មាស មុត ដែរ គួរតែត្រូវបានច្រានចោលទាំងស្រុង។

២. ដោយចោទប្រកាន់ថា ស.ច.ស.ជ. បានបំពេញកិច្ចស៊ើបសួរក្លែងក្លាយ ហើយបញ្ចប់កិច្ចស៊ើបសួរមុនកាលកំណត់ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ និង បានបដិសេធដោយមិនសមហេតុផល មិនពិចារណាលើភ័ស្តុតាងដែលប្រមូលបាន ក្រោយពេលបើកកិច្ចស៊ើបសួរឡើងវិញ ខកខានមិនបានធ្វើការសម្រេចដែលតម្រូវឱ្យមាន ដោយហេតុនេះ បានធ្វើការវិភាគក្លែងក្លាយលើបញ្ហាថា តើលោក មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬយ៉ាងណានោះ ស.ព.អ. ស្នើសុំអង្គបុរេជំនុំជម្រះ ("អ.ប.ជ.") ឱ្យសម្រេចច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ.[2] និង បញ្ជូនរឿងក្តីទៅជំនុំជម្រះនៅក្នុងសវនាការ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") Michael Bohlander[3] បើទោះបីជាដីកាដំណោះស្រាយទាំងពីរមានសុពលភាពដូចគ្នាក៏ដោយ។ ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយបានបកស្រាយការស៊ើបអង្កេត និង ច្បាប់ជាធរមាន មិនត្រឹមត្រូវ និង លើកឡើងពីការសម្រេចរបស់ ស.ច.ស.ជ. ដោយមិនត្រឹមត្រូវ។ ស.ព.អ. យល់ខុសទៅលើគោលបំណងរបស់បណ្តឹងឧទ្ធរណ៍ ដោយភាគច្រើនគាត់និយាយពីដីកាសន្និដ្ឋានស្ថាពររបស់គាត់ម្តងទៀត[4]។ ស.ព.អ. បានស្នើដោយគ្មានហេតុផលឱ្យ អ.ប.ជ. ចូលរួមពាក់ព័ន្ធនឹងយុត្តិធម៌មិនប្រក្រតី ដែលមិនគោរពគោលការណ៍ *វិមតិ*

---

[1] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.")។

[2] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D266 ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[3] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[4] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/7 ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ.")។

*សង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ទទួលស្គាល់ជាសកលដោយប្រើប្រាស់សុភាសិតថ្មីថា *បើមានវិមតិសង្ស័យ ត្រូវជំនុំជម្រះ*។

៣. ស.ច.ស.ជ. បានបំពេញភារកិច្ចតាមផ្លូវច្បាប់របស់គាត់ ដោយមានការប្រុងប្រយ័ត្នខ្ពស់ ប្រកបដោយសីលធម៌ និង ភាពស្មោះត្រង់ ដោយគោរពយ៉ាងស្មោះស ទៅតាមខ្លឹមសារ និង ស្មារតីនៃច្បាប់ ព្រមទាំងប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់យ៉ាងប្រុងប្រយ័ត្ន។ ស.ច.ស.ជ. បានបំពេញកិច្ចស៊ើបសួរប្រកបដោយប្រសិទ្ធភាព និង ពិតប្រាកដ រួមជាមួយ ស.ច.ស.អ. Marcel Lemonde និង Siegfried Blunk មុនពេលបញ្ចប់កិច្ចស៊ើបសួរ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១។ ក្នុងនាមជា ស.ច.ស. ឯករាជ្យ ស្មើនឹងដៃគូអន្តរជាតិរបស់គាត់ ស.ច.ស.ជ. មិនត្រូវបានតម្រូវឱ្យពិចារណាទៅលើភ័ស្តុតាងដែលពួកគេប្រមូលបានឡើយ ដើម្បីឈានទៅរកការសម្រេចរបស់គាត់ ទៅលើបញ្ហាដែលថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលទៅលើលោក មាស មុត ដែលនៅទីបំផុតផ្អែកលើកត្តានានាដែលគាត់ និង ស.ច.ស.អ. Bohlander បានបញ្ជាក់ និង អនុវត្តរួមគ្នា។ ដូចដែល ស.ព.អ. អះអាងដោយមិនពិត ស.ច.ស.ជ. មិនបានពឹងផ្អែកដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់ទៅលើការសន្និដ្ឋានដែលថា *មានតែ* ប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ម្នាក់ប៉ុណ្ណោះ ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

៤. ស.ព.អ. ខកខានមិនបានបង្ហាញ ដូចដែលគាត់តម្រូវឱ្យធ្វើ ឱ្យឃើញថាតើ ស.ច.ស.ជ. មានកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាន ទាក់ទងនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ជារួម ឬ ដោយឡែក តាមរបៀបណា ដែលតម្រូវឱ្យ អ.ប.ជ. ច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់នោះ។ បើទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលប់ក៏ដោយ ក៏ អ.ប.ជ. នៅតែត្រូវការមតិភាគច្រើនលើសលប់ ដើម្បីសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីឱ្យរឿងក្តីអាចបន្តទៅដំណាក់កាលជំនុំជម្រះដែរ។

៥. ដោយពិចារណាទៅលើទម្រង់ដ៏ច្របូកច្របល់ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដើម្បីជៀសវាងភាពបត់បែន និង ច្រំដែលមិនចាំបាច់ ចម្លើយនឹងចាប់ផ្តើមដោយពោលប្រាស្រ័យអំពីបញ្ហាជាបឋម គឺរៀបរាប់អំពីទឡ្ហីករណ៍ដែលតម្រូវឱ្យមានការច្រានចោលភ្លាមៗ និង ពោលប្រាស្រ័យអំពីការពឹងផ្អែករបស់ ស.ព.អ. ទៅលើកត្តាដែលមិនពាក់ព័ន្ធ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានលើកឡើងនៅក្នុងផ្នែកស្តីពីច្បាប់ជាធរមានរបស់គាត់ និង ត្រូវបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងមូលរបស់គាត់។ បន្ទាប់មក ចម្លើយនឹងពោលប្រាស្រ័យអំពីផ្នែកទី ៥ នៃបណ្តឹងឧទ្ធរណ៍ ដែលក្នុងផ្នែកនេះ ស.ព.អ. បង្វែរគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់*

*ជនត្រូវចោទ* ឱ្យបានជាប្រយោជន៍គាត់។ ដោយបានដោះស្រាយបញ្ហាកំណត់ជាមូលដ្ឋាននៃសេណារីយូដីកាដំណោះស្រាយផ្ទុយគ្នា (ដូចដែលបានអះអាងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់លោក មាស មុត ផងដែរ)[5] បន្ទាប់មក ចម្លើយនឹងពោលប្រាស្រ័យអំពីមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ. ដោយចាប់ផ្ដើមពីការអះអាងរបស់គាត់ដែលថា ស.ច.ស.ជ. មានកំហុស ដែលខកខាន មិនបានពិចារណាលើភស្តុតាងដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ (មូលដ្ឋាន ខ)។ លុះត្រាតែវិនិច្ឆ័យពេញលេញនូវតម្លៃនៃកិច្ចស៊ើបសួរដែលបានធ្វើឡើង នៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ រួចហើយ ទើបអាចពោលប្រាស្រ័យអំពីការអះអាងរបស់ ស.ព.អ. ដែលថា ស.ច.ស.ជ. ខកខានមិនបានចេញសេចក្ដីសម្រេចទៅលើអង្គហេតុទាំងអស់ និង កំណត់ប្រភេទនៃបទចោទចំពោះអង្គហេតុទាំងនោះនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់បាន (មូលដ្ឋាន "គ" និង មូលដ្ឋាន "ក")។ មូលដ្ឋានរបស់ ស.ព.អ. ដែលនៅសេសសល់ ត្រូវបានពោលប្រាស្រ័យទៅតាមលំដាប់លំដោយនៃបណ្ដឹងឧទ្ធរណ៍ ។

## II. បញ្ហាបឋម

### ក. ទឡ្ហីករណ៍មួយចំនួនធំរបស់ ស.ព.អ. សមនឹងទទួលបានការច្រានចោលភ្លាមៗ

៦. ស.ព.អ. បានស្នើយ៉ាងប្រញាប់ប្រញាល់ ឱ្យ អ.ប.ជ. ច្រានចោលជាបន្ទាន់នូវទឡ្ហីករណ៍មួយចំនួនធំដែលមិនមានសក្ដានុពលក្នុងការច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់[6] គឺទឡ្ហីករណ៍ដែល "មិនមានមូលដ្ឋានសំអាងគ្រប់គ្រាន់" មិនមានភាពពេញលេញ ឬ មិនបានបង្ហាញពីកំហុស[7]

---

[5] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 ("បណ្ដឹងឧទ្ធរណ៍របស់ មាស មុត")។

[6] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៤៧ និង ៤៨) សាលដីកាលើបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១០ និង ដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ២២៖ "[អ.ប.ជ.] យល់ឃើញថា ខ្លួនអាចទាត់ចោលទឡ្ហីករណ៍របស់ភាគីណា ដែលមិនមានសក្ដានុពល នាំដល់ការច្រានចោល ឬ កែប្រែសេចក្ដីសម្រេច ដែលត្រូវបានជំទាស់ដោយមិនចាំបាច់ពិនិត្យដល់អង្គសេចក្ដី"។ *សូមមើលផងដែរ រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីកាលើរឿងក្ដី ០០១") កថាខណ្ឌ ២០។

[7] កថាខណ្ឌ ២០ នៃសាលដីកាលើរឿងក្ដី ០០១។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២៖ "អង្គជំនុំជម្រះតុលាការកំពូល នឹងច្រានចោល

ទឡ្ហីករណ៍ដែល "ផ្អែកលើការបកស្រាយផ្សេងទៀតដែលមិនមានការគាំទ្រ ទៅលើភស្តុតាងដូចគ្នា" ដោយមិនបានពន្យល់ពីមូលហេតុ ដែលនាំឱ្យការសម្រេចនោះមិនមានសុពលភាព ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលនៅសល់[8] ការគ្រាន់តែលើកឡើងម្តងហើយម្តងទៀតនូវទឡ្ហីករណ៍បរាជ័យពីក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ ដោយមិនមានការបង្ហាញឱ្យឃើញថា ការបដិសេធរបស់ ស.ច.ស. ចំពោះទឡ្ហីករណ៍ទាំងនេះ គឺជាកំហុស ដែលតម្រូវឱ្យមានការអន្តរាគមន៍ពីសំណាក់ អ.ប.ជ.[9] និង ការជំទាស់នឹងសំអាងហេតុ ដែលការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ. មិនបានពឹងផ្អែក[10]។ ជាពិសេស អ.ប.ជ. គួរតែច្រានចោលភ្លាមៗ នូវទឡ្ហីករណ៍របស់ ស.ព.អ. ដែល៖

ដោយមិនវិភាគលម្អិត៖ ... (ix) ការអះអាងដែលមិនមានការគាំទ្រដោយភស្តុតាងណាមួយ ការអះអាងមិនពេញលេញ ខកខានមិនបានបង្ហាញពីកំហុសឆ្គង"។

[8] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ F36 ("សាលដីកាលើរឿងក្តី ០០២/០១") កថាខណ្ឌ ៩០ ដែលដកស្រង់ *ក្នុងចំណោមនោះមាន រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Strugar* សំណុំរឿងលេខ IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ២១ ដល់ ២២៖ "ការអះអាងដែលថាអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់ស្ថានទម្ងន់គ្រប់គ្រាន់ចំពោះភស្តុតាងជាក់លាក់មួយចំនួន ឬ ក៏គួរបកស្រាយភស្តុតាងក្នុងលក្ខណៈជាក់លាក់មួយនេះ គឺត្រូវស្ថិតក្រោមការច្រានចោលភ្លាមៗ"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២២៖ "អង្គជំនុំជម្រះតុលាការកំពូល នឹងច្រានចោលដោយមិនវិភាគលម្អិត៖ ... (iv) ទឡ្ហីករណ៍ដែលជំទាស់ចំពោះការដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែក ឬ មិនបានពឹងផ្អែកទៅលើភស្តុតាងណាមួយ ដោយមិនបានពន្យល់ថាហេតុអ្វីទោះត្រូវច្រានចោលការផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលនៅសល់នោះ"។

[9] *សូមមើល* កថាខណ្ឌ ២០ នៃសាលដីកាលើរឿងក្តី ០០១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២៖ "អង្គជំនុំជម្រះតុលាការកំពូល នឹងច្រានចោលដោយមិនវិភាគលម្អិត៖ ... (vii) ការលើកឡើងដដែលនូវទឡ្ហីករណ៍ ដែលមិនទទួលបានជោគជ័យ នៅដំណាក់កាលជំនុំជម្រះ ដោយមិនមានការបង្ហាញថា ការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូង បង្កើតបានជាកំហុសឆ្គងដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើអន្តរាគមន៍"។

[10] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២២៖ "អង្គជំនុំជម្រះតុលាការកំពូល នឹងច្រានចោលដោយមិនវិភាគលម្អិត៖ ... (iii) ការជំទាស់ចំពោះការសម្រេចលើអង្គហេតុ ដែលការផ្តន្ទាទោសមិនបានពឹងផ្អែកលើ និង ទឡ្ហីករណ៍ដែលគ្មានភាពពាក់ព័ន្ធសោះ ដែលផ្តល់ការគាំទ្រទៅដល់ ឬ ដែលស៊ីសង្វាក់ជាមួយនឹងការសម្រេចដែលរងការជំទាស់"។

ក. អះអាងថា កិច្ចស៊ើបអង្កេតនៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ គឺលម្អៀង[11]។ ស.ព.អ. ខកខានមិនបានបង្ហាញពីទឡ្ហីករណ៍ណាមួយដែលថា ស.ច.ស. ណាម្នាក់ ដែលបានស៊ើបអង្កេតនៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ជា ស.ច.ស.ជ. ស.ច.ស.អ. Lemonde និង/ឬ ស.ច.ស.អ. Blunk ដែល "អាចមានភាពលម្អៀងពិតប្រាកដមែន"[12]។

ខ. អះអាងថា ស.ច.ស.ជ. ខកខានមិនបានពឹងផ្អែកលើចម្លើយរបស់ ខៀវ សំផន ដែលថា លោក មាស មុត ធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិម[13]។ ស.ព.អ. ខកខានមិនបានពន្យល់ថា ហេតុអ្វីបានជាការសម្រេចរបស់ ស.ច.ស.ជ. និង ស.ច.ស.អ. Bohlander ដែលថា លោក មាស មុត មិនធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិម មិនគួរទុកជាបានការ ដោយផ្អែកលើភ័ស្តុតាងផ្សេងទៀត[14]។

គ. លើកឡើងម្តងហើយម្តងទៀត អំពីការគណនាចំនួនជនរងគ្រោះ នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់[15]។ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា តើ ស.ច.ស.ជ. ឬ ស.ច.ស.អ. Bohlander មានកំហុសដោយរបៀបណា ក្នុងការច្រានចោលការគណនានេះ ព្រោះ ស.ព.អ. មិនបានប្តឹងឧទ្ធរណ៍ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានរកឃើញចំនួនជនរងគ្រោះ ខុសគ្នាខ្លាំងធៀបទៅនឹងចំនួនដែល ស.ព.អ. អះអាង[16]។ និង

[11] កថាខណ្ឌ ៣៥, ៤៣, ៤៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[12] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អ.វ.ត.ក/ក.ស.ច.ស (អបជ 0១) សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះចៅក្រម ន័យ ធុល ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២00៨ ឯកសារ C11/29 កថាខណ្ឌ ១៩៖ "អ្នកប្តឹងជំទាស់ចិត្តត្រូវបង្ហាញភស្តុតាង ឱ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះ ដើម្បីឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះ អាចមានភាពលំអៀងពិតប្រាកដមែន"។ គឺមាននៅមានចំណុចជាមូលដ្ឋានជាច្រើនដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ"។

[13] កថាខណ្ឌ ១៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[14] កថាខណ្ឌ ១១១, ១១៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥0 នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[15] កថាខណ្ឌ ១៦៣-១៦៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ) កថាខណ្ឌ ១៦៥-១៦៦ (ស្ទឹងហាវ) កថាខណ្ឌ១៦៨ (វត្តឥន្ទញ្ញាណ) កថាខណ្ឌ ១៦៩-១៧0 (ស-២១) ដែលដកស្រង់ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ.។

[16] កថាខណ្ឌ ៤៦៤, ៤៦៧-៤៦៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ឃ. អះអាងថា ដីកាសម្រេចលើកលែងចោទប្រកាន់ បានសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់[17]។ ស.ច.ស.ជ. មិនបានសម្រេចបែបនេះទេ ហើយគាត់ក៏មិនបានសំអាងដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់ទៅលើការសម្រេចបែបនេះដែរ[18]។

**ខ. ការពឹងផ្អែករបស់ ស.ព.អ. ទៅលើកត្តាបញ្ជូនមិនពាក់ព័ន្ធរបស់សាលាក្តី ICTY ក្នុងការកំណត់អ្នកទទួលខុសត្រូវបំផុតនោះ គឺមិនត្រឹមត្រូវ**

៧. ស.ព.អ. បានស្នើដោយខុសឆ្គង និង គ្មានសុភវិនិច្ឆ័យ ឱ្យ អ.ប.ជ. ជំនួសកត្តានានាដែល ស.ច.ស. បានបញ្ជាក់ និង អនុវត្ត ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត[19] ដោយកត្តាបញ្ជូនរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("សាលាក្តី ICTY")[20]។ ស.ព.អ. លើកឡើងនូវកត្តាទាំងនេះ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ស.ច.ស.ជ. ខកខានមិនបានពិចារណាឱ្យបានត្រឹមត្រូវ ទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និង កម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត នៅពេលធ្វើការសម្រេចថាតើលោក មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬយ៉ាងណានោះ[21]។ បរិបទចរចារពិសេសរបស់ អ.វ.ត.ក. ធ្វើឱ្យកត្តាបញ្ជូនរបស់សាលាក្តី ICTY មិនជាប់ពាក់ព័ន្ធ[22]។ ក្នុងការស្នើសុំឱ្យ អ.ប.ជ. អនុវត្តកត្តាទាំងនេះ ស.ព.អ. ខកខានមិនបានពិចារណាអំពីអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. ក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវខ្ពស់បំផុត[23] ប្រវត្តិនៃការចរចាររបស់ អ.វ.ត.ក.[24] គោលការណ៍គតិយុត្តិដែលចាំបាច់[25] និង កាលៈទេសៈបរិបទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[26]។ អ.ប.ជ. គួរតែកុំ

---

[17] កថាខណ្ឌ ១៧១-១៩០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[18] *សូមមើល* កថាខណ្ឌ ៩៣-៩៦ *ខាងក្រោម*។

[19] *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 ("ដីកាដំណោះស្រាយរឿងក្តី ០០៤/១") កថាខណ្ឌ ៣-៤១។

[20] *សូមមើល* កថាខណ្ឌ ១០-១១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[21] *សូមមើល* កថាខណ្ឌ ២០០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[22] *សូមមើល* កថាខណ្ឌ ១៨ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[23] ស.ច.ស. ទាំងពីររូប បានឯកភាពថា ការសម្រេចថាតើលោក មាស មុត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬអត់នោះ គឺតម្រូវឱ្យប្រើឆន្ទានុសិទ្ធិ។ *សូមមើល* កថាខណ្ឌ ៣៦៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់កថាខណ្ឌ ៩-១០ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[24] *សូមមើល* កថាខណ្ឌ ១២ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[25] កថាខណ្ឌ ២៦-៣៦ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

អើពើនឹងការទទួចសុំមិនត្រឹមត្រូវរបស់ ស.ព.អ. ឱ្យអនុវត្តកត្តាបញ្ជូនរបស់សាលាក្តី ICTY ហើយ ជំនួសវិញ អនុវត្តកត្តារបស់ ស.ច.ស.។

៨. ***ស.ច.ស. បានបញ្ជាក់ និង អនុវត្តកត្តាសម្រាប់កំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវខ្ពស់បំផុត*** ដោយផ្អែកលើ "ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើប្រវត្តិនៃការចរចាមុនពេលបង្កើត អ.វ.ត.ក. និង ការវិវឌ្ឍចាប់តាំងពីពេលនោះមក"[27] គោលការណ៍គតិយុត្តិដែលចាំបាច់[28] និង ភស្តុតាងដែលប្រមូលបាន នៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់ពួកគាត់[29] ស.ច.ស. បានបញ្ជាក់ និង អនុវត្តកត្តាទាំងនេះ ដើម្បីទប់ស្កាត់សកម្មភាពតាមអំពើចិត្ត ដូចជា "រង្វាស់ដែលអាចវាស់វែង និង ត្រូវតែវាស់វែងលើការអនុវត្តឆន្ទានុសិទ្ធិ"[30] ដោយពិចារណាទៅលើ "ភាពអាចបត់បែនបាន" នៃពាក្យទទួលខុសត្រូវខ្ពស់បំផុត[31]។ កត្តាទាំងនេះរួមមាន៖

ក. *ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង* រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ("អ.ស.ប.") មានចេតនា "កំហិតយុត្តាធិការបុគ្គល ចំពោះអ្នកដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពួកគេបានដឹងយ៉ាងច្បាស់ពីចំនួនសរុបនៃការស្លាប់" ហើយថាមាន "បុគ្គលអាចជាចារីជាច្រើន ដែលម្នាក់ៗអាចទទួលខុសត្រូវ ក្នុងការស្លាប់មនុស្សរាប់រយ ឬ រាប់ពាន់នាក់"[32]។ យុត្តាធិការបុគ្គលបែបមានកម្រិតកំណត់របស់ អ.វ.ត.ក. ឆ្លុះបញ្ចាំងពី "គោលបំណងថែរក្សាសន្តិភាព និង ការផ្សះផ្សាជាតិ"[33] ព្រមទាំងធនធាន និង សមត្ថភាពមានកម្រិតរបស់ខ្លួន ក្នុងការបំពេញកិច្ចស៊ើបសួរ និង ជំនុំជម្រះ[34]។

---

[26] *សូមមើល* កថាខណ្ឌ ៣៧-៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[27] កថាខណ្ឌ ១២ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[28] *សូមមើល* កថាខណ្ឌ ២៦-៣៦ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[29] កថាខណ្ឌ ៤០-៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[30] កថាខណ្ឌ ៩ នៃ ដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[31] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១") (សម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២០។

[32] កថាខណ្ឌ ១៨ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[33] កថាខណ្ឌ ១៦ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[34] លិខិតដូចគ្នាចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ពីអគ្គលេខាធិការផ្ញើជូនប្រធានមហាសន្និបាត និង ប្រធានក្រុមប្រឹក្សាសន្តិសុខ សមាជប្រជុំលើកទី ៥៣ របៀបវារៈលេខ 110(b) ឯកសារ អ.ស.ប. លេខ A/53/850-S/1999/231 ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ

ខ. *គោលការណ៍នៃវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយបែបចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ* គោលការណ៍គតិយុត្តិដែលតម្រូវកំណត់ទាំងនេះ ត្រូវអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ទាំងចំពោះអង្គហេតុ និង អង្គច្បាប់[35]។ ការអនុវត្តគោលការណ៍ទាំងនេះ "មានសារៈសំខាន់ជាងគេ នៅក្នុងប្រព័ន្ធដែលច្បាប់មិនបានចែងពេញលេញ"[36]។

គ. *ការធ្វើសេចក្ដីសម្រេចនៅក្នុងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ* សេចក្ដីសម្រេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងនៅកម្រិតកំពូល ហើយត្រូវបានអនុវត្តដោយថ្នាក់ក្រោម ដោយមានផលវិបាកបុគ្គលក្នុងករណីមិនគោរពតាម[37]។ ខណៈដែលថ្នាក់កំពូលរៀបចំគោលនយោបាយជាពាក្យពេចន៍ទូទៅ ហើយកម្មាភិបាលថ្នាក់ក្រោម "ត្រូវបានផ្ដល់លទ្ធភាពស្វែងយល់លម្អិត នៅក្នុងពេលអនុវត្តគោលនយោបាយទាំងនោះ ... ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និង មធ្យោបាយអនុវត្តគោលនយោបាយ ស្ថិតនៅលើថ្នាក់កំពូល ដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ"[38]។

ឃ. *ស្ថានទម្ងន់ប្រហាក់ប្រហែលនៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់របស់អំពើទាំងនោះគឺត្រូវស្ថិតក្រោមគោលបំណងរបស់ភាគីនៃកិច្ចព្រមព្រៀង* ខណៈដែលស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និង កម្រិតនៃការទទួលខុសត្រូវ គឺជាកត្តាពាក់ព័ន្ធក្នុងការសម្រេចលើយុត្តាធិការបុគ្គល ជាការចាំបាច់ណាស់ដែលត្រូវពិនិត្យមើលភ័ស្តុតាង ធៀបជាមួយទំហំទាំងស្រុងនៃការឈឺចាប់ ដែល

---

១៩៩៩ ឧបសម្ព័ន្ធ របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងអនុលោមតាមសេចក្ដីសម្រេចលេខ ៥២/១៣៥ របស់មហាសន្និបាត ("របាយការណ៍ក្រុមអ្នកជំនាញ") កថាខណ្ឌ ១២៦, ១៣៤ (ឯកសារភ្ជាប់ ២)។

[35] *សូមមើល រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៤) សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីការដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៣១០។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ និង១៤៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។

[36] កថាខណ្ឌ ២៧ នៃដីកាដំណោះស្រាយរឿងក្ដី ០០៤/១។

[37] កថាខណ្ឌ ៤០-៤១ នៃដីកាដំណោះស្រាយរឿងក្ដី ០០៤/១។

[38] កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយរឿងក្ដី ០០៤/១។

ទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[39]។ ទាំងនេះ "ចៀសមិនរួចនឹងមានការពិនិត្យ ទៅលើចំនួនអ្នកស្លាប់សរុប ដែលបណ្តាលមកពីការសម្លាប់ ការបង្អត់អាហារដោយចេតនា ឬ ដោយការធ្វេសប្រហែស ចំពោះពលករដោយបង្ខំ និង អ្នកទោស ព្រមទាំងសេវាសុខភាពសាធារណៈ ដែលជាទូទៅមិនគ្រប់គ្រាន់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ចំនួនអ្នកដែលត្រូវបានផ្លាស់ទីលំនៅ និង អ្នកដែលត្រូវបានបង្ខំឱ្យធ្វើការធ្ងន់។ល។"[40]។

៩. ***ប្រវត្តិនៃការចរចាររបស់ អ.វ.ត.ក. ផ្តល់ព័ត៌មានអំពីកត្តាយុត្តាធិការបុគ្គលដែលមានជាធរមាន*** បន្ទាប់ពីការជជែកដេញដោល និង ខ្វែងយោបល់គ្នាជិតបួនឆ្នាំ[41] រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានឯកភាពលើតុលាការមួយសម្រាប់ "យុត្តិធម៌តាមបែបជ្រើសរើស"៖ "មានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុង អ.វ.ត.ក. ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ"[42] គឺ មេដឹកនាំជាន់ខ្ពស់ និង "អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម" ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ ១៩៧៩[43]។ ខណៈដែលពាក្យពេចន៍ទាំងនេះ ត្រូវបានទុកចោលមិនបានចែងកំណត់នៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[44] ជនដែលត្រូវស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. នឹងត្រូវទុកឱ្យសហព្រះរាជអាជ្ញា និង ជាចុងក្រោយ ស.ច.ស. សម្រេចតាមអំណាចឆន្ទានុសិទ្ធ[45]។

១០. ក្រុមអ្នកជំនាញរបស់អគ្គលេខាធិការ អ.ស.ប. ដែលមានភារកិច្ចស្វែងរកជម្រើសនានាសម្រាប់នាំ "មេដឹកនាំខ្មែរក្រហម" មកកាត់សេចក្តី[46] បានផ្តល់អនុសាសន៍ឱ្យបង្កើតសាលាក្តីអន្តរជាតិ *ចំពោះកិច្ច*

---

[39] កថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[40] កថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[41] បើយោងតាម David Scheffer អតីតឯកអគ្គរដ្ឋទូតសុឆន្ទៈសម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម ការពិភាក្សាលម្អិតអំពីយុត្តាធិការបុគ្គល ទើបតែចាប់ផ្តើមនៅឆ្នាំ១៩៩៩ ប៉ុណ្ណោះ។ *សូមមើល* David Scheffer *ប្រវត្តិចរចាអំពីបញ្ហាយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.* អ្នកឃ្លាំមើលសាលាក្តីកម្ពុជា ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ទំព័រ ២។

[42] កថាខណ្ឌ ៣១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[43] មាត្រា ១, ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ២(១) នៃកិច្ចព្រមព្រៀង។

[44] មាត្រា ១, ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ បុព្វកថា មាត្រា ២, ៥(៣), ៦(៣) នៃកិច្ចព្រមព្រៀង។

[45] កថាខណ្ឌ ៧៤ នៃសាលដីកាលើរឿងក្តី ០០១។

[46] លិខិតចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៨ ពីអគ្គលេខាធិការ ផ្ញើជូនប្រធានមហាសន្និបាត ឯកសារ អ.ស.ប. លេខ A/52/1007 ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩៨ ទំព័រ ១ (ឯកសារភ្ជាប់ ៣)។

មួយ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសាលាក្តី ICTY[47] ដោយព្រះរាជអាជ្ញាមានសិទ្ធិអំណាចផ្តាច់មុខក្នុងការសម្រេចលើជនណាដែលត្រូវបញ្ជូនទៅជំនុំជម្រះ[48]។ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកចំណុចសំខាន់តាមអនុសាសន៍ សម្រាប់តុលាការនាពេលអនាគតថា ត្រូវផ្តោតលើ "*ជនទទួលខុសត្រូវខ្ពស់បំផុត* ចំពោះការរំលោភបំពាន់ធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[49] រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធអនុសាសន៍ដែលថា ឱ្យបង្កើតសាលាក្តីតាមគំរូរបស់សាលាក្តី ICTY ដែលព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិផ្តាច់មុខ ក្នុងការបញ្ជូនរឿងទៅជំនុំជម្រះ[50]។

១១. ក្នុងការសម្រេចជាស្ថាពរលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. អ.ស.ប. "បានបន្ថែមពាក្យ 'បំផុត' ធ្វើជាការបង្ហាញពី *វិធីសាស្ត្រក្នុងការកម្រិតកំណត់លើវិសាលភាពនៃយុត្តាធិការបុគ្គល ក្នុងលក្ខណៈសមហេតុផលមួយ*"[51] ដោយយល់ឃើញថា ពាក្យ "អ្នកដែលទទួលខុសត្រូវ" នៅក្នុងមាត្រា ១ នៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតតុលាការ អ.វ.ត.ក. ដោយរាជរដ្ឋាភិបាលកម្ពុជា[52] មានលក្ខណៈ

---

[47] កថាខណ្ឌ ១៣៩-១៤៨ នៃរបាយការណ៍ក្រុមអ្នកជំនាញ (ឯកសារភ្ជាប់ ២)។

[48] កថាខណ្ឌ ១១០ នៃរបាយការណ៍ក្រុមអ្នកជំនាញ (ឯកសារភ្ជាប់ ២)។

[49] កថាខណ្ឌ ១១០ នៃរបាយការណ៍ក្រុមអ្នកជំនាញ (ការគូសបញ្ជាក់បន្ថែម) (ឯកសារភ្ជាប់ ២)។

[50] *សូមមើល* លិខិតចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩ ពីនាយករដ្ឋមន្ត្រីកម្ពុជា ផ្ញើជូនអគ្គលេខាធិការ ឯកសារ អ.ស.ប. លេខ A/53/851 និង S/1999/230 ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩។ *សូមមើលផងដែរ* លិខិតរបស់អគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូនឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០០ ទំព័រ ២។ លិខិតរបស់អគ្គលេខាធិការ អ.ស.ប Kofi Annan ផ្ញើជូនឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០០ ទំព័រ ១, ៣។

[51] Stephen Heder *យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់" និង ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និង ដំណើរការវិវឌ្ឍន៍នាពេលថ្មីៗនេះ* អ្នកឃ្លាំមើលសាលាក្តីកម្ពុជា ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១២ ("Heder យុត្តាធិការបុគ្គល") ទំព័រ ៣៥ ដែលអាចរកបានតាមគេហទំព័រ៖ http://www.cambodiatribunal.org/assets/pdf/reports/Final%20Revised%20Heder%20Personal%20Jurisdiction%20Review.120426.pdf, quoting Phnom Penh ដែលដកស្រង់សម្តីនៅភ្នំពេញ ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០០ នៅម៉ោង ៣ រសៀល៖ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ការគូសបញ្ជាក់បន្ថែម)។

[52] សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ អ.ស.ប. លេខ RC/MP/0008/00 ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០០ មាត្រា ១, ២ (ឯកសារភ្ជាប់ ១)។

ទូលាយពេក[53]។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយករូបមន្ត "ទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឆ្នាំ ២០០១[54] ដែលបានឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀង[55]។ នៅពេលបញ្ចប់ការចរចា អ្នកចរចាសំខាន់បំផុតរបស់ អ.ស.ប. បានថ្លែងថា អ្នកដែលជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត គឺអាស្រ័យលើសហព្រះរាជអាជ្ញា និង ស.ច.ស.[56]។

១២. ***កត្តាបញ្ជូនរបស់សាលាក្តី ICTY គឺមិនពាក់ព័ន្ធ*** ផ្ទុយពីគ្នា នីតិវិធីបញ្ជូនរបស់សាលាក្តី ICTY ត្រូវបានអនុម័តដើម្បីសម្របសម្រួល ដល់តម្រូវការផ្នែកថវិកា និង ដើម្បីជម្រុញដល់ផែនការបញ្ចប់របស់សាលាក្តី។ ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. បានបង្កើតសាលាក្តី ICTY ឱ្យមានយុត្តាធិការទូលាយ ដើម្បីជំនុំជម្រះ "*អ្នកទទួលខុសត្រូវ*"[57] ប៉ុន្តែ ឆន្ទានុសិទ្ធិដោយសេរីរបស់រដ្ឋអាជ្ញា ចំពោះជនណាដែលត្រូវបញ្ជូនទៅជំនុំជម្រះនោះ[58] បាននាំទៅដល់បញ្ហាថវិកាភ្លាមៗ ក្នុងការផ្តល់ហិរញ្ញវត្ថុដល់បន្ទុករឿងក្តីដ៏ធំសម្បើមរបស់សាលាក្តី[59]។ អគ្គលេខាធិការ អ.ស.ប. ត្រូវបានស្នើសុំឱ្យ "ចាត់វិធានការចាំបាច់នានា" ដើម្បីបង្កើនជាអតិបរមានូវប្រសិទ្ធភាព និង សេដ្ឋកិច្ចរបស់សាលាក្តី[60]។ ក្រុមអ្នកជំនាញរបស់អគ្គលេខាធិការ អ.ស.ប. ដែលទទួលភារកិច្ចក្នុងការត្រួតពិនិត្យលើប្រសិទ្ធិភាពរបស់

---

[53] Heder យុត្តាធិការបុគ្គល ទំព័រ ៣៤-៣៥។

[54] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ HJ/1/3/01 (កែសម្រួលដោយ Helen Jarvis នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០១) មាត្រា ១, ២។

[55] *សូមមើល* មាត្រា ១, ២(១) នៃកិច្ចព្រមព្រៀង។

[56] *សូមមើល* សេចក្តីថ្លែងការណ៍របស់ អគ្គលេខាធិការរង Hans Corell បន្ទាប់ពីចាកចេញពីទីក្រុងភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៣ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៣ ទំព័រ ២។

[57] លក្ខន្តិកៈដែលមានបច្ចុប្បន្នភាពរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលធ្វើវិសោធនកម្មតាមរយៈសេចក្តីសម្រេចលេខ ១៨៧៧ នៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៩ ( "លក្ខន្តិកៈសាលាក្តី ICTY") មាត្រា ១ (ការគូសបញ្ជាក់បន្ថែម)។

[58] មាត្រា ១៦ នៃលក្ខន្តិកៈសាលាក្តី ICTY។

[59] នៅត្រឹមឆ្នាំ ១៩៩៩ ជនជាប់ចោទ ៩១ រូប ត្រូវបានបញ្ជូនទៅជំនុំជម្រះជាសាធារណៈ នៅសាលាក្តី ICTY។ *សូមមើល* របាយការណ៍របស់ក្រុមអ្នកជំនាញ ធ្វើការវាយតម្លៃទៅលើមុខងារ និង ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ឯកសារ អ.ស.ប. លេខ A54/634 ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៥, ២៨, ៣០។

[60] សេចក្តីសម្រេចមហាសន្និបាត អ.ស.ប. 53/212 ឯកសារ អ.ស.ប. លេខ A/RES/53/212 ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៨។

សាលាក្តី ICTY រួមជាមួយចៅក្រមរបស់សាលាក្តី ICTY បានឯកភាពគ្នាថា ការជំនុំជម្រះ "បុគ្គលតូចតាច" នឹងមិនបំពេញតាមគោលដៅរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ឡើយ[61]។

១៣. បន្ទាប់ពីមានរបាយការណ៍របស់ក្រុមអ្នកជំនាញ ប្រធានសាលាក្តី ICTY គឺលោក Claude Jorda បានបញ្ជូនផែនការបញ្ចប់ទៅក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.[62]។ គោលបំណងសំខាន់នៃការបញ្ជូនរឿងក្តី គឺដើម្បីឱ្យសាលាក្តី ICTY អាចផ្តោតធនធានរបស់ខ្លួន ទៅលើជនជាប់ចោទដែលមានឋានៈខ្ពស់ និង ដើម្បីមានលទ្ធភាព បញ្ចប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងអស់របស់ខ្លួន នៅត្រឹមឆ្នាំ ២០០៨[63]។ ដោយមិនចាំបាច់ឆ្លងកាត់ការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ក្នុងការធ្វើវិសោធនកម្មលក្ខន្តិកៈសាលាក្តី ICTY ដើម្បីអនុវត្តសំណើររបស់គាត់នោះ លោកប្រធាន Claude Jorda បានបញ្ជាក់ថា ទោះបីជាមាន ឬ មិនមានវិសោធនកម្មទៅលើលក្ខន្តិកៈរបស់សាលាក្តី ICTY ក៏ដោយ ក៏មាត្រា ១១ *ស្ទួន* នៃវិធាននីតិវិធី និង ភ័ស្តុតាង "នឹងត្រូវធ្វើវិសោធនកម្ម"[64]។ បន្ទាប់មកក៏មានការធ្វើវិសោធនកម្មវិធាន ១១ *ស្ទួន* ដើម្បីអនុញ្ញាតឱ្យរដ្ឋអាជ្ញា អាចស្នើសុំការបញ្ជូនរឿងក្តីទៅតុលាការថ្នាក់ជាតិបាន[65]។ នៅក្នុងឆ្នាំ ២០០៤ វិធាន ១១ *ស្ទួន* ត្រូវបានកែប្រែ ដោយតម្រូវឱ្យក្រុមប្រឹក្សាជំនុំជម្រះបញ្ជូនរឿងក្តី ធ្វើការពិចារណាទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និង កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[66]។

---

[61] របាយការណ៍របស់ក្រុមអ្នកជំនាញ ធ្វើការវាយតម្លៃទៅលើមុខងារ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ឯកសារ អ.ស.ប. លេខ A54/634 ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៦។

[62] របាយការណ៍ស្តីពីស្ថានភាពតុលាការរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង លទ្ធភាពនាពេលអនាគតសម្រាប់ការបញ្ជូនរឿងក្តីមួយចំនួនទៅតុលាការជាតិ (ខែមិថុនា ឆ្នាំ ២០០២) ("របាយការណ៍របស់ប្រធានសាលាក្តី ICTY") ជាឧបសម្ព័ន្ធនៃលិខិតចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០២ របស់អគ្គលេខាធិការ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារ អ.ស.ប. លេខ S/2002/678 ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ (ឯកសារភ្ជាប់ ៤)។

[63] លិខិតចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០២ របស់អគ្គលេខាធិការ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារ អ.ស.ប. លេខ S/2002/678 ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ទំព័រ ១។ កថាខណ្ឌ ៧៥ នៃរបាយការណ៍របស់ប្រធានសាលាក្តី ICTY (ឯកសារភ្ជាប់ ៤)។

[64] កថាខណ្ឌ ៤៤ នៃរបាយការណ៍របស់ប្រធានសាលាក្តី ICTY (ឯកសារភ្ជាប់ ៤)។

[65] វិធាននីតិវិធី និងភស្តុតាងរបស់សាលាក្តី ICTY IT/32/Rev.50 ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៥ វិធាន ១១ *ស្ទួន* (អនុម័តថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលកែសម្រួលឡើងវិញនៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០២)។

[66] វិធាននីតិវិធី និងភស្តុតាងរបស់សាលាក្តី ICTY IT/32/Rev.50 ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៥ វិធាន ១១ *ស្ទួន*(គ) ត្រូវបានវិសោធនកម្មនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ អនុលោមតាមសេចក្តីសម្រេចលេខ ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ

១៤. *ជារួម* ដោយមិនគិតអំពីប្រវត្តិនៃការចរចា ដែលនាំឱ្យមានការបង្កើត អ.វ.ត.ក. ស.ព.អ. ស្នើសុំដោយមិនត្រឹមត្រូវ ឱ្យ អ.ប.ជ. អនុម័តយកកត្តាបញ្ជូនរបស់សាលាក្តី ICTY ដែលមិនត្រឹមតែមិនមានការឯកភាពពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនពាក់ព័ន្ធ និង មិនអាចអនុវត្តបាន "ដោយសារការវាស់វែងទៅតាមប្រភេទនៃចំនួនទាំងនេះ" នឹងធ្វើឱ្យទាហានធម្មតា ដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ កម្មាភិបាលថ្នាក់លើរបស់ពួកគេ ដែលបានបញ្ជាពួកគេ ក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[67]។ យុត្តាធិការបុគ្គលបែបពីលើដល់ក្រោម និង គ្រប់ដណ្តប់យ៉ាងទូលាយបែបនេះ មិនមែនជាការប្រមើលមើលទុករបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. ដែល "បានដឹងថា នៅមានចារីប្រភេទនេះជាច្រើនសន្ធឹកសន្ធាប់ទៀត ហើយពួកគេនឹងមិនត្រូវបាននាំមកកាត់ទោស" នោះឡើយ[68]។ អ.ប.ជ. គួរចៀសវាងពីការអំពាវនាវយ៉ាងខ្លាំងក្លារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឱ្យបោះបង់ចោល កត្តាដែលបានទទួលស្គាល់រួចហើយ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែល ស.ច.ស. បានអនុវត្តស៊ីសង្វាក់គ្នារហូតមក ក្នុងរឿងក្តី ០០៤/១[69] រឿងក្តី ០០៤/២[70] និង រឿងក្តី ០០៣[71] ដែលជាចៃដន្យ ស.ព.អ. ទុកចោលដោយមិនទទួលស្គាល់យ៉ាងសាកសម មិនត្រូវបានច្រានចោលដោយ អ.ប.ជ.[72] ហើយអនុវត្តជំនួសវិញនូវកត្តា

---

អ.ស.ប.។ *សូមមើលផងដែរ* សេចក្តីសម្រេចលេខ ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ឯកសារ អ.ស.ប. លេខ S/RES/1534 (ឆ្នាំ ២០០៤) ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៤។

[67] កថាខណ្ឌ ១៩ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[68] កថាខណ្ឌ ១៩ នៃ ដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[69] កថាខណ្ឌ ៣-៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[70] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D359 កថាខណ្ឌ ៤២១-៤៨៤។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D360 កថាខណ្ឌ ៤៧-៥៦ ដែលដកស្រង់កថាខណ្ឌ ៣៧-៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[71] កថាខណ្ឌ ៣៦០-៤០៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣២-៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់កថាខណ្ឌ ៣៧-៤១ ដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[72] ទោះបីជា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទថា ការវិភាគរបស់ ស.ច.ស. អំពីតួនាទីរបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ជាការវិភាគខុសឆ្គងក្តី តែអង្គបុរេជំនុំជម្រះបានសម្រេចថា មិនមានកំហុសឆ្គងនៅក្នុងកត្តារបស់ ស.ច.ស. សម្រាប់ការសម្រេចលើជនទទួលខុសត្រូវខ្ពស់បំផុតឡើយ។ *សូមមើល* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងរឿងក្តី ០០៤/១ (សម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ៦៤-៨០។

បញ្ហនមិនពាក់ព័ន្ធរបស់សាលាក្តី ICTY ដែលមុខជានាំឱ្យមានការបដិសេធសិទ្ធិទទួលបានការប្រព្រឹត្តិស្មើភាពគ្នារបស់លោក មាស មុត[73]។

## III. ចម្លើយតបផ្នែក ៥ - សំណើទាក់ទងនឹងដីកាដំណោះស្រាយផ្ទុយគ្នា

១៥. ស.ព.អ. បានស្នើសុំដោយគ្មានហេតុផលឱ្យ អ.ប.ជ. អនុវត្តសុភាសិតប្រាសចាកផ្លូវច្បាប់ក្នុងតុលាការ គឺ *បើមានវិមតិសង្ស័យ ត្រូវជំនុំជម្រះ*។ ស.ព.អ. ស្នើបែបនេះ តាមរយៈការសុំឱ្យ អ.ប.ជ. មិនអើពើដោយមិនគោរពគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ទទួលស្គាល់ជាសកល[74] និង ទទួលយកដោយមិនសមហេតុផលនូវ "គោល

---

[73] មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខាផ្តល់សច្ចាប័ន និងចូលជាសមាជិក តាមរយៈសេចក្តីសម្រេចលេខ 2200A (XXI) របស់មហាសន្និបាត អ.ស.ប. នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមានថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ អនុលោមតាមមាត្រា ៤៩។ វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង។

[74] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលធ្វើវិសោធនកម្មតាមព្រះរាជក្រម ថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើប្រាស់វិសោធនកម្ម ទៅលើ មាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាដទៃទៀត ចាប់ពីជំពូក៨ ដល់ជំពូក១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានសភាជាតិអនុម័ត នៅថ្ងៃទី៤ ខែមីនា ឆ្នាំ ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា") មាត្រា ៣៨៖ "វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ មាត្រា ១២(២) ១៣(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីការដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១៖ "អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះ (គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ) ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស"។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវបានធានាតាមរយៈមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មិនអាចត្រូវបានចរចាដើម្បីគេចចេញឡើយ ដោយភាគីនៃកិច្ចព្រមព្រៀង។ *សូមមើលផងដែរ* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nurnberg តាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង រឿងក្តីពីក្រសួងនានា មតិជំទាស់របស់ចៅក្រម Powers ភាគ XIV (ខែតុលា ឆ្នាំ ១៩៤៦ - ខែមេសា ឆ្នាំ១៩៤៩) ទំព័រ ៨៧៨ "ហេតុនេះ បញ្ហាផ្នែកច្បាប់សម្រាប់យើងកំណត់ គឺមិនមែនថា តើអំពើជាក់លាក់មួយគួរតែជាឧក្រិដ្ឋកម្មដែរឬយ៉ាងណានោះទេ តែថា តើវាជាឧក្រិដ្ឋកម្មនៅក្រោមវិធានជាធរមាននៅទីនេះឬយ៉ាងណា ដោយត្រូវចងចាំក្នុងចិត្តជានិច្ចថា យើងគ្មានសិទ្ធិពង្រីកវិធានទាំងអស់នោះ តាមរយៈការបកស្រាយនោះទេ។ វាជាវិធានទូទៅដែលថា លក្ខន្តិកៈ និងវិធាននានា ដែលកំណត់និយមន័យឧក្រិដ្ឋកម្ម ត្រូវតែបកស្រាយយ៉ាងតឹងរ៉ឹង ជាប្រយោជន៍ដល់ជនជាប់ចោទ។ ចំណុចនេះមានន័យថា បញ្ហានានាពាក់ព័ន្ធ ការបកស្រាយដែលមានមន្ទិលសង្ស័យ គួរត្រូវបានដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba

នយោបាយ" បែបស្រមើស្រមៃ ដែលបញ្ជូនរឿងក្តីទៅជំនុំជម្រះ ក្នុងករណីដែល អ.ប.ជ. មិនអាចរកបានសំឡេងភាគច្រើនលើសលប់ សម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា ដែល ស.ព.អ. អះអាង ដោយគ្មានសំអាងហេតុគាំទ្រថា មានបង្ហាញច្បាស់ក្នុងវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល និង ក្នុងកិច្ចព្រមព្រៀង[75]។

១៦. ស.ព.អ. បកស្រាយច្បាប់ជាធរមានខុស ដោយអះអាងថា វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង "ចង្អុលបង្ហាញពីជម្រើសគោលនយោបាយ" ដែលធ្វើឱ្យមាន "ពាក្យពេចន៍ជាក់លាក់" ថា ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលប់នោះទេ រឿងក្តីប្រឆាំងលោក មាស មុត នឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការ[76]។ ប្រសិនបើជា "ពាក្យពេចន៍ជាក់លាក់" មែននោះ ស.ច.ស. នឹងមិនពិចារណារួមគ្នាថា "វិធានផ្ទៃក្នុង ៧៧(១៣) គ្រាន់តែចែងអំពីសេណារីយ៉ូ ដែលមានដីកាលើកលែងការចោទប្រកាន់ ឬ ក៏មានដីកាចោទប្រកាន់ បញ្ជូនទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នាទេ"[77] ហើយថា សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា គឺស្ថិតលើ អ.ប.ជ.[78]។ ស.ច.ស. ទាំងពីរនាក់ គឺជាសមាជិកនៃកិច្ចប្រជុំពេញអង្គ ដែលមានសិទ្ធិក្នុងការបោះឆ្នោត លើវិធានទាក់ទងនីតិវិធីរបស់ អ.វ.ត.ក.[79] ដូច្នេះហើយពួកគាត់ប្រាកដជាបានយល់ដឹងច្បាស់លាស់ អំពីនីតិវិធីដែលអាចអនុវត្តបានសម្រាប់ដីកាដំណោះស្រាយរបស់ពួកគាត់។

---

Gombo ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៣១ (ដែលសម្រេចថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ)។

[75] កថាខណ្ឌ ១៩១-១៩៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[76] កថាខណ្ឌ ១៩៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើលផងដែរ* កថាខណ្ឌ ១៩២-១៩៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[77] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[78] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៦។

[79] វិធាន ៣, ១៨(៣)(ខ) នៃវិធានផ្ទៃក្នុង។

១៧. ស.ព.អ. បានផ្តល់ព័ត៌មានខុស ដោយអះអាងថា វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺជា "*ច្បាប់ពិសេស* ទាក់ទងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ហេតុដូច្នេះ មានអនុភាពអនុវត្តលើពាក្យពេចន៍ទូទៅ នៅក្នុងវិធាន ៧៧(១៣)(ក)[80]។ ការលើកឡើងបែបនេះគឺជារឿងមិនសមហេតុផល និង ផ្ទុយពីគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* [81]។ ភាគីនៃកិច្ចព្រមព្រៀងមិនអាចចរចាឱ្យងាកចេញពីគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* នៅពេលរៀបចំក្របខណ្ឌ អ.វ.ត.ក. ដែលនាំឱ្យចៅក្រមអាចកាត់បន្ថយ បន្សាប ឬ មិនគោរពការអនុវត្តគោលការណ៍នេះ ក្នុងពេលព្រាងវិធានផ្ទៃក្នុង ដែលអនុវត្តតាមកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. នោះឡើយ[82]។

១៨. *មតិ* របស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល មិនបានគាំទ្រដល់ការបកស្រាយរបស់ ស.ព.អ. ទៅលើវិធាន ៧៧(១៣) នេះឡើយ[83]។ មតិនោះទាក់ទងនឹងការខ្វែងយោបល់គ្នារវាង ស.ច.ស. នៅក្នុងបរិបទនៃនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នារបស់ អ.ប.ជ. *នៅមុន* ពេលដែល ស.ច.ស. បញ្ចប់កិច្ចដំណើរការស៊ើបអង្កេត ពោលគឺនៅពេល "*ស្នើចេញ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់"[84]។ ស.ច.ស. មិនបានស្នើសុំឱ្យ អ.ប.ជ. ដោះស្រាយមតិខ្វែងគ្នារបស់ពួកគាត់ នៅមុនពេលចេញដីកាដំណោះស្រាយរបស់ខ្លួនឡើយ[85] ប៉ុន្តែ ជំនួសវិញ ស.ច.ស. បានឯកភាពគ្នាចេញដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងពេលជាមួយគ្នាទៅវិញ[86]។ តួនាទីរបស់ អ.ប.ជ. លើបណ្តឹងឧទ្ធរណ៍ មិនមែន "សម្រេចលើបញ្ហាជាក់លាក់ដែល [ស.ច.ស.] ខ្វែងយោបល់គ្នានោះទេ"[87]។ ប៉ុន្តែ តួនាទីរបស់ អ.ប.ជ. គឺត្រូវសម្រេចថា តើ ស.ច.ស. បានប្រើប្រាស់ឆន្ទានុសិទ្ធិខ្លួនបាន

---

[80] កថាខណ្ឌ ១៩៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[81] *សូមមើល* កថាខណ្ឌ ១៥ ជើងទំព័រ ៧៤ *ខាងលើ*។

[82] មេធាវីការពារក្តីសូមដាក់បញ្ចូល តាមរយៈឯកសារយោងនូវទឡ្ហីករណ៍ដែលបានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤៥-៤៦។

[83] កថាខណ្ឌ ១៩៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៦៥ នៃសាលដីកាលើរឿងក្តី ០០១។ *សូមមើលផងដែរ* កថាខណ្ឌ ១៩៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[84] កថាខណ្ឌ ៦៥ នៃសាលដីកាលើរឿងក្តី ០០១ (ការគូសបញ្ជាក់បន្ថែម) ដែលដកស្រង់មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក., មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង, វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[85] *សូមមើល* កថាខណ្ឌ ២៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[86] *សូមមើល* កថាខណ្ឌ ៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[87] កថាខណ្ឌ ៦៥ នៃសាលដីកាលើរឿងក្តី ០០១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

ត្រឹមត្រូវដែរឬយ៉ាងណា ក្នុងការឈានទៅដល់ការសន្និដ្ឋានរបស់ពួកគេ ដែលមានភាពផ្ទុយគ្នាដូច្នេះ[88]។ នាំឱ្យយល់ខុស ស.ព.អ. មានចេតនារំលងសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរួមគ្នារបស់ ស.ច.ស. ដែលសម្រេច *មិន* បញ្ជូនការខ្វែងយោបល់គ្នារបស់ពួកគាត់ ទាក់ទងនឹងលទ្ធផលនៃការស៊ើបអង្កេត ទៅឱ្យអ.ប.ជ. ដើម្បីចេញសេចក្តីសម្រេច[89]។

១៩. ស.ព.អ. បានផ្តល់ព័ត៌មានខុស ដោយអះអាងថា ការបកស្រាយរបស់គាត់ទៅលើវិធាន ៧៧(១៣) គឺស៊ីសង្វាក់គ្នានឹងស្មារតី និង វចនាសម្ព័ន្ធនៃក្របខណ្ឌ អ.វ.ត.ក. ដែល "គោរពតាមយ៉ាងរឹងមាំ" នូវគោលនយោបាយបញ្ជូនរឿងក្តីទៅជំនុំជម្រះនៅក្នុងសវនាការ[90]។ ស.ព.អ. នាំឱ្យយល់ខុស ដោយប្រដូចនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា តាមមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង ជាមួយនឹងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នា[91]។ ការពឹងផ្អែកដោយមិនពាក់ព័ន្ធទៅលើ David Scheffer[92] ដែលមិនមែនជាប្រភពគតិយុត្តិ និង មិនបានដាក់បង្ហាញនូវសម្ភារនៃការចរចាពាក់ព័ន្ធនោះ[93] ស.ព.អ. ខកខានមិនបានផ្តល់សំអាងហេតុសម្រាប់ការអះអាងរបស់គាត់ដែល

---

[88] *សូមមើល* កថាខណ្ឌ ២១ នៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៤/១ (សម្រេចជាឯកច្ឆន្ទ)។

[89] *សូមមើល* វិធាន ៧២(១) - (២) នៃវិធានផ្ទៃក្នុង។

[90] កថាខណ្ឌ ១៩៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[91] កថាខណ្ឌ ១៩៧-១៩៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[92] កថាខណ្ឌ ១៩៨ ជើងទំព័រ ៧៥៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់ David Scheffer *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៤៦ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២០០៨)។

[93] គួរកត់សម្គាល់ថា មេធាវីការពារក្តី ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដោយការយកចិត្តទុកដាក់ បានព្យាយាមរួមគ្នាក្នុងការស្វែងរកប្រភពនៃសម្ភារៈឯកសារ ដែលមានភាពពាក់ព័ន្ធ ដើម្បីស្វែងយល់អំពីបរិបទ និង ខ្លឹមសារនៃប្រវត្តិចរចារបស់ អ.វ.ត.ក.។ មេធាវីការពារក្តីបានផ្ញើលិខិតទៅលោក Scheffer ដែលជាអគ្គរដ្ឋទូតសុឆន្ទៈ សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម ដែលបានចូលរួមក្នុងការចរចា ដែលនាំទៅដល់ការបង្កើត អ.វ.ត.ក. (*សូមមើល* David Scheffer *ប្រវត្តិចរចាអំពីបញ្ញាយុត្តាធិការរបស់ អ.វ.ត.ក.* អ្នកឃ្លាំមើលសាលាក្តីកម្ពុជា ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១) និង លោក Stephen Heder ដែលជាអតីតអ្នកស៊ើបអង្កេត/អ្នកវិភាគរបស់ ក.ស.ព. និង ក.ស.ច.ស. ហើយដែលជាអ្នកនិពន្ធអំពីប្រវត្តិនៃការចរចា អ.វ.ត.ក. (*សូមមើល យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់" និង ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និង ដំណើរការវិវឌ្ឍន៍នាពេលថ្មីៗនេះ* អ្នកឃ្លាំមើលសាលាក្តីកម្ពុជា ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១២) ដោយស្នើសុំពួកគាត់ឱ្យផ្តល់នូវប្រភពនៃសម្ភារៈឯកសារ ដែលមានភាពពាក់ព័ន្ធទាំងអស់។ ស.ច.ស.អ. Bohlander ចាត់ទុកថា លិខិតរបស់មេធាវីការពារក្តី គឺជាកិច្ចស៊ើបសួរ ដែលស្ថិតក្នុងសមត្ថកិច្ចទាំងស្រុងរបស់ ស.ច.ស. ហើយបានស្នើដល់លោក Scheffer និង លោក Heder ឱ្យបញ្ជូនចម្លើយតបរបស់ពួកគេ មកកាន់គាត់។ លោក Scheffer បានជម្រាបដល់ ស.ច.ស.អ. ថា "បន្ទាប់ពីបានប្រឹក្សាជាមួយការិយាល័យទីប្រឹក្សាច្បាប់របស់ក្រសួងការបរទេស

ថា កិច្ចព្រមព្រៀង "ផ្តល់នូវគោលការណ៍ណែនាំច្បាស់លាស់" ដែលថា រឿងក្តីត្រូវបន្តទៅជំនុំជម្រះ នៅពេលដែល អ.ប.ជ. មិនអាចដោះស្រាយបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នា[94]។ ផ្នែក ដែលបានដកស្រង់ពីសៀវភៅរបស់លោក Scheffer គឺទាក់ទងនឹងនីតិវិធីដោះស្រាយការខ្វែង យោបល់គ្នា មិនមែនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នានោះទេ[95]។

២០. *ជារួម* ការអះអាងរបស់ ស.ព.អ. មិនមានមូលដ្ឋាន ហើយក៏មិនមានធម្មនុញ្ញភាពដែរ។ គម្រោងការ របស់គាត់ក្នុងការជម្រុញសេណារីយ៉ូដែលថា រឿងក្តីប្រឆាំងលោក មាស មុត នឹងមិនអាចបញ្ជូនទៅ ជំនុំជម្រះបាន តែក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានច្រានចោលដោយសំឡេងភាគ ច្រើនលើសលប់លើបណ្តឹងឧទ្ធរណ៍នោះ គឺមិនអើពើនឹងគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ ដល់ជនត្រូវចោទ* ឡើយ។ ក្រៅពីការក្លែងបន្លំសម្មតិកម្មទាំងអស់នេះ ថាជាការបកស្រាយយ៉ាង លម្អិត នូវប្រភពគតិយុត្តិដែលចងកាតព្វកិច្ចឱ្យអនុវត្តតាម ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញ ទាល់តែសោះថា រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានអនុម័ត "គោលនយោបាយ" នៃការច្រាន ចោលតាមលទ្ធភាព នូវគោលការណ៍ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ទទួលស្គាល់ជាសកល រួម ជាមួយសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយទទួលយកវិធីសាស្ត្រជាប្រយោជន៍ដល់ អយ្យការ ដែលធ្វើតាមអំពើចិត្ត និង មិនខ្វល់ខ្វាយ ដោយបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ពីរនាក់ ដែលមានសិទ្ធិស្មើគ្នា និង ឯករាជ្យ ចេញដីកាដំណោះស្រាយផ្ទុយគ្នា មានអនុភាព អនុវត្តដូចគ្នា។ ការដែលមិនអាចស្វែងរកសំឡេងភាគច្រើនលើសលប់ថា ស.ច.ស. មានកំហុស ឬ

---

ស.វ.អ. និង ជាមួយការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិរួចមក ឯកសារមួយចំនួនដែលមេធាវីការពារក្តីស្នើ សុំ មិនអាចដាក់បង្ហាញបានឡើយ"។ ចំពោះឯកសារដទៃផ្សេងទៀត លោក Scheffer បានជូនយោបល់ដល់ ស.ច.ស.អ. ឱ្យធ្វើ ការទាក់ទងជាមួយនឹងក្រសួងការបរទេស ស.វ.អ.។ ក្រសួងការបរទេស ស.វ.អ. មិនបានឆ្លើយតបទាល់តែសោះ ចំពោះសំណើ សុំឯកសាររបស់ ស.ច.ស.អ. ។ លោក Heder បានជម្រាបដល់ ស.ច.ស.អ. ថា ភាគច្រើនលើសលប់នៃឯកសារ ដែលមេធាវី ការពារក្តីស្នើសុំ គឺលោកលែងមានក្នុងដៃទៀតហើយ។ កំណត់ហេតុនៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D224 ERN 01428544-01428546។ លិខិតជូនចំពោះលោក David Scheffer ដែលមានចំណងជើងថា "សំណើសុំ ប្រភពនៃសម្ភារៈឯកសារ ដែលទាក់ទងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D224.2។ សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុត របស់អង្គការសហប្រជាជាតិ ថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D181/1។

[94] កថាខណ្ឌ ១៩៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[95] David Scheffer *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៤៦ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២០០៨)។

ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ ដែលអាចប៉ះពាល់ដល់ការ អនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដែលមិនមានចំណុចណាមួយកើតឡើងនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មិនអាចត្រូវបានច្រានចោលនោះទេ។ បើទោះបីជា អ.ប.ជ. ច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសំឡេងភាគច្រើនលើសលប់ ដោយផ្អែកលើមូលដ្ឋានដែលថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ក៏ដោយ ក៏ អ.ប.ជ. នៅតែត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលប់ដែរ ដើម្បីអាចឱ្យរឿងក្តីបន្តទៅដំណាក់កាលជំនុំជម្រះនោះ[96]។

## IV. ចម្លើយតបនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍

### ក. ចម្លើយតបនឹងមូលដ្ឋាន "ខ"៖ ស.ច.ស.ជ. មិនមានកំហុសផ្នែកច្បាប់ ក្នុងការមិនពិចារណាទៅលើភ័ស្តុតាងដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១

២១. ស.ព.អ. បកស្រាយខុស នូវករណីយកិច្ចស៊ើបអង្កេតរបស់ ស.ច.ស. ដោយអះអាងថា ការស៊ើបអង្កេត នៅមុនការជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ មាន លក្ខណៈមិនពេញលេញ ដោយសារតែ ស.ច.ស. មិនបាន "ស៊ើបសួរយ៉ាងត្រឹមត្រូវ មិនលម្អៀង និង ដោយមានប្រសិទ្ធភាព" ទៅលើអង្គហេតុនានា ដែលខ្លួនបានទទួល[97] ហើយថា ការបើកកិច្ចស៊ើបសួរឡើងវិញ ដោយ ស.ច.ស.អ. បម្រុង Laurent Kasper-Ansermet និង ការបន្តដោយ ស.ច.ស.អ. Harmon និង ស.ច.ស.អ. Bohlander ធ្វើឱ្យសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរនោះ "ត្រូវបានមោឃភាពតាមផ្លូវច្បាប់"[98]។ ការស៊ើបសួរត្រូវបានបញ្ចប់យ៉ាងពេញលេញ នៅពេលដែល ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានចេញសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួររួមគ្នា។ សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរមិនអស់សុពលភាពឡើយ នៅពេលដែល ស.ច.ស.អ. បម្រុង Kasper-Ansermet បានបើកកិច្ចស៊ើបសួរឡើងវិញ ហើយក៏មិនអាចមោឃភាព ដោយកិច្ចស៊ើបសួរដែលត្រូវបានធ្វើឡើង នៅក្រោយពេលបើកកិច្ចស៊ើបសួរឡើងវិញនោះដែរ។ ស.ច.ស.ជ.

---

[96] *សូមមើល* កថាខណ្ឌ ៤៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[97] កថាខណ្ឌ ៣៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើលផងដែរ* កថាខណ្ឌ ៤៣-៥៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[98] កថាខណ្ឌ ៣៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើលផងដែរ*កថាខណ្ឌ ៣៦-៤២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

មិនត្រូវបានតម្រូវឱ្យពិចារណាលើភ័ស្តុតាងដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដើម្បីអាចឱ្យគាត់ប្រើប្រាស់ត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់គាត់ ក្នុងការឈានទៅដល់ការសម្រេចរបស់គាត់លើយុត្តាធិការបុគ្គលនោះឡើយ។

២២. ***កិច្ចស៊ើបសួរត្រូវបានបញ្ចប់ពេញលេញ នៅពេលដែល ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានរួមគ្នាចេញសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ*** ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានស៊ើបអង្កេតលើអង្គហេតុទាំងអស់ដែលពួកគាត់បានទទួល ហើយបានប្រមូលសម្ភារឯកសារដែលចាំបាច់សម្រាប់សម្រេចថាការស៊ើបអង្កេតរបស់ខ្លួនចប់សព្វគ្រប់ នៅមុនពេលចេញសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ។ ស.ព.អ. ខកខានមិនបានបង្ហាញភ័ស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ការស៊ើបអង្កេត "មិនត្រឹមត្រូវ លម្អៀង និង គ្មានប្រសិទ្ធភាព"[99]។ ក្រៅតែពីការអះអាងជាទូទៅថា ស.ច.ស. ងាកចេញពី "កាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តការយកចិត្តទុកដាក់ដ៏ហ្មត់ចត់ ក្នុងការធ្វើការស៊ើបអង្កេតពិតប្រាកដ និង ប្រកបដោយប្រសិទ្ធភាព"[100] នោះ ស.ព.អ. ខកខានមិនបានទទួលស្គាល់ថា លក្ខខណ្ឌតម្រូវទាំងនេះ មិនបានបង្កើតឱ្យមាន "សិទ្ធិដាច់ខាត... ដើម្បីឈានដល់ការជំនុំជម្រះ ឬ ការផ្តន្ទាទោស"[101] និង មិនបានបង្ហាញឱ្យឃើញថា តើការស៊ើបអង្កេតដែលបញ្ចប់កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ មិនអាច "នាំទៅដល់ការកំណត់លើអង្គហេតុ ... និង ក្នុងករណីសមស្រប ធ្វើការកំណត់អត្តសញ្ញាណ និង ដាក់ទណ្ឌកម្មចំពោះអ្នកទទួលខុសត្រូវ"[102] ដោយរបៀបណានោះឡើយ។ នៅពេលអះអាងថា ការស៊ើបអង្កេតមានភាពលម្អៀង ស.ព.អ. ក៏ខកខានផងដែរ មិនបានបង្ហាញបន្ថែមនូវទឡ្ហីករណ៍ណាមួយ កុំថាឡើយដល់ទៅបង្ហាញឱ្យឃើញថា ស.ច.ស. ណាម្នាក់ ឬ ទាំងពីរនាក់ "អាចមានភាពលម្អៀងពិតប្រាកដមែន" នោះ[103]។ ហេតុដូច្នេះ

---

[99] កថាខណ្ឌ ៤៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើលផងដែរ* កថាខណ្ឌ ៣៥, ៤៤-៥៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[100] កថាខណ្ឌ ៤៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (ការដកស្រង់ខាងក្នុងត្រូវបានលុបចេញ)។

[101] *រឿងក្តី Brecknell តទល់នឹង ចក្រភពអង់គ្លេស* ECtHR បណ្តឹងលេខ 32457/04 សាលក្រម ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៦៦។

[102] *រឿងក្តី Armani Da Silva តទល់នឹងចក្រភពអង់គ្លេស* ECtHR បណ្តឹងលេខ 5878/08 សាលក្រម ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៣៣។

[103] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ០១) សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះចៅក្រម ន័យ ធុល ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ C11/29 កថាខណ្ឌ ១៩។

អ.ប.ជ. គួរតែច្រានចោលភ្លាមៗ នូវការអះអាងដែលមិនពេញលេញ និង គ្មានការគាំទ្រដែលថា ការស៊ើបអង្កេតមានភាពលម្អៀង[104]។

២៣. ដូចដែលបានតម្រូវតាមក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក. ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានបំពេញកិច្ចដោយយកចិត្តទុកដាក់[105] ត្រឹមត្រូវ[106] និង ឆាប់រហ័ស[107] ក្នុងការអនុវត្តកិច្ចស៊ើបសួរពិតប្រាកដ និង ប្រកបដោយប្រសិទ្ធភាព។ ស.ច.ស. បានប្រមូលភ័ស្តុតាង ទាក់ទងអង្គហេតុទាំងអស់ ដែលខ្លួនបានទទួល ដោយវិភាគយ៉ាងហ្មត់ចត់លើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. និង បានបង្កើតកត្តាដើម្បីវាយតម្លៃថា តើលោក មាស មុត ត្រូវទទួលខុសត្រូវចំពោះអង្គហេតុ ដែលពួកគាត់បានស៊ើបអង្កេតដែរឬយ៉ាងណា។

២៤. *ស.ច.ស. បានបំពេញកិច្ចស៊ើបសួរដោយយកចិត្តទុកដាក់* ស.ព.អ. ខកខានមិនបានទទួលស្គាល់នូវការយកចិត្តទុកដាក់ ដែល ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានបំពេញកិច្ចស៊ើបសួរយ៉ាងពិតប្រាកដ និង ប្រកបដោយប្រសិទ្ធភាព[108]។ នៅពេលដែលកិច្ចស៊ើបសួរបានចាប់ផ្តើម នៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៩[109] ស.ច.ស.ជ. និង ស.ច.ស.អ. Lemonde បានបង្កើតផែនការសកម្មភាពលម្អិតដើម្បីស៊ើបអង្កេតលើលោក មាស មុត[110]។ នៅពេលដែល ស.ច.ស.អ. Lemonde បានលាលែងពីតំណែងនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០ ការស៊ើបអង្កេតកំពុងតែបន្តដំណើរការយ៉ាងប្រសើរ[111]។ នៅពេលដែល ស.ច.ស.អ. Blunk ចូលកាន់តំណែងបន្តពី ស.ច.ស.អ. Lemonde នៅថ្ងៃទី ០១ ខែ

---

[104] កថាខណ្ឌ ២០ នៃសាលដីកាលើរឿងក្តី ០០១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

[105] មាត្រា ៥(១) នៃក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក.។

[106] មាត្រា ៥(៣) នៃក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក។

[107] មាត្រា ៥(៣), ៥(៤) នៃក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក.។

[108] កថាខណ្ឌ ៤៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[109] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។

[110] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ២៦ (ខែ មិថុនា ឆ្នាំ ២០១០) ទំព័រ ២ https://www.eccc.gov.kh/sites/default/files/publications/The%20Court%20Report%20%5BJune%202010%5D%20FINAL.pdf ។

[111] *សូមមើល* កថាខណ្ឌ ១៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

ធ្នូ ឆ្នាំ ២០១០[112] គាត់បានបន្តការស៊ើបអង្កេតរួមជាមួយ ស.ច.ស.ជ. ដោយចាប់ផ្តើមពីចំណុចដែលការស៊ើបអង្កេតនៅសល់[113]។ ពួកគាត់ "បានបង្កើតក្រុមការងាររួមគ្នា"[114] "បានឯកភាពគ្នាលើវិធីសាស្ត្រនៃការស៊ើបអង្កេត"[115] និង បានស៊ើបអង្កេត "ដោយរលូន និង ឯកភាពគ្នាទាំងស្រុង"[116]។

២៥. ការបង្ហាញពីការយកចិត្តទុកដាក់ ក្នុងការស៊ើបអង្កេតទៅលើអង្គហេតុទាំងអស់ ដែល ស.ច.ស. បានទទួល តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង *តែ* ចំពោះអង្គហេតុទាំងនោះ[117] ស.ច.ស.អ. បានស្នើសុំទៅ ស.ព.អ. ឱ្យបញ្ជាក់បំភ្លឺថា តើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពិតជាមានបំណងចង់ឱ្យ ស.ច.ស. ធ្វើការស៊ើបសួរ ទៅលើមន្ទីរសន្តិសុខទាំងអស់របស់កងទ័ពបដិវត្តកម្ពុជា ("ក.ប.ក.") និង ទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតនៅទូទាំងប្រទេសកម្ពុជា ដែលមានការចោទប្រកាន់ថា មានការបោសសម្អាត ក.ប.ក. កើតឡើងឬយ៉ាងណា[118]។ ស.ព.អ. បានបញ្ជាក់បំភ្លឺថា ស.ច.ស. មិនត្រូវបានស្នើសុំ ឱ្យធ្វើការស៊ើបអង្កេតទៅលើមន្ទីរសន្តិសុខរបស់ ក.ប.ក. ទាំងអស់ ឬ ទៅលើទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតក្រៅពី "កំណត់អត្តិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម និង ការកើតឡើងនៃឧក្រិដ្ឋកម្មដ៏ទូលំទូលាយ និង ជាប្រព័ន្ធ"[119] និង គុក ៨១០ ដែល "បានធ្វើការស៊ើបសួររួច

---

[112] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. *បណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ https://www.eccc.gov.kh/en/articles/dr-siegfried-blunk-appointed-new-international-co-investigating-judge។

[113] *សូមមើល* កថាខណ្ឌ ១៥ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[114] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ៣៣ (ខែ កុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ https://www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[115] កថាខណ្ឌ ៤៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[116] កថាខណ្ឌ ៤១ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[117] វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៣៥-៣៦។

[118] សំណើសុំការបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D1/2 ដែលយោងកថាខណ្ឌ ១ (៣), ៦៥-៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[119] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D1/2/1 កថាខណ្ឌ ២ ដែលយោងកថាខណ្ឌ ៦៥-៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ហើយ ក្នុងសំណុំរឿងក្តី ០០២"[120]។ ដោយសារវិសាលភាពនៃកិច្ចស៊ើបសួររបស់ពួកគាត់ ត្រូវបានបញ្ជាក់បំភ្លឺ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានបន្តពិនិត្យមើលភស្តុតាងជាឯកសារ និង បានដាក់សម្ភារឯកសារពាក់ព័ន្ធជាងមួយពាន់ទំព័រ ទៅក្នុងសំណុំរឿងក្តី ០០៣[121]។ ឯកសារទាំងនោះរួមមានសារទូរលេខ កំណត់ហេតុកិច្ចប្រជុំ ចម្លើយពីសាក្សីផ្ទៃក្នុង ដូចជា កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ការស្តាប់ចម្លើយសាក្សីផ្សេងទៀត និង សម្ភារៈឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[122]។

២៦. នៅពេលដែល ស.ច.ស. បានចេញរួមគ្នានូវសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[123] ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានដាក់ចូលក្នុងសំណុំរឿង នូវសម្ភារឯកសារដែលពាក់ព័ន្ធជាមួយអង្គហេតុទាំងអស់ ដែលពួកគាត់បានទទួលតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមបញ្ចូលទាំងទីតាំងឧក្រិដ្ឋកម្ម ដែលជាប់ទាក់ទងនឹងអង្គហេតុដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះផងដែរ[124]។

---

[120] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D1/2/1 កថាខណ្ឌ ៣ ដែលយោងកថាខណ្ឌ ៦៣-៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[121] ដីកាសម្រេចស្តីពីការដាក់ឯកសារសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១១ ឯកសារ D4 (ដែលបានដាក់ឯកសារចំនួន ១១៥៦ ឯកសារ ចូលក្នុងសំណុំរឿង ០០៣)។ ដីកាសម្រេចស្តីពីការដាក់ឯកសារសំណុំរឿង ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០១១ ឯកសារ D9 (ដែលបានដាក់ឧបសម្ព័ន្ធចំនួនបី ដែលចងក្រងនូវបញ្ជីអ្នកទោសមន្ទីរសន្តិសុខ ស-២១ មកពីកងពលធំ ១៦៤, ៥០២ និង ៨០១)។ ដីកាសម្រេចស្តីពីការដាក់ឯកសារសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០១១ ឯកសារ D10 (ដែលបានដាក់ឯកសារចំនួន ១៣១ ឯកសារ ចូលក្នុងសំណុំរឿង ០០៣)។

[122] កថាខណ្ឌ ២, ៤២, ៤៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[123] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។

[124] *សូមមើល ឧទា.* <u>មន្ទីរសន្តិសុខទឹកសាប៖</u> កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ ឯកសារ D4.1.477។ បទសម្ភាសន៍ជាមួយលោក សំ សុក (POW/MIA) ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០២ ឯកសារ D4.1.746។ ឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស - ក្រុមការងារភាពយន្តរបស់ពួកកុម្មុយនីស្តខ្មែរបានថតខ្សែភាពយន្តពីកោះតាងបន្ទាប់ពីឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០៥ ឯកសារ D4.1.757។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6។ <u>ចំការគុមនេះ៖</u> កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/17។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/16។ របាយការណ៍របស់ DC-Cam ដែលមានចំណងជើងថា "ទម្រង់នៃការដ្ឋាន ស៊ីហ្សុីភី" របាយការណ៍ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅទីក្រុងសីហនុ រួមមានរបាយការណ៍ស្តីពីការដ្ឋានកោះខ្យង ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ឯកសារ D4.1.1026។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15។ ការដ្ឋានតំបន់រាម (រួមទាំងបិតត្រាំង និង កងកេង)៖ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ

ស.ព.អ. បាននាំឱ្យមានការយល់ខុស ដោយអះអាងថា ស.ច.ស.អ. ដែលចូលកាន់តំណែងបន្ត បាន ដាក់ "ឯកសារចំនួន ២៤៦៧ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន" ទៅក្នុងសំណុំរឿង នៅក្រោយពេលដែលកិច្ចស៊ើបសួរ ត្រូវបានបើកឡើងវិញជាថ្មី[125]។ ការប្រៀបធៀបបែប ទិន្នន័យ គឺមិនមានភាពពាក់ព័ន្ធឡើយ ក្នុងការវាយតម្លៃថា តើការស៊ើបអង្កេតមានលក្ខណៈពិតប្រាកដ និង មានប្រសិទ្ធភាព និង ថាតើកិច្ចស៊ើបអង្កេតនោះត្រូវបានបញ្ចប់ពេញលេញដែរឬយ៉ាងណានោះ។

២៧. *ស.ច.ស. បានបំពេញកិច្ចស៊ើបសួរយ៉ាងត្រឹមត្រូវ* ស.ព.អ. បានផ្តល់ព័ត៌មានខុស ដោយអះអាងថា ស.ច.ស. ត្រូវ "ចាត់វិធានការស៊ើបអង្កេតជាក់ស្តែង" ដើម្បីស្វែងរកចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា[126] ធ្វើការចុះស៊ើបអង្កេតដល់មូលដ្ឋានផ្ទាល់[127] ឬ ធ្វើការស្តាប់ចម្លើយសាក្សីបន្ថែម[128] ទើប

---

២០១០ ឯកសារ D2/16។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/9។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/17។ បទសម្ភាសន៍ជាមួយលោក ឯក នី (POW/MIA) ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០២ ឯកសារ D4.1.747។ បទសម្ភាសន៍លោក សេង សិន ខៀវ នុក អំពីទីតាំងសាកសព និង គ្រាប់មីននៅលើកោះតាង ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៣ ឯកសារ D4.1.749។ ទូរលេខដែលមានចំណងជើងថា "ទូរលេខ ១១ ជូនបង មុត ជ្រាបសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699។ ការរៀបចំចាត់ចែងតំបន់ ៣៧ និង កងពលធំ ៣/១៦៤ នៅកោះតាង បន្ទាប់ពីឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០០៥ ឯកសារ D4.1.754។ របាយការណ៍របស់សហព្រះរាជអាជ្ញា ដែលមានចំណងជើងថា "ឯកសារទំនាក់ទំនងរបស់ខ្មែរក្រហម ឆ្នាំ១៩៧៥-១៩៧៨" ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D4.1.655។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/10។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី លឿង ប៊ុន្នី ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D4.1.889។ បទសម្ភាសន៍ជាមួយ កាំ ម៉ែន (POW/MIA) ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០០០ ឯកសារ D4.1.762។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ប៊ុនឡេង ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១១ ឯកសារ D8។ របាយការណ៍ដែលមានចំណងជើងថា "សភាពការណ៍ខ្មាំងខាងក្រៅ និង សភាពការណ៍ផ្ទៃក្នុង" ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ១៩៧៨ ឯកសារ D4.1.1023។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ ខុន ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៩ ឯកសារ D4.1.795។

[125] កថាខណ្ឌ ៥៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[126] កថាខណ្ឌ ៥១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ ស.ច.ស.ជ. និង ស.ច.ស.អ. Bohlander បានពិចារណារួមគ្នាថា កិច្ចការស្តាប់ចម្លើយរបស់ DC-Cam ដែលប្រមូលបានដោយមិនមានការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវទទួលបាននូវតម្លៃជាភស្តុតាងទាបជាងការស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យ ស.ច.ស.។ *សូមមើល* កថាខណ្ឌ ១០៣-១០៤ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[127] កថាខណ្ឌ ៥១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

កិច្ចស៊ើបសួររបស់ពួកគាត់ មានភាពពិតប្រាកដ និង ប្រកបដោយប្រសិទ្ធភាព។ ស.ច.ស. មានឆន្ទានុសិទ្ធិក្នុងការអនុវត្ត កិច្ចស៊ើបសួរ *ណាមួយ* ដែលខ្លួនចាត់ទុកថា មានភាពចាំបាច់នាំទៅដល់ការស្វែងរកការពិត[129] ទាក់ទងនឹងអង្គហេតុទាំងអស់ដែលខ្លួនបានទទួល[130]។ ខណៈដែលស.ច.ស.ដែលមានឆន្ទានុសិទ្ធិក្នុងការ "រៀបចំ *យុទ្ធសាស្ត្រ* សម្រាប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ"[131] ពួកគេមិនបានតម្រូវឱ្យបង្ហាញពីវិធីសាស្ត្រក្នុងការស៊ើបអង្កេតនោះឡើយ[132] ស.ច.ស.អ. Blunk បានពន្យល់ថា៖

> បទពិសោធន៍សាមសិបឆ្នាំរបស់ខ្ញុំ ក្នុងនាមជាចៅក្រម និង ជារដ្ឋអាជ្ញា បានបង្រៀនខ្ញុំថា ឯកសារគឺជាភស្តុតាងដែលគួរឱ្យជឿជាក់បំផុត ដោយហេតុនេះហើយ ទើបធនធាននៃការិយាល័យ [នៃ ស.ច.ស.] ត្រូវបានផ្តោតមួយរយៈពេល ទៅលើការវិភាគឯកសារភស្តុតាងចំនួន ១០០០០ និង កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៧០០ ដែលចងក្រងក្នុងរឿងក្តី ០០២ ដើម្បីស្វែងរកភាពពាក់ព័ន្ធ ជាមួយនឹងរឿងក្តី ០០៣ និង រឿងក្តី ០០៤។

---

[128] កថាខណ្ឌ ៥០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[129] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធិរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩ C20/5/18 កថាខណ្ឌ ៦៣។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុង ឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតចំពោះ "សំណើសុំបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/5 កថាខណ្ឌ ១៥។

[130] វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D198/1 កថាខណ្ឌ ៦ ជើងទំព័រ ១។

[131] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតចំពោះ "សំណើសុំបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/5 កថាខណ្ឌ ១៥ (ការគូសបញ្ជាក់បន្ថែមនៅក្នុងសំណៅដើម)។

[132] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតចំពោះ "សំណើសុំបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៤០។

បន្ទាប់ពីបញ្ចប់ការវិភាគនេះហើយ ការចុះស៊ើបសួរដល់ទីកន្លែងត្រូវចាប់ផ្តើមឡើងវិញ ហើយសាក្សីសំខាន់ៗត្រូវបានស្តាប់ចម្លើយ រួមទាំង ឌុច ផងដែរ[133]។

២៨. ស.ព.អ. ថ្លែងខុសអំពីខ្លឹមសារនៃសំណុំរឿង នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដោយអះអាងថា "មានតែកំណត់ហេតុស្តាប់ចម្លើយចំនួន ២០ ប៉ុណ្ណោះ ... ពីសាក្សីចំនួន ១៧ នាក់"[134]។ មានកំណត់ហេតុស្តាប់ចម្លើយចំនួនច្រើនជាង ៤៣០[135]។ ចំពោះបញ្ហាថា តើកំណត់ហេតុស្តាប់ចម្លើយចំនួន ២០ ដែល ស.ព.អ. បានលើកឡើង កើតចេញពីសំណុំរឿងផ្សេងទៀត ឬ មកពីសំណុំរឿង ០០៣ និង ថាតើចាំបាច់ត្រូវមានការស្តាប់ចម្លើយបន្ថែមទៀតឬយ៉ាងណានោះ គឺស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. ផ្តាច់មុខ។

២៩. ស.ព.អ. ចោទប្រកាន់ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk ថាបានរំលោភបំពានដោយចេតនាលើសម្បថរបស់ពួកគេ ដោយអះអាងថា ស.ច.ស. "បានតមយ៉ាងសកម្ម" មិនដាក់របាយការណ៍ស៊ើបអង្កេតចំនួនប្រាំបី (និង ឯកសារភ្ជាប់នៃរបាយការណ៍ទាំងនោះ) ទៅក្នុងសំណុំរឿង[136]។ ទោះជាក្នុងស្ថានភាពណាក៏ដោយ នេះគឺជាការធ្វេសប្រហែស។ របាយការណ៍ស៊ើបអង្កេតចំនួនប្រាំបី (និង ឯកសារភ្ជាប់នៃរបាយការណ៍ទាំងនោះ) ត្រូវបានព្រាងឡើង អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលចេញដោយ ស.ច.ស.អ. Lemonde តែម្នាក់ឯង[137] ហើយដែលរបាយការណ៍ទាំងនោះត្រូវបានដាក់ជូនគាត់ទាំងអស់ នៅមុនពេលដែលគាត់លាឈប់ពីមុខតំណែង[138]។ ដូចដែល ស.ព.អ.

---

[133] Thomas Miller *ចៅក្រមសាលាក្តីខ្មែរក្រហមពិភាក្សាអំពីបញ្ហាប្រឈមរបស់តុលាការ* សារពត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១ ដែលអាចរកបាននៅតាមគេហទំព័រ៖ https://www.phnompenhpost.com/national/krt-judge-talks-court-controversies ។

[134] កថាខណ្ឌ ៥០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[135] ការស្វែងរកនៅលើ ZyLAB បង្ហាញថា ការិយាល័យ ស.ច.ស. បានដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តែជាភាសាអង់គ្លេសចំនួន ៤៣៦ ទៅក្នុងសំណុំរឿង នៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១។ *សូមមើល* ZyLAB "Case File: CF003" "Language: English" "Title: written record of interview* " "Filing Date: before 29th April 2011" "Document Date: before 29th April 2011" និង "Filing Party: OCIJ"។ ឯកសារខ្លះដែលបានដាក់ទៅក្នុងសំណុំរឿង នៅក្នុងអំឡុងពេលនេះ អាចជាន់គ្នា។

[136] កថាខណ្ឌ ៥១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[137] ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D2។

[138] *សូមមើល* របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D64.1.1។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D64.1.13។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D2/24។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២៧ ខែ

បានយល់ស្រប របាយការណ៍ទាំងអស់នេះ មិនត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍បញ្ចប់ដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលត្រូវដាក់ជូន ស.ច.ស.ជ. និង ស.ច.ស.អ. Blunk នៅក្រោយពេលដែល ស.ច.ស.អ. Lemonde បានចាកចេញឡើយ[139]។ ដោយសារតែ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានដាក់ចូលទៅក្នុងសំណុំរឿង នូវឯកសារផ្សេងទៀតទាំងអស់ ដែលជាឯកសារភ្ជាប់នៃរបាយការណ៍បញ្ចប់ដីកាចាត់ឱ្យស៊ើបសួរជំនួស[140] ហើយដោយសារតែ ស.ច.ស.អ. បម្រុង Kasper-Ansermet មិនបានដាក់របាយការណ៍ស៊ើបអង្កេតទាំងប្រាំបី ចូលទៅក្នុងសំណុំរឿង និង ដោយសារតែ ស.ច.ស.អ. Harmon និង ស.ច.ស.អ. Bohlander បានដាក់របាយការណ៍ទាំងនោះចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១៣[141] និង ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៧[142] ទើបការអះអាងរបស់ ស.ព.អ. គឺជាការអះអាងយ៉ាងគឃ្លើន និង នាំឱ្យយល់ច្រឡំ។ ដោយ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានដាក់ចូលទៅក្នុងសំណុំរឿង នូវឯកសារចំនួន ៣៩ ដែលជាឯកសារភ្ជាប់នៃរបាយការណ៍ស៊ើបអង្កេតទាំងប្រាំបីនោះផងដែរ ដោយផ្អែកលើការពិនិត្យរបស់

---

កក្កដា ឆ្នាំ ២០១០ ឯកសារ D64.1.14។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១០ ឯកសារ D64.1.16។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D64.1.17។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D64.1.20។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D64.1.21។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D64.1.49។

139 កថាខណ្ឌ ៥១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើល* របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D2/1។ តារាងសង្ខេបឯកសារ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D2/1.1។

140 តារាងសង្ខេបឯកសារ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D2/1.1។

141 *សូមមើល* របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D64.1.1។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D64.1.13។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D64.1.14។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១០ ឯកសារ D64.1.16។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D64.1.17។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D64.1.20។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D64.1.21។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D64.1.49។

142 *សូមមើល* របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D2/24។

ពួកគាត់ ទៅលើសម្ភារឯកសារនៃរឿងក្ដី ០០២[143] នេះគ្រាន់តែបង្ហាញថា ស.ច.ស. បានបំពេញកិច្ច យ៉ាងត្រឹមត្រូវ និង ដោយស្មោះត្រង់ ក្នុងការធ្វើការស៊ើបសួរដែលពិតប្រាកដ និង ប្រកបដោយ ប្រសិទ្ធភាពប៉ុណ្ណោះ។

៣០. *ស.ច.ស. បានបំពេញកិច្ចស៊ើបសួរយ៉ាងឆាប់រហ័ស* ស.ព.អ. បានកំណត់ចរិកលក្ខណៈខុសទៅលើ ការវាយតម្លៃរបស់ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk លើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ចំពោះលោក មាស មុត បន្ទាប់ពីមានកិច្ចស៊ើបសួរក្នុងរយៈពេលចំនួន ២០ ខែ ថាជា "ទស្សនៈ បឋម"[144]។ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ យុត្តាធិការបុគ្គលមិនមែនជាបញ្ហាគតិយុត្តិថ្មី សម្រាប់ ស.ច.ស. ឡើយ។ ស.ច.ស.ជ. បានបំពេញកិច្ចស៊ើបសួរលើ ឌុច អស់រយៈពេលចំនួន ១០ ខែ[145] និង បានសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[146]។ ស.ច.ស.ជ. ក៏បានស៊ើប អង្កេតផងដែរលើ នួន ជា ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ អស់រយៈពេលចំនួន ៣០ ខែ[147] និង បានសម្រេចថាពួកគេ គឺជាមេដឹកនាំជាន់ខ្ពស់ ឬ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[148]។

៣១. ដើម្បីបំពេញកិច្ចស៊ើបសួរដែលពិតប្រាកដ និង ប្រកបដោយប្រសិទ្ធភាព ស.ច.ស. មិនត្រឹមតែត្រូវ កំណត់អង្គហេតុប៉ុណ្ណោះទេ ថែមទាំងត្រូវកំណត់អត្តសញ្ញាណ អ្នកដែលទទួលខុសត្រូវផងដែរ[149]។ ក្នុងអំឡុងពេលស៊ើបសួរលើអង្គហេតុទាំងអស់ ដែល ស.ច.ស. បានទទួល ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានធ្វើការ "វិភាគស៊ីជម្រៅទៅលើប្រភពដើម និង អត្ថន័យនៃពាក្យ 'ទទួលខុស ត្រូវខ្ពស់បំផុត'" និង បានបង្កើតកត្តា "ផ្អែកលើច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ព្រមទាំងយុត្តិសាស្ត្រ

---

[143] ដីកាសម្រេចស្ដីពីការដាក់ឯកសារសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១១ ឯកសារ D4។ ឧបសម្ព័ន្ធ៖ បញ្ជីឯកសារត្រូវផ្ទេរពីសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១១ ឯកសារ D4.1។

[144] កថាខណ្ឌ ៤៦ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[145] *រឿងក្ដី* កាំង ហ្គេកអ៊ាវ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ដីកាដំណោះស្រាយបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 ("ដីកាដំណោះស្រាយរឿងក្ដី ០០១") កថាខណ្ឌ ៤, ៧។

[146] កថាខណ្ឌ ១២៩ នៃដីកាដំណោះស្រាយរឿងក្ដី ០០១។

[147] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយសំណុំរឿង ០០២") កថាខណ្ឌ ៣, ១៣។

[148] កថាខណ្ឌ ១៣២៧-១៣២៨ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[149] *សូមមើល ឧទា. រឿងក្ដី Armani Da Silva តទល់នឹងចក្រភពអង់គ្លេស* ECtHR បណ្ដឹងលេខ 5878/08 សាលក្រម ចុះថ្ងៃ ទី ៣០ ខែមីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៣៣។

របស់តុលាការអន្តរជាតិនានា"[150]។ ស.ច.ស. ត្រូវតែមានជំនឿជឿជាក់ជានិច្ចកាលថា ពួកគាត់មានយុត្តាធិការ ក្នុងការបន្តកិច្ចដំណើរការនីតិវិធីស៊ើបអង្កេតរបស់ខ្លួន[151] ព្រោះ "ការបន្តកិច្ចដំណើរការនីតិវិធី ដោយមិនមានយុត្តាធិការ នឹងធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអាណត្តិរបស់ អ.វ.ត.ក."[152]។

៣២. ក្នុងការថ្លឹងថ្លែងរវាងលទ្ធផលនៃកិច្ចស៊ើបសួររបស់ខ្លួន ធៀបជាមួយកត្តាដែលពួកគាត់បង្កើតឡើងក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល ស.ច.ស.ជ. និង ស.ច.ស.អ. បានឈានដល់ការសម្រេចថាមាន "ភាពសង្ស័យ" លើថាលោក មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ហើយបាន "ឯកភាពជាឯកច្ឆន្ទ" មិនចោទប្រកាន់គាត់[153]។ ដោយមិនចោទប្រកាន់គាត់ ទើប ស.ច.ស. មិនអាចបញ្ជូនគាត់ទៅជំនុំជម្រះ[154]។ បទដ្ឋានដែល ស.ច.ស. ត្រូវបំពេញ ដើម្បីសម្រេចថា កិច្ចស៊ើបសួរ

---

[150] Thomas Miller *ចៅក្រមសាលាក្តីខ្មែរក្រហមនិយាយអំពីបញ្ហាប្រឈមនៅតុលាការ* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ដែលអាចរកបាននៅតាមគេហទំព័រ៖ https://www.phnompenhpost.com/national/krt-judge-talks-court-controversies ។

[151] កថាខណ្ឌ ៣៤, ៣៧ នៃសាលដីកាលើរឿងក្តី ០០១។ *សូមមើលផងដែរ* Répertoire de droit pénal et de procédure pénale (Dalloz), Frédérique Agostini, Compétence (ខែកុម្ភៈ ឆ្នាំ ២០០៥ ធ្វើបច្ចុប្បន្នភាពខែកុម្ភៈ ឆ្នាំ ២០០៧) កថាខណ្ឌ ២១៣៖ "Comme toute juridiction pénale, le juge d'instruction a le droit mais aussi le devoir, une fois qu'il est saisi, de vérifier sa compétence territoriale, matérielle et personnelle." [ការបកប្រែក្រៅផ្លូវការ "ដូចគ្នានឹងតុលាការព្រហ្មទណ្ឌនានា ចៅក្រមស៊ើបអង្កេត នៅពេលបានទទួល មានសិទ្ធិ និង ភារកិច្ច ដើម្បីស្វែងរកយុត្តាធិការដែនដី យុត្តាធិការលើរឿងក្តី និង យុត្តាធិការបុគ្គលរបស់គាត់"] (ឯកសារភ្ជាប់ ៨)។

[152] កថាខណ្ឌ ៣៤ នៃសាលដីកាលើរឿងក្តី ០០១។

[153] កថាខណ្ឌ ៥៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ ស.ច.ស. មានអំណាច ប៉ុន្តែមិនមានកាតព្វកិច្ចនោះទេ ក្នុងការដាក់ឱ្យស្ថិតក្រោមការពិនិត្យបុគ្គលណាមួយឡើយ។ *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D198/1 កថាខណ្ឌ ១០។

[154] *រឿងក្តី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និង នៅក្នុងស្រុកបាកាន ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៥ -៣៦។ ជាមុនលក្ខខណ្ឌសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស.ច.ស. គ្រាន់តែអាចដាក់ឱ្យស្ថិតក្រោមការពិនិត្យជនសង្ស័យណាមួយ ប្រសិនបើអាចកំណត់បានថា មាន "ភស្តុតាងច្បាស់លាស់ និង ស៊ីសង្វាក់គ្នា" ដែលថា ជននោះអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងវិសាលភាពនៃការស៊ើបអង្កេតរបស់ខ្លួន។ *សូមមើល* វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D198/1 កថាខណ្ឌ ១០។

របស់ពួកគាត់ បានបញ្ចប់ដោយពេញលេញ គឺបណ្ដាសម្ភារឯកសារចាំបាច់ទាំងឡាយ ដែលអនុញ្ញាតឱ្យពួកគាត់អាចសម្រេច *ថាតើត្រូវចេញ ឬ មិនចេញ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[155] មិនមែន "ភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនរឿងទៅជំនុំជម្រះ"[156] ដែលតម្រូវឱ្យ ស.ចៅ.ស. បន្តកិច្ចស៊ើបសួរ *រហូតដល់ពេល* ដែលពួកគាត់អាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។ ដោយសារតែ ស.ចៅ.ស. មិនមានជំនឿជឿជាក់ថាលោក មាស មុត ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ទើប ស.ចៅ.ស. មិនអាចបំពេញកិច្ចស៊ើបសួរបន្ថែមទៀត។ កិច្ចស៊ើបសួរណាមួយដែលធ្វើឡើង ហួសពីយុត្តាធិការរបស់ ស.ចៅ.ស. នឹងត្រូវមោឃភាព និង ក្លាយជាអាសារឥតការ[157]។ ការបន្តបែបនេះ គឺជាការប្រើប្រាស់ដោយមិនសមហេតុផលផងដែរ នូវធនធានរបស់ការិយាល័យរបស់ពួកគាត់ ដែលកំពុងតែស្ថិតក្នុងដំណើរការស៊ើបអង្កេតលើ អ៊ឹម ចែម អោ អាន និង យឹម ទិត្យ នោះ។

---

[155] *សូមមើល* Droit et pratique de l'instruction préparatoire (Dalloz), Christian Guéry and Pierre Chambon, Formalités de fin de procédure (ឆ្នាំ២០១៨-២០១៩) កថាខណ្ឌ ៦១២.១១៖ "La procédure est complète lorsqu'elle réunit les éléments nécessaires pour décider s'il y a lieu de prononcer la mise en prévention de l'inculpé et pour déterminer la juridiction compétente." [ការបកប្រែក្រៅផ្លូវការ៖ "នីតិវិធីគឺបញ្ចប់ពេញលេញ នៅពេលដែលប្រមូលបាននូវសមាសធាតុ ដែលចាំបាច់សម្រាប់សម្រេចថា តើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងជនត្រូវចោទដែរឬយ៉ាងណា ព្រមទាំងកំណត់សមត្ថកិច្ចយុត្តាធិការ"] (ឯកសារភ្ជាប់ ១០)។

[156] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៣៦។

[157] Droit et pratique de l'instruction préparatoire (Dalloz), Christian Guéry and Pierre Chambon, Obstacles à la poursuite de l'instruction (ឆ្នាំ២០១៨-២០១៩) កថាខណ្ឌ ៦១១.១១៖ "Cette vérification s'impose, car la déclaration d'incompétence entraîne l'annulation des actes de l'instruction." [ការបកប្រែក្រៅផ្លូវការ៖ "ការផ្ទៀងផ្ទាត់នេះគឺតម្រូវឲ្យមាន ដោយសារតែការប្រកាសថាមិនមានសមត្ថកិច្ច នាំឲ្យមោឃភាពកិច្ចស៊ើបសួរដែលបានបំពេញ"] (ឯកសារភ្ជាប់ ៩)។ តុលាការកំពូល សភាព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ៩៥-៨២.៣៣៣៖ "L'incompétence du juge est une cause de nullité des actes accomplis en dehors de ses attributions légales et peut être soulevée en tout état de la procédure." [ការបកប្រែក្រៅផ្លូវការ៖ ការមិនមានសមត្ថកិច្ចរបស់ចៅក្រម គឺជាមូលហេតុសម្រាប់មោឃភាពកិច្ចដែលបានសម្រេច ហួសពីសមត្ថកិច្ចផ្លូវច្បាប់របស់គាត់ ហើយបញ្ហានេះអាចលើកឡើង នៅដំណាក់កាលណាមួយក៏បានក្នុងកិច្ចដំណើរការនីតិវិធី"] (ឯកសារភ្ជាប់ ៧)។ តុលាការកំពូល សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ១៩៩៣ ៩៣-៨០.០៧៩៖ "L'exception d'incompétence étant accueillie, la cassation entraine, par voie de conséquence, l'annulation de la procédure." [ការបកប្រែក្រៅផ្លូវការ៖ "ដោយសារតែការជំទាស់ចំពោះសមត្ថកិច្ចរបស់ចៅក្រមត្រូវបានអនុញ្ញាត អង្គជំនុំជម្រះតុលាការកំពូល ជាលទ្ធផល នាំឲ្យមោឃភាពកិច្ចដំណើការនីតិវិធីនោះ"] (ឯកសារភ្ជាប់ ៦)។ *សូមមើលផងដែរ* វិធាន ៧៦ នៃវិធានផ្ទៃក្នុង។

៣៣. ***សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ដែលបានចេញរួមគ្នាដោយ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk គឺជាសេចក្តីជូនដំណឹងស្ថាពរ និង មិនត្រូវបានចាត់ទុកជាមោឃៈ ដោយសារការបើកកិច្ចស៊ើបសួរឡើងវិញរបស់ ស.ច.ស.អ. បម្រុង Kasper-Ansermet ឡើយ*** ដោយហេតុថា ស.ច.ស. មានឋានៈស្មើគ្នា[158] "មានឯករាជ្យភាពចំពោះការស៊ើបអង្កេតរបស់ខ្លួន"[159] និង មានឆន្ទានុសិទ្ធិឯករាជ្យនៅក្នុងការសម្រេចថាត្រូវបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួននៅពេលណា[160] ស.ច.ស.ជ. មិនត្រូវបានតម្រូវឱ្យពិចារណាលើភ័ស្តុតាងដែលបានប្រមូលនៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដើម្បីធ្វើសេចក្តីសម្រេចរបស់ខ្លួនលើយុត្តាធិការបុគ្គល ដោយសារគ្រាន់តែកិច្ចស៊ើបសួរត្រូវបានបើកឡើងវិញ ឬ បន្តដោយ ស.ច.ស.អ. ដែលបានចូលកាន់តំណែងនាពេលក្រោយៗមកនោះឡើយ។ ស.ច.ព. ខកខានមិនបានផ្តល់សំអាងគាំទ្រការអះអាងរបស់ខ្លួនដែលថា សេចក្តីជូនដំណឹងស្តីពីការបិទស៊ើបសួរ "ពិតជាហួសពេលហើយ" នៅពេល ស.ច.ស.អ. បម្រុង Kasper-Ansermet បានបើកកិច្ចស៊ើបសួរឡើងវិញ[161] ហើយត្រូវបានមោឃភាព ដោយសារកិច្ចស៊ើបសួរដែលបានធ្វើឡើងដោយ ស.ច.ស.អ. Harmon និង Bohlander[162]។ បើទោះបីជា ស.ច.ស.ជ. បានពិចារណាលើភ័ស្តុតាងនៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ រួមទាំងភ័ស្តុតាងទាក់ទងនឹងអំពើប្រល័យពូជសាសន៍ក៏ដោយ[163] ក៏ភ័ស្តុតាងទាំងនេះមិនអាចផ្លាស់ប្តូរការសម្រេចរបស់គាត់លើយុត្តាធិការបុគ្គលបាននោះឡើយ (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋាន "ឆ" (កថាខណ្ឌ ៨៩-៩២) *ខាងក្រោម*។

---

[158] មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[159] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៦៣ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[160] វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥។

[161] កថាខណ្ឌ ៣៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[162] កថាខណ្ឌ ៤០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[163] *សូមមើល* កថាខណ្ឌ ៦០-៦២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

៣៤. ស.ព.អ. ទទួលស្គាល់ថា ចាប់តាំងពីពេល "ការបដិសេធត្រូវបានប្ដឹងផ្ដល់ ហើយនីតិវិធីបណ្ដឹងឧទ្ធរណ៍ត្រូវបានបញ្ចប់" ទាក់ទងនឹងសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរ ស.ច.ស.ជ. មានសិទ្ធិចេញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ទៅឱ្យសហព្រះរាជអាជ្ញា សុំឱ្យដាក់សេចក្ដីសន្និដ្ឋានស្ថាពរ[164]។ ក្រោយពេលដែល ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានរួមគ្នាចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ស.ព.អ. មានរយៈពេលចំនួន ១៥ ថ្ងៃ សម្រាប់ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម[165] ដែល ស.ច.ស. ទាំងពីរមានឆន្ទានុសិទ្ធិបដិសេធ[166] ដោយសារ "ការយល់ដឹងរបស់ខ្លួនអំពីការស៊ើបអង្កេត និង សំណុំរឿង"[167]។ ការបដិសេធរបស់ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk ចំពោះសំណើរបស់ ស.ព.អ. សុំឱ្យបំពេញកិច្ចស៊ើបសួរ[168] មានសុពលភាព ហើយសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរបានចូលជាស្ថាពរ បន្ទាប់ពី អ.ប.ជ. បានសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ. នៅថ្ងៃទី ២ និង ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១[169]។ ស.ច.ស.ជ. មិនបានចេញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ "ភ្លាមៗ"[170]

---

[164] *សូមមើល* កថាខណ្ឌ ៣៦ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[165] វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។

[166] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២១។

[167] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៣) សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយរបស់ [កោសលុប] ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៧ ឯកសារ D276/1/1/3 កថាខណ្ឌ ១២, ២២។ *សូមមើលផងដែរ រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២១៖ "*ភាគីនានាអាចស្នើសុំ ប៉ុន្តែមិនមែនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរនោះទេ*"។

[168] ដីកាសម្រេចស្ដីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D20/3។ ដីកាសម្រេចស្ដីអំពីការដាក់សាជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ D26។

[169] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្ដីសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និង សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D20/4/4។ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជ

ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ[171] ពីព្រោះគាត់យល់ឃើញថា ការធ្វើដូច្នេះដោយមិនបានពិភាក្សាអំពីស្ថានភាពនៃការស៊ើបសួរជាមុន ជាមួយនឹង ស.ច.ស.អ. ដែលត្រូវបានតែងតាំងត្រឹមត្រូវ គឺជា "ការប្រញាប់ប្រញាល់បំពេញកិច្ចនាំឱ្យខុសនីតិវិធី"[172]។

៣៥. ខណៈដែលវិធានផ្ទៃក្នុងចែងថា សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅក្នុងករណីខ្លួន "យល់ស្រប [ជាមួយ ស.ច.ស.] ថា ការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយ"[173] ស.ព.អ. មិនត្រូវបានអនុញ្ញាតឱ្យរាំងកិច្ចដំណើរការនីតិវិធី តាមរយៈការមិនព្រមចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននោះឡើយ[174]។ ប្រសិនបើធ្វើដូច្នេះ គាត់អាចនឹងមានចេតនាធ្វើឱ្យជាប់គាំងកិច្ច

---

អាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី" ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ D26/1/3។

[170] ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D52។

[171] វិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង។

[172] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ នៅគេហទំព័រ៖ https://www.eccc.gov.kh/km/articles/17495។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០៖ "**បានឃើញ**ថា នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Harmon បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់ ទាក់ទងនឹងសុពលភាពនៃឯកសារមួយចំនួន ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ០០៣ ចាប់តាំងពីការលាលែងតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk និង ស្ថានភាពបច្ចុប្បន្ននៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣" (អក្សរដិតនៅក្នុងអត្ថបទដើម)។ នៅថ្ងៃដដែលនោះ ស.ច.ស.ជ. បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយពិចារណាថា ការស៊ើបអង្កេតបានបញ្ចប់តាំងពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ មកម្ល៉េះ។ *សូមមើល* ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D52។

[173] វិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង។

[174] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D52/1។ *ប្រៀបធៀប* សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D225 កថាខណ្ឌ ៧ (ដែល ស.ច.ស.អ. Bohlander បានផ្តល់ឱកាសដល់ភាគីទាំងអស់អាចស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមក្នុងរយៈពេល ៣០ ថ្ងៃ)។ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D256 កថាខណ្ឌ ១៤ (ដែលក្នុងនោះ ស.ច.ស.អ. Bohlander បានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ពួកគេមានរយៈពេល បី ខែ ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ)។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D385 ERN 00564268៖ "**ដោយហេតុថា** នៅពេលនេះសហចៅក្រមស៊ើបអង្កេតបានសម្រេចលើរាល់សំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់ដែលស្នើមក បានបំពេញកិច្ចស៊ើបសួរដែលត្រូវបានសម្រេចទទួល

ដំណើរការនីតិវិធីយ៉ាងមានប្រសិទ្ធភាព ដោយបានដកហូតឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស. លើកិច្ចស៊ើបសួរ[175] និង ធ្វើឱ្យបាត់បង់តួនាទីតាមឋានានុក្រមរបស់ អ.ប.ជ. នៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចរបស់ ស.ច.ស.[176]។ ស.ច.ស.ជ. មានឆន្ទានុសិទ្ធិសម្រេចនៅពេលណាត្រូវចេញដីកាដំណោះស្រាយរបស់ខ្លួន[177]។ ដោយពិចារណាលើផលប្រយោជន៍របស់

---

យក បានចេញដីកាបដិសេធចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនត្រូវបានទទួលយក និង ដោយហេតុថា អង្គបុរេជំនុំជម្រះបានសម្រេចលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ដែលត្រូវបានធ្វើ។ **អាស្រ័យហេតុនេះ** សម្រេចបញ្ជូនសំណុំរឿងស៊ើបសួរជូនសហព្រះរាជអាជ្ញានៃ អ.វ.ត.ក. ដើម្បីពិនិត្យ និង ចេញជាដីកាសន្និដ្ឋានស្ថាពរ" (អក្សរដិតក្នុងសំណៅដើម)។

[175] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៦៣។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅនឹង "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/5 កថាខណ្ឌ ១៥។

[176] *សូមមើល* វិធាន ៧៣(ក) នៃវិធានផ្ទៃក្នុង (ចែងថា មានតែ អ.ប.ជ. ប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ស.ច.ស.)។ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង (ចែងថា សេចក្តីសម្រេចរបស់ អ.ប.ជ. ត្រូវបិទផ្លូវតវ៉ា)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ២៧ (ដែលទទួលស្គាល់នូវលក្ខណៈជាកាតព្វកិច្ចនៃសេចក្តីសម្រេចរបស់ អ.ប.ជ. ទៅលើ ស.ច.ស. ត្រូវបានគាំទ្រដោយ "ឋានានុក្រមផ្នែកយុត្តាធិការរបស់ [អ.ប.ជ.] ទៅលើ [ស.ច.ស.] ក្រោមប្រព័ន្ធច្បាប់ អ.វ.ត.ក.")។ នៅពេលដែល ស.ព.អ. ត្រូវបានស្នើសុំឱ្យចេញដីកាសន្និដ្ឋានស្ថាពរ អ.ប.ជ. បានដោះស្រាយបណ្តឹងឧទ្ធរណ៍ទាំងអស់ពាក់ព័ន្ធនឹងការបដិសេធរបស់ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk ទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ ស.ព.អ.។ *សូមមើល* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D20/4/4។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី" ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D26/1/3។

[177] មាត្រា ១៧៥ (VII) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖ "A l'issue, selon les cas, du délai d'un mois ou de trois mois prévu [pour le procureur de la République pour adresser ses réquisitions motivées au juge d'instruction] … le juge d'instruction peut rendre son ordonnance de règlement, y compris s'il n'a pas reçu de réquisitions ou d'observations dans ces délais." [ការបកប្រែក្រៅផ្លូវការ៖ "នៅពេលផុតពេលកំណត់ មួយខែ ឬ បីខែ [សម្រាប់រដ្ឋអាជ្ញាក្នុង

ភាគី[178] ស.ច.ស.ជ. បានរង់ចាំយ៉ាងអត់ធ្មត់ ដើម្បីឱ្យការបើកកិច្ចស៊ើបសួរឡើងវិញនោះបានបញ្ចប់រហូតដល់ពេលដែលគាត់ និង ស.ច.ស.អ. Bohlander បានចេញដីកាដំណោះស្រាយដាច់ដោយឡែកក្នុងពេលដំណាលគ្នា ដោយផ្អែកលើលទ្ធផលនៃកិច្ចស៊ើបសួររបស់គាត់រៀងៗខ្លួន។

៣៦. ស.ព.អ. អះអាងដោយភ័ន្តច្រឡំថា សេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរ "ពិតជាហួសពេលហើយ" ជាមួយនឹងការបើកកិច្ចស៊ើបសួរឡើងវិញ[179]។ ដោយហេតុថា ស.ច.ស. មានឆន្ទានុសិទ្ធិឯករាជ្យនៅក្នុងការសម្រេចថា ពេលណាត្រូវបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួននោះ[180] ការបើកកិច្ចស៊ើបសួរឡើងវិញរបស់ ស.ច.ស.អ. បម្រុង Kasper-Ansermet មិនមានអានុភាពលើការសម្រេចចុងក្រោយនៃសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួររបស់ ស.ច.ស.ជ. នោះទេ ដែលវានៅតែមានសុពលភាពរហូតដរាបណាគាត់មិនបានបំពេញកិច្ចស៊ើបសួរបន្ថែម[181]។ ខណៈដែល ស.ច.ស.អ. បម្រុង Kasper-Ansermet មានសិទ្ធិអនុវត្តអំណាចឆន្ទានុសិទ្ធិដែលមានជាប់មកជាមួយគាត់ ដោយឯកតោភាគី ដើម្បីពិចារណាឡើងវិញលើសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរ ហើយនឹងបើកកិច្ចស៊ើបសួរឡើងវិញ នៅមុនពេលចេញដីកាដំណោះស្រាយក៏ដោយ ក៏ ស.ច.ស.ជ. មានសិទ្ធិដូចគ្នា

---

ការចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនដាក់ជូនចៅក្រមស៊ើបសួរ] ក្នុងករណីដែលអាចអនុវត្តបាន ... ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយរបស់ខ្លួន ទោះបីគាត់មិនបានទទួលដីកាសន្និដ្ឋាន ឬ សេចក្ដីសង្កេតណាមួយក្នុងអំឡុងពេលកំណត់នេះក៏ដោយ"] (ឯកសារភ្ជាប់ ៥)។ *សូមមើលផងដែរ* Droit et pratique de l'instruction préparatoire (Dalloz), Christian Guéry and Pierre Chambon, Formalités de fin de procédure (ឆ្នាំ២០១៨-២០១៩) កថាខណ្ឌ ៦១២.៦១៖ "Le juge d'instruction qui ne reçoit pas de réquisitions dans le délai prescrit (un ou trois mois) peut rendre l'ordonnance de règlement." [ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបសួរដែលមិនបានទទួលដីកាសន្និដ្ឋានណាមួយនៅក្នុងពេលកំណត់ (មួយ ឬបីខែ) អាចចេញដីកាដំណោះស្រាយរបស់ខ្លួនបាន"] (ឯកសារភ្ជាប់ ១០)។

[178] កថាខណ្ឌ ៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[179] កថាខណ្ឌ ៣៨ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[180] វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥។

[181] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D235/2 កថាខណ្ឌ ៩។ *សូមមើល ឧទា.* សេចក្ដីជូនដំណឹងលើកទី ២ ស្ដីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D252។ *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៧ ឯកសារ D334/2 កថាខណ្ឌ ១២-១៦។

នៅក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិដែលមានជាប់មកជាមួយគាត់ *មិនធ្វើការ* ពិចារណាឡើងវិញលើសេចក្ដីជូនដំណឹងនេះបានដូចគ្នា[182]។

៣៧. កិច្ចដែលបំពេញដោយ ស.ច.ស.អ. Harmon និង ស.ច.ស.អ. Bohlander មិន "គ្រប់គ្រាន់ក្នុងការធ្វើឱ្យមោឃភាពសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរ" ដែលបានចេញនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ នោះឡើយ[183]។ ក្រោយការបើកកិច្ចស៊ើបសួរឡើងវិញ ស.ច.ស.អ. ទាំងអស់ ដែលនឹងមកបំពេញការងារនាពេលក្រោយៗ មានឆន្ទានុសិទ្ធិឯករាជ្យធ្វើការស៊ើបសួរដែលខ្លួនយល់ឃើញថាចាំបាច់ក្នុងការបញ្ជាក់ការពិត រហូតដល់ពេលខ្លួនយល់ឃើញថាការស៊ើបអង្កេតមានលក្ខណៈពេញលេញ[184]។ សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ មិនត្រូវបានមោឃភាពនោះទេ ដោយហេតុថាកិច្ចស៊ើបសួរប្រឆាំងនឹងលោក មាស មុត ត្រូវបានបើកឡើងវិញដោយឯកតោភាគី[185] កិច្ចស៊ើបសួរនេះបានបន្តធ្វើឡើង អនុលោមតាមការខ្វែងយោបល់គ្នារវាង ស.ច.ស.ជ. និង ស.ច.ស.អ. Harmon ទាក់ទងនឹងស្ថានភាពនៃកិច្ចស៊ើបសួរ[186] ស.ច.ស.អ. Bohlander បានចេញសេចក្ដីជូនដំណឹងស្ដីពីការបិទស៊ើបសួរ ដោយគូសបញ្ជាក់អំពីការខ្វែងយោបល់គ្នាដែលត្រូវបានចុះបញ្ជីជាមួយនឹង ស.ច.ស.ជ.[187] ហើយ ស.ច.ស.ជ. មិនបានបំពេញកិច្ចស៊ើបសួរបន្ថែម ដែលតម្រូវឱ្យគាត់ចេញសេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរមួយផ្សេងទៀតនោះឡើយ។

៣៨. ស.ព.អ. បាននាំឱ្យយល់ខុស ដោយបានអះអាងថា សេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរត្រូវចាត់ទុកជាមោឃៈ ពីព្រោះលោក មាស មុត មិនដែលបានតវ៉ាថា កិច្ចស៊ើបសួរបានបញ្ចប់នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[188] ហើយ អ.ប.ជ. បានពិចារណាជាឯកច្ឆន្ទលើកំណត់ហេតុនៃការស្តាប់

---

[182] *រឿងក្ដី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) សេចក្ដីសម្រេចលើពាក្យសុំពិចារណាសាជាថ្មី អំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ C22/1/68 កថាខណ្ឌ ២៥។

[183] កថាខណ្ឌ ៤០ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[184] *សូមមើល* កថាខណ្ឌ ២៧, ៣២ *ខាងលើ*។

[185] *សូមមើល* ដីកាសម្រេចស្ដីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D28។

[186] *សូមមើល* សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០។

[187] សេចក្ដីជូនដំណឹងលើកទី ២ ស្ដីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D252។

[188] កថាខណ្ឌ ៤១ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

ចម្លើយចំនួន ១០ដែលបានធ្វើឡើងក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ថា "ត្រូវបានអនុញ្ញាត"[189]។ វាមិនពាក់ព័ន្ធនឹងការគាំទ្រការអះអាងរបស់គាត់ដែលថា ស.ច.ស.ជ. ត្រូវពិចារណាលើភ័ស្តុតាង ដែលប្រមូលបាននៅក្រោយការបើកកិច្ចស៊ើបសួរឡើងវិញនោះទេ។ វាគ្រាន់តែបង្ហាញថា កិច្ចស៊ើបសួរដែលបានបើកឡើងវិញត្រូវបានអនុញ្ញាតឱ្យបន្តកិច្ចដំណើរការនីតិវិធី រហូតដល់ពេល ស.ច.ស.អ. Bohlander បានយល់ឃើញថា កិច្ចស៊ើបសួររបស់គាត់បានបញ្ចប់ពេញលេញ បង្ហាញថា លោក មាស មុត បានអនុវត្តសិទ្ធិទទួលបានជំនុំជម្រះក្តីដោយយុត្តិធម៌ជាមូលដ្ឋានរបស់គាត់ ក្នុងការចូលរួម នៅក្នុងកិច្ចស៊ើបសួរដែលបានបើកឡើងវិញ ហើយនឹងបង្ហាញថា អ.ប.ជ. បានអនុវត្តតួនាទីរបស់ខ្លួន ជាសភាស៊ើបសួរ។

៣៩. *ជារួម* គ្រាន់តែដោយសារកិច្ចស៊ើបសួរត្រូវបានបើកឡើងវិញ ហើយ ស.ច.ស.អ. ក្រោយៗ បាន ប្រមូលសម្ភារឯកសារបន្ថែមទៀត ដែលពួកគាត់យល់ឃើញថាចាំបាច់ក្នុងការបញ្ជាក់ការពិត មិន អាចធ្វើឱ្យកិច្ចស៊ើបសួរដែលបានបិទបញ្ចប់ដោយ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ មានលក្ខណៈមិនពេញលេញ ហើយមោឃភាពសេចក្តីជូនដំណឹងស្តីពីការ បិទកិច្ចស៊ើបសួរដែលពួកគាត់បានចេញរួមគ្នានោះទេ។ ដូចដែលតម្រូវ ស.ច.ស. បានបំពេញកិច្ច ដោយយកចិត្តទុកដាក់ ត្រឹមត្រូវ និង យ៉ាងឆាប់រហ័ស ក្នុងការស៊ើបអង្កេតពិតប្រាកដ និង ប្រកប ដោយប្រសិទ្ធភាព ទៅលើអង្គហេតុដែលខ្លួនទទួលបាន។ ពួកគាត់ប្រមូលផ្តុំសម្ភារឯកសារដែល ចាំបាច់សម្រាប់ពិចារណាថាកិច្ចស៊ើបសួររបស់ពួកគាត់បានបញ្ចប់ពេញលេញ ដោយបានពិនិត្យមើល លើអង្គហេតុ និង បានកំណត់អត្តសញ្ញាណថា លោក មាស មុត មិនអាចទទួលខុសត្រូវចំពោះអង្គ ហេតុទាំងនោះ ដោយសារ អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើគាត់។ ដូច្នេះហើយ ស.ច.ស.ជ. មិនត្រូវបានតម្រូវឱ្យពិចារណាលើភ័ស្តុតាង ដែលប្រមូលបានក្រោយពេលបើកកិច្ចស៊ើបសួរឡើងវិញ ដើម្បីអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវនោះទេ។ ដោយខកខានមិនបានបង្ហាញឱ្យឃើញពី កំហុសអង្គច្បាប់នៅក្នុងសេចក្តីសម្រេចរបស់ ស.ច.ស.ជ. ដែលមិនពិចារណាលើភ័ស្តុតាងក្រោយ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដែលនឹងនាំឱ្យមោឃភាពការសម្រេចរបស់គាត់លើយុត្តាធិការបុគ្គល ឬ សេចក្តីសម្រេចរបស់ ស.ច.ស.ជ. មិនពិចារណាលើភ័ស្តុតាងនេះ មានភាពអយុត្តិធម៌ ឬ មិនសម ហេតុផល នាំឱ្យមានការបំពានឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា តើ

[189] កថាខណ្ឌ ៤២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

ស.ច.ស.ជ. បានប្រព្រឹត្តកំហុសអង្គច្បាប់ ឬ ការបំពានឆន្ទានុសិទ្ធិជាកត្តាកំណត់ជាមូលដ្ឋាន ជារួម ដោយឡែក ដោយរបៀបណា។ គួរច្រានចោល មូលដ្ឋាន "ខ"។

**ខ. ការឆ្លើយតបទៅនឹងមូលដ្ឋាន "គ" (ផ្នែកខ្លះ)៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់នៅពេលពិចារណា និង ចេញសេចក្ដីសម្រេចលើអង្គហេតុទាំងអស់ នៅក្នុងវិសាលភាពនៃរឿងក្ដី ០០៣**

៤០. ស.ព.អ. ទទួលស្គាល់ថា "ព្រឹត្តិការណ៍ទាំងឡាយ" មិនមានន័យដូចគ្នានឹង "ទីតាំងឧក្រិដ្ឋកម្ម" នោះទេ[190] ប៉ុន្តែ បានសំយោគន័យដោយភ័ន្តភាំង តាមរយៈការអះអាងថា ស.ច.ស.ជ. គួរចេញសេចក្ដីសម្រេចលើ *ទីតាំងឧក្រិដ្ឋកម្ម* នីមួយៗ ដែលបង្កើតជាផ្នែកនៃ *អង្គហេតុ* ដែលខ្លួនទទួលបាន បន្ថែមទៅលើអង្គហេតុផ្ទាល់ ដើម្បីសម្រេចលើយុត្តាធិការបុគ្គល[191]។ ស.ច.ស.ជ. បានពិចារណា និង ចេញសេចក្ដីសម្រេចយ៉ាងត្រឹមត្រូវ លើអង្គហេតុទាំងអស់ដែលខ្លួនទទួលបាន។ គាត់មិនត្រូវបានតម្រូវឱ្យធ្វើការសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលបង្កើតបានជាផ្នែកនៃអង្គហេតុនោះទេ ដរាបណាគាត់បានពិចារណាវា នៅពេលសម្រេចលើអង្គហេតុដែលខ្លួនទទួលបាន។ ទឡ្ហីករណ៍ផ្សេងទៀតនៅក្នុងមូលដ្ឋាន "គ" របស់ ស.ព.អ. ដែលលើកឡើងពីកំហុសនៅក្នុងសេចក្ដីសម្រេចរបស់ ស.ច.ស.ជ. ថាមិនបានកំណត់ប្រភេទបទចោទតាមច្បាប់ នៅពេលសម្រេចលើយុត្តាធិការបុគ្គល[192] នឹងលើកយកមកបង្ហាញនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋាន "ក" ដើម្បីជៀសវាងភាពច្រំដែល[193] ពីព្រោះវាជាន់គ្នានឹងទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងមូលដ្ឋាន "ក"[194]។

៤១. ដោយទទួលស្គាល់ថា ទឹកសាប ចំការធូរេន បិតត្រាំង កងកេង *មន្ទីរណែនាំ* និង ការដ្ឋាន និង ទីតាំងសម្លាប់ផ្សេងទៀតនៅរាម បង្កើតបានជាផ្នែកនៃអង្គហេតុដែល ស.ច.ស. ទទួលបាន[195] ស.ព.អ.

---

[190] កថាខណ្ឌ ៦៤ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[191] កថាខណ្ឌ ៦៣-៦៩ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[192] *សូមមើល* កថាខណ្ឌ ៧០-៨២ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[193] *សូមមើល* កថាខណ្ឌ ៤៥-៥៤ *ខាងក្រោម*។

[194] *សូមមើល* កថាខណ្ឌ ២៣-៣៤ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[195] កថាខណ្ឌ ៦៥-៦៩ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។ ជាពិសេស៖ ទឹកសាបគឺជា "ផ្នែកដ៏សំខាន់" នៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៦៦)។ ចម្ការធូរេន ក៏ស្ថិត "ក្នុងអង្គហេតុដូចគ្នាទាំងនេះដែរ" (កថាខណ្ឌ ៦៦)។ ការដ្ឋានតំបន់រាម និង ទីតាំងសម្លាប់មនុស្សនានា ក៏ "មានទំនាក់ទំនងមិនបានបំបែកបាន" ទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៦៧)។ មាន "ទំនាក់ទំនងច្បាស់

យល់ស្របថា ទីតាំងឧក្រិដ្ឋកម្មគឺត្រឹមជាអង្គហេតុប្រយោលនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតែប៉ុណ្ណោះ[196]។ ចំណុចនេះស៊ីសង្វាក់ជាមួយនឹងទស្សនៈរបស់ចៅក្រមអន្តរជាតិ អ.ប.ជ. ដែលថា ទីតាំងឧក្រិដ្ឋកម្ម ដែលមិន "ត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[197] មិនមែនជាអង្គហេតុថ្មីនោះទេ[198] ប្រសិនបើវាផ្សាភ្ជាប់ជាមួយនឹងអង្គហេតុដែលបានដាក់បញ្ចូលទៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួររួចហើយនោះ[199]។

៤២. ស.ព.អ. អានដីកាសម្រេចលើកលែងចោទប្រកាន់ខុស ដោយអះអាងថា ស.ច.ស.ជ. ខកខានមិនបានពិចារណាលើទីតាំងឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍បទល្មើស នៅពេលធ្វើការសម្រេចលើអង្គហេតុ[200]។ ស.ច.ស.ជ. ត្រូវចេញសេចក្តីសម្រេចមួយ "លើអង្គហេតុទាំងអស់ ប៉ុន្តែអង្គហេតុទាំងអស់នោះគឺជាផ្នែកមួយនៃកិច្ចស៊ើបសួររបស់ខ្លួន"[201]។ បំពេញកិច្ចដោយយកចិត្តទុកដាក់ ស.ច.ស.ជ.

---

លាស់" មួយរវាងទឹកសាប និងការបោសសម្អាតក្នុងកងពលនៃ ក.ប.ក. (កថាខណ្ឌ ៦៦)។ កងកេង និង បិតត្រាំង "កំស្ថិតក្នុង" ការបោសសម្អាតក្នុងកងពលនៃ ក.ប.ក. (កថាខណ្ឌ ៦៧) ចម្ការធូរេន និង បន្ទាយសេរ៉ី "មានទំនាក់ទំនងមិនបានផ្តាច់បាន" ទៅនឹងការបោសសម្អាតក្នុងកងពលនៃ ក.ប.ក. (កថាខណ្ឌ ៦៧)។

[196] *សូមមើល* កថាខណ្ឌ ៦៤ ជើងទំព័រ ២៣៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (ជើងទំព័រត្រូវបានលុបចោល)។

[197] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 (យោបល់របស់ចៅក្រម Beauvallet និង ចៅក្រម Bwana) កថាខណ្ឌ ១៩។

[198] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 (យោបល់របស់ចៅក្រម Beauvallet និង ចៅក្រម Bwana) កថាខណ្ឌ ៥៥-៥៦។

[199] *សូមមើល ឧទា.* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 (យោបល់របស់ចៅក្រម Beauvallet និង ចៅក្រម Bwana) កថាខណ្ឌ ៣៣, ៤៦។

[200] កថាខណ្ឌ ៦៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[201] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៣៧។ *សូមមើល ផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-

បានរៀបរាប់គ្រប់អង្គហេតុទាំងអស់ដែលខ្លួនបានទទួល[202] បានសម្រេចលើអង្គហេតុទាំងនេះ[203] និងបានដកស្រង់ភ័ស្តុតាងទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងអស់ ដែលជាផ្នែកនៃអង្គហេតុ[204]។ នៅក្នុងបរិបទដែលមានការស៊ើបអង្កេតទំហំធំដូចនៅ អ.វ.ត.ក. វាមិនអាចអនុវត្តបានឡើយ ក្នុងការឱ្យ ស.ច.ស. ធ្វើការសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកនៃអង្គហេតុ ដែលខ្លួនទទួលបានតាមរយៈ "ខ្លឹមសារនៃឧបសម្ព័ន្ធរាប់រយ" ដាក់ភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូច ដែល ស.ព.អ. អះអាងថា ស.ច.ស.ជ. គួរធ្វើនោះ[205]។

៤៣. បើទោះបីជា អ.ប.ជ. ត្រូវសម្រេចថា ស.ច.ស.ជ. ត្រូវធ្វើការសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗក៏ដោយ ក៏ អ.ប.ជ. គ្មានធនធានចាំបាច់ឯណា សម្រាប់ពិនិត្យមើលឡើងវិញលើខ្លឹមសារនៃ

---

២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D198/1 កថាខណ្ឌ ១០។

[202] កថាខណ្ឌ ៥៤ ជើងទំព័រ ៦៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[203] *សូមមើល* កថាខណ្ឌ ៥៥-៣៥៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើល ផងដែរ* កថាខណ្ឌ ២៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[204] *សូមមើល ឧទា.* ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ ៥២៦, ៥៤៧-៤៨, ៥៥១, ៥៥២, ៥៦២, ៥៦៥, ៦១៤ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6 (ចម្ការធូរេន)), ជើងទំព័រ ៥៧០, ៦៤៦-៤៧, ៨២៨, ៨៩១, ៨៩៣-៩៥, ៨៩៧, ៨៩៩, ៩០០-០១, ៩០៤, ៩០៨, ៩០៩, ៩១២-១៣ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 (ចម្ការធូរេន)), ជើងទំព័រ ៥៦៨, ៥៨៦, ៦១៨, ៦១២ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/16 (ចម្ការធូរេន)), ជើងទំព័រ ១៩២ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ ឯកសារ D4.1.477 (ទឹកសាប)), ជើងទំព័រ ៥៩៥, ៨៩៨ (ដែលដកស្រង់កំណត់ហេតុនៃកិច្ចសម្ភាសន៍ ប៉ែន សារិន ដោយការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.8 (ទឹកសាប)), ជើងទំព័រ ៥០៤, ៦៦២, ៦៩៣, ៧០០, ៨១៧-១៨ (ដែលដកស្រង់របាយការណ៍ចំណងជើង "ជម្រាបបង ៨៩ គោរពជ្រាប" ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.3 (ទឹកសាប)), ជើងទំព័រ ៦២៣-២៤, ៦២៧-២៨, ៦៣២-៣៥, ៦៣៨-៤០, ៦៤២, ៦៨២, ៨២៥, ៨២៧, ៩៣១, ៩៥៤-៥៨, ៩៦២ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/10 (ការដ្ឋានតំបន់រាម), ជើងទំព័រ ៥៥០, ៥៦៥, ៥៦៧, ៥៧០, ៥៨៣-៨៤, ៥៨៦, ៥៩០, ៥៩២-៩៣, ៦១២, ៦១៦-១៧, ៦១៩, ៦២៣, ៦២៥-២៦, ៦២៩-៣០, ៦៣៦, ៦៤១, ៧២២, ៩៣៩, ៩៥៤, ៩៦៣, ៩៦៧ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/9 (ការដ្ឋានតំបន់រាម)), ជើងទំព័រ ១២៨, ២៦០ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វ ឌុន ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៩ ឯកសារ D4.1.795 (ការដ្ឋានតំបន់រាម))។

[205] កថាខណ្ឌ ៦៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

សំណុំរឿង ហើយធ្វើការសម្រេចលើវានោះដែរ ពីព្រោះ អ.ប.ជ. មិនត្រូវបាន "បង្កើតឡើង" ឬ "រៀបចំដើម្បីដឹកនាំការស៊ើបអង្កេត" នៅក្នុងបរិបទនៃរឿងក្តី អ.វ.ត.ក. ដែលមានលក្ខណៈពិសេសបែបនេះឡើយ[206]។ កិច្ចដែលសមស្របបំផុត គឺត្រូវបញ្ជូនសំណុំរឿងទៅឱ្យ ស.ច.ស.ជ. វិញ ដើម្បីឱ្យគាត់ធ្វើការសម្រេចលើអង្គហេតុដែលតម្រូវឱ្យមាន[207] ដោយសារគាត់បានដឹងអំពីកិច្ចស៊ើបសួរ។

៤៤. *ជារួម* ដីកាសម្រេចលើកលែងចោទប្រកាន់ មិនមាន "វិការៈផ្នែកអង្គច្បាប់"[208] ដោយសារ ស.ច.ស.ជ. មិនបានសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលបង្កើតជាផ្នែកនៃអង្គហេតុដែលគាត់ទទួលបានឡើយ។ ដោយដកស្រង់ភ័ស្តុតាងទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងការសម្រេចលើអង្គហេតុរបស់គាត់ ស.ច.ស.ជ. ប្រាកដជាបានពិចារណាលើវា[209] នៅពេលសម្រេចថា អ.វ.ត.ក. គ្មានយុត្តាធិការបុគ្គលលើលោក មាស មុត។ ដោយខកខានមិនបានបង្ហាញឱ្យឃើញកំហុសអង្គច្បាប់នៅក្នុងការពិចារណារបស់ ស.ច.ស.ជ. លើអង្គហេតុដែលខ្លួនទទួលបាន ដែលនឹងនាំឱ្យមោឃភាពការសម្រេចលើយុត្តាធិការបុគ្គល ឬ សេចក្តីសម្រេចរបស់ ស.ច.ស.ជ. មិនធ្វើការសម្រេចជាក់លាក់

---

206 *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។

207 *សូមមើល* Droit et pratique de l'instruction préparatoire (Dalloz), Christian Guéry and Pierre Chambon, Ordonnances de règlement (ឆ្នាំ២០១៨-២០១៩) កថាខណ្ឌ ៦១៤.២២៖ "... Le juge d'instruction, dessaisi par son ordonnance de règlement de la procédure, ne saurait poursuivre son information sur les faits qu'il aurait omis de viser dans cette ordonnance, à moins d'en être saisi à nouveau régulièrement. En un tel cas, la chambre d'accusation statuant sur l'appel de cette ordonnance, après avoir annulé celle-ci doit procéder dans les conditions prévues par l'article 206 du Code de procédure pénale, et peut donc renvoyer le dossier au même juge d'instruction, afin de poursuivre l'information sur les faits omis par l'ordonnance de règlement." [ការបកប្រែក្រៅផ្លូវការ៖ "... ចៅក្រមស៊ើបសួរ *លែងមានភារកិច្ចទៀតហើយ* (functus officio) នៅពេលចេញដីកាដំណោះស្រាយរបស់ខ្លួន មិនអាចបន្តស៊ើបអង្កេតទៅលើអង្គហេតុនានាដែលគាត់បានលុបចេញពីដីកាដំណោះស្រាយរបស់ខ្លួនបានទេ លុះត្រាតែគាត់ទទួលយកអង្គហេតុនោះមកពិនិត្យដោយមានសុពលភាពម្តងទៀត។ ក្នុងករណីនេះ សភាស៊ើបសួរដែលសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បន្ទាប់ពីមោឃភាពដីកាដំណោះស្រាយហើយនោះ ត្រូវដំណើរការអនុលោមតាមមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយហេតុនេះ អាចបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរដដែល ដើម្បីឱ្យបន្តការស៊ើបសួរលើអង្គហេតុដែលបានលុបចោលនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន"] (ឯកសារភ្ជាប់ ១១)។

208 *ផ្ទុយពី* កថាខណ្ឌ ៦៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

209 *សូមមើល* កថាខណ្ឌ ៣០៤ នៃសាលដីកាលើរឿងក្តី ០០២/០១។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kvočka និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-98-30/1-A សាលដីកា ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលដីកាចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៤១។

លើទីតាំងឧក្រិដ្ឋកម្ម ដែលបង្កើតជាផ្នែកនៃអង្គហេតុ មានភាពអយុត្តិធម៌ ឬ មិនសមហេតុផល បង្កើតជាការបំពានឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថាតើ ស.ច.ស.ជ. បានប្រព្រឹត្តកំហុសអង្គច្បាប់ ឬ ការបំពានឆន្ទានុសិទ្ធិជាកត្តាកំណត់ជាមូលដ្ឋាន ជារួម ឬ ដោយឡែកដោយរបៀបណា។ គួរច្រានចោល ផ្នែកនេះនៃមូលដ្ឋាន "គ"។

**គ. ចម្លើយតបទៅនឹងមូលដ្ឋាន "ក" និង "គ" (មួយផ្នែក)៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់នៅក្នុងការផ្តល់សំអាងហេតុលើដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសារការខកខានមិនបានធ្វើសេចក្តីសម្រេចដែលតម្រូវឱ្យមាន និង មិនបានកំណត់ប្រភេទបទចោទតាមច្បាប់**

៤៥. ស.ព.អ. អះអាងដោយភ័ន្តច្រឡំថា ស.ច.ស.ជ. មិនអាចសម្រេចលើយុត្តាធិការបុគ្គលបាន ដោយមិនកំណត់ប្រភេទបទចោទតាមច្បាប់ជាបឋម ចំពោះការសម្រេចលើអង្គហេតុដែលគាត់បានធ្វើឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និង ចំពោះការសម្រេចលើអង្គហេតុ ដែល ស.ព.អ. ចោទប្រកាន់ថា ស.ច.ស.ជ. ខកខានមិនបានធ្វើ[210]។ ក្រោយពីបានធ្វើការសម្រេចដែលតម្រូវឱ្យមានលើយុត្តាធិការបុគ្គល ដើម្បីឈានទៅរកការសម្រេចលើយុត្តាធិការបុគ្គល និង សម្រាប់ឱ្យ អ.ប.ជ. ពិនិត្យមើលលើការសម្រេចនេះបាន ស.ច.ស.ជ. មិនត្រូវបានតម្រូវឱ្យកំណត់ប្រភេទបទចោទ និង ទម្រង់នៃការទទួលខុសត្រូវ តាមច្បាប់នោះទេ។ បើទោះបីជា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ដូចដែល ស.ព.អ. អះអាងក៏ដោយ ក៏វាមិនមែនជាកត្តាកំណត់ជាមូលដ្ឋាននៃការសម្រេចរបស់គាត់លើយុត្តា ធិការបុគ្គលនោះដែរ (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋាន "ឆ" (កថាខណ្ឌ ៨៩-៩២) *ខាងក្រោម*)។

៤៦. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ទាល់តែអង្គហេតុត្រូវបានកំណត់តាមច្បាប់រួចហើយ ទើប ស.ច.ស.ជ. អាចសម្រេចថា តើលោក មាស មុត ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬយ៉ាងណា[211]។ គាត់បកស្រាយខុសលើការសម្រេចរបស់ អ.ប.ជ. ដែលថា ដើម្បីពិនិត្យមើលការសម្រេចលើយុត្តាធិការបុគ្គលបាន អ.ប.ជ. "ប្រាកដជាត្រូវអាចពិនិត្យមើល សេចក្តី

---

[210] កថាខណ្ឌ ២០-៣៤, ៧០-៨២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[211] កថាខណ្ឌ ២៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

សន្និដ្ឋាននានា ដែលនាំឱ្យមានការសម្រេចបែបនេះ រួមទាំង សេចក្តីសន្និដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬ ភរិយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ [ជនសង្ស័យ]"[212]។

៤៧. អ.ប.ជ. មិនដែលបានសម្រេចថា ការកំណត់ប្រភេទបទចោទតាមច្បាប់ គឺជាបុរេលក្ខខណ្ឌសម្រាប់ការសម្រេចលើយុត្តាធិការបុគ្គលនោះទេ។ ផ្ទុយមកវិញ អ.ប.ជ. បានទទូចអំពីលក្ខខណ្ឌតម្រូវដែលថា ការសម្រេចដែលបានធ្វើឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ជួយ អ.ប.ជ. ក្នុងការពិនិត្យមើលឡើងវិញលើការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.[213]។ និយាយម្យ៉ាងទៀត អ.ប.ជ. ទាមទារថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវមានហេតុផល ដូចដែលចែងនៅក្នុងវិធានផ្ទៃក្នុង[214]។ ប្រសិនបើ អ.ប.ជ. មានបំណងចង់ឱ្យដីកាសម្រេចលើកលែងចោទប្រកាន់ កំណត់ប្រភេទបទចោទ និង ទម្រង់នៃការទទួលខុសត្រូវ ហើយចាត់ទុកវាជាបុរេលក្ខខណ្ឌចំពោះការកំណត់យុត្តាធិការបុគ្គលមែននោះ អ.ប.ជ. ប្រាកដជាប្រើប្រាស់ពាក្យពេចន៍នេះជាក់លាក់ហើយ ហើយអាចនឹងដកស្រង់ឯកសារសំអាងផ្លូវច្បាប់ទៀតផង[215]។

៤៨. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ការកំណត់ប្រភេទបទចោទ ចាំបាច់ត្រូវធ្វើឡើងដោយសារ "ឧក្រិដ្ឋកម្មជាក់លាក់មានសារៈសំខាន់ចំពោះការវាយតម្លៃពីភាពធ្ងន់ធ្ងរ"[216]។ គ្មាន "ឋានានុក្រមជាប់មកជាមួយ... ក្នុងចំណោមឧក្រិដ្ឋកម្ម"[217] ដែលត្រូវបានរៀបរាប់នៅក្នុងច្បាប់ស្តីពី

---

[212] កថាខណ្ឌ ២០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ២៦ នៃសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១ (សម្រេចជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* កថាខណ្ឌ ១៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[213] កថាខណ្ឌ ២៦ នៃសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១ (សម្រេចជាឯកច្ឆ័ន្ទ)។

[214] វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។

[215] *សូមមើល* កថាខណ្ឌ ២៦ នៃសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១ (សម្រេចជាឯកច្ឆ័ន្ទ)។

[216] *សូមមើល* កថាខណ្ឌ ២៣-២៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[217] សាលាក្តី ICTY និង អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានសម្រេចម្តងហើយម្តងទៀតថា "ពុំមានឋានានុក្រមដែលភ្ជាប់មកជាមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលសាលាក្តីមានយុត្តាធិការ" ពោលគឺ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A និង សំណុំរឿងលេខ IT-94-1-A*bis* សាលដីកានៅក្នុងបណ្តឹងសាទុក្ខការផ្តន្ទាទោស ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23 និង សំណុំរឿងលេខ IT-96-23/1-A សាលដីកា ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១៧១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-A សាលដីកា ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៧៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Rutaganda* សំណុំរឿងលេខ ICTR-96-3-A សាលដីកា ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៩០។ *រឿងក្តី*

ការបង្កើត អ.វ.ត.ក. និង កិច្ចព្រមព្រៀងឡើយ។ ទាំងអស់នេះ គឺជា "ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់..."[218]។ ទោះបីជា ស.ច.ស. បានកំណត់ប្រភេទបទចោទតាមច្បាប់ចំពោះអង្គហេតុ ដែល អ៊ឹម ចែម ត្រូវបានចោទប្រកាន់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួនក៏ដោយ[219] ក៏ករណីនេះមិនមែនជាកត្តាកំណត់ជាមូលដ្ឋាននៃអំណាចឆន្ទានុសិទ្ធិរបស់ពួកគេ នៅក្នុងការសម្រេចថា អ៊ឹម ចែម មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះដែរ[220]។ កត្តាជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់ ស.ច.ស. គឺកត្តាផ្សេងៗទៀត ដូចជាតួនាទីទាបរបស់ អ៊ឹម ចែម នៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.")[221] ការចូលរួមមានកម្រិតក្នុងសហឧក្រិដ្ឋកម្មរួមដូចបានចោទប្រកាន់[222] និង ភាពធ្ងន់ធ្ងរនៃអំពើរបស់គាត់ បើប្រៀបធៀបជាមួយនឹងភាពធ្ងន់ធ្ងរនៃអំពើឃោរឃៅ ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[223]។

៤៩. ការបង្ហាញតែមួយគត់របស់ ស.ព.អ. ដើម្បីគាំទ្រការអះអាងរបស់គាត់គឺ ស.ច.ស.ជ. បានខកខានមិនបានចេញ "ទស្សនៈដែលមានសំអាងហេតុ" ទៅលើអង្គហេតុទាំងអស់ដែលគាត់បានទទួលពោលគឺវត្តឥន្ទញាណ គឺជាការបោកប្រាស់[224]។ ស.ច.ស.ជ. បានរកឃើញថា ទីតាំងនោះត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខ[225] ទីតាំងនោះអាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងវរសេនាតូចនៃកងពលធំ ១៦៤[226] សាក្សីនិយាយអំពីការចាប់ខ្លួន ការឃុំខ្លួន និង ការកាប់សម្លាប់[227] ក៏ប៉ុន្តែគ្មាន

---

*រដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សំណុំរឿងលេខ ICTR-95-1-A សាលដីកា (សំអាងហេតុ) ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៣៦៧។

[218] មាត្រា ១ នៃកិច្ចព្រមព្រៀង។ មាត្រា ១, ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[219] កថាខណ្ឌ ២៨១-៣០៥ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[220] *សូមមើល* កថាខណ្ឌ ៣០៦-២៥ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[221] កថាខណ្ឌ ៣១៦ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[222] កថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[223] កថាខណ្ឌ ៣១៧-១៨ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[224] កថាខណ្ឌ ២១-២២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[225] កថាខណ្ឌ ២៩២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[226] កថាខណ្ឌ ២៩៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[227] កថាខណ្ឌ ២៩៤-៩៥ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

ភ័ស្តុតាងបង្ហាញថា សាកសពចំនួន ២០០ ដែលត្រូវបានគាស់ចេញនៅក្រោយបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យនៅជិតទីតាំងនោះ គឺជាសាកសពជនរងគ្រោះដែលត្រូវបានសម្លាប់នៅវត្តឥន្ទញាណនោះឡើយ[228] ហើយគ្មានឯកសារបង្ហាញថា មានវត្តមានរបស់លោក មាស មុត នៅក្នុងអំឡុងពេលចាប់ខ្លួន ឬ ការពិនិត្យការដ្ឋាននោះទេ[229]។ ការរកឃើញទាំងនេះ គឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការរកឃើញរបស់ ស.ច.ស.អ.[230] ហើយអាចឱ្យ អ.ប.ជ. ពិនិត្យមើលឡើងវិញលើការសម្រេចអំពីយុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ. បាន។

៥០. ស.ព.អ. អះអាងដោយផ្ដាំផ្ដងថា ដោយសារ ស.ច.ស.ជ. មិនសំដៅជាក់លាក់លើវត្តឥន្ទញាណនៅក្នុងផ្នែកស្ដីពី "សំអាងហេតុ និង សេចក្ដីសន្និដ្ឋាន" នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ "ដោយសារតែមិនអាចដឹងពីមូលដ្ឋាន ដែលដីកាសម្រេចលើកលែងចោទប្រកាន់មានក្នុងការធ្វើសេចក្ដីសន្និដ្ឋានដូច្នេះ"[231]។ ផ្នែកស្ដីពី "សំអាងហេតុ និង សេចក្ដីសន្និដ្ឋាន" គ្រាន់តែសង្ខេបដីកាសម្រេចលើកលែងចោទប្រកាន់តែប៉ុណ្ណោះ ផ្នែកនេះមិនមែនជាមូលដ្ឋានតែមួយសម្រាប់ ស.ច.ស.ជ. សម្រេចលើយុត្តាធិការបុគ្គលនោះឡើយ។ វាជាការមិនចាំបាច់ដែល ស.ច.ស.ជ. និយាយជាក់លាក់អំពីវត្តឥន្ទញាណនៅក្នុងផ្នែកនេះ ដោយសារវានឹងគ្រាន់ជាការនិយាយច្រំដែលពីការសម្រេចរបស់ខ្លួនថា ភ័ស្តុតាងទាំងនោះមិនបញ្ជាក់ថា ជនរងគ្រោះត្រូវបានសម្លាប់នៅទីតាំងនោះ និង ថាគ្មានភ័ស្តុតាងបង្ហាញអំពីវត្តមានរបស់លោក មាស មុត នៅទីតាំងនោះ។

៥១. ស.ព.អ. ទទួលស្គាល់ថា ស.ច.ស.ជ. បានសម្រេចនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន ទោះបីជាបានរៀបរាប់ការកឃើញចោះៗ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ[232] គោលនយោបាយបោសសម្អាតខ្មាំងផ្ទៃក្នុង និង ការពាក់ព័ន្ធរបស់ លោក មាស មុត ជាមួយនឹងការបង្កើត និង ការអនុវត្តគោលនយោបាយ

---

[228] កថាខណ្ឌ ២៩៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[229] កថាខណ្ឌ ២៩៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[230] កថាខណ្ឌ ៤២៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (វត្តឥន្ទញាណស្ថិតក្រោមការគ្រប់គ្រងរបស់កងវរសេនាតូចមួយនៃកងពល ១៦៤ តែមិនមានភស្តុតាងច្បាស់លាស់ដែលបង្ហាញថា មាស មុត ទទួលខុសត្រូវទីតាំងនោះទេ) កថាខណ្ឌ ៤៣០-៣៤ (វត្តឥន្ទញាណត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង) កថាខណ្ឌ ៤៣៥-៣៦ (មិនមានភស្តុតាងស្របគ្នាស្ដីពីការសួរចម្លើយនៅទីតាំងនោះទេ) កថាខណ្ឌ ៤៤៣ (មិនមានភស្តុតាងដែលអាចគួរជឿបានថា លោក មាស មុត បានធ្វើទស្សនកិច្ចនៅទីតាំងនោះទេ)។

[231] កថាខណ្ឌ ២២ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[232] កថាខណ្ឌ ២៨ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

នេះ[233] និង គោលនយោបាយបង្កើត និង ដំណើរការសហករណ៍ ព្រមទាំងការដ្ឋានការងារដោយបង្ខំ និង ការចូលរួមពាក់ព័ន្ធរបស់លោក មាស មុត នៅក្នុងការអនុវត្ត[234]។ ការរកឃើញទាំងនេះមិនមែនត្រឹមតែអនុញ្ញាតឱ្យ អ.ប.ជ. អាចពិនិត្យមើលការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ. បានប៉ុណ្ណោះទេ ប្រសិនបើ អ.ប.ជ. មានភាពចាំបាច់ក្នុងការកំណត់ប្រភេទបទចោទតាមច្បាប់ អ.ប.ជ. គឺអាចធ្វើទៅបាន ដោយសារ ស.ព.អ. បានយល់ឃើញថា មានភាពជាក់លាក់គ្រប់គ្រាន់ ដោយបានស្នើកំណត់ប្រភេទបទចោទដោយខ្លួនឯង[235]។

៥២. ស.ព.អ. គ្រាន់តែឆ្លៀតឱកាសលើកឡើងពីការកំណត់ប្រភេទបទចោទបន្ថែម តាមរយៈការនិយាយបញ្ជាក់សាជាថ្មីនូវទឡ្ហីករណ៍ដកស្រង់ពីដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនតែប៉ុណ្ណោះ[236] ដើម្បីគាំទ្រការអះអាងខុសដែលថា ស.ច.ស.ជ. បានខកខានមិនបានពិចារណាលើទីតាំងឧក្រិដ្ឋកម្មដែលបង្កើតជាផ្នែកនៃអង្គហេតុដែលគាត់បានទទួល នៅក្នុងពេលធ្វើការសម្រេចលើអង្គហេតុ (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋាន "គ" (កថាខណ្ឌ ៤០-៤៤) *ខាងលើ*)។ ស.ព.អ. ខកខានមិនបានពន្យល់ថាហេតុអ្វីបានជាគាត់ដកស្រង់ពីដីកាសន្និដ្ឋានស្ថាពររបស់គាត់ ជាជាងការសម្រេចរបស់ ស.ច.ស.អ. ទៅវិញ ដោយសារគាត់មិនបានប្ដឹងឧទ្ធរណ៍ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយស្នើសុំឱ្យបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ "ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[237]។

៥៣. បើទោះបីជា អ.ប.ជ. ចាំបាច់ត្រូវពិចារណាថា ស.ច.ស.ជ. គួរកំណត់ប្រភេទបទចោទ និង ទម្រង់នៃការទទួលខុសត្រូវតាមច្បាប់ នៅមុនពេលសម្រេចលើយុត្តាធិការបុគ្គលក៏ដោយ ក៏ ស.ច.ស.ជ. មិនប្រាកដថាអាចធ្វើដូច្នេះដែរ។ នៅក្នុងដីកាដំណោះស្រាយ ស.ច.ស. អាចកំណត់ប្រភេទបទចោទតាមច្បាប់ប្រឆាំងនឹង *ជនត្រូវចោទ* ក្នុងគោលបំណងនៃការសម្រេចថា តើលក្ខខណ្ឌអប្បបរមាសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានបំពេញដែរឬយ៉ាងណា[238]។ ស.ច.ស.ជ. និង ស.ច.ស.អ.

---

[233] កថាខណ្ឌ ២៩-៣០ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[234] កថាខណ្ឌ ៣១ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[235] កថាខណ្ឌ ៣៣ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[236] កថាខណ្ឌ ៧១-៨២ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[237] កថាខណ្ឌ ៣, ២០៣ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[238] *សូមមើល* វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង (ចែងថា ស.ច.ស. "ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថា ត្រូវ ... បញ្ជូន *ជនត្រូវចោទ* ទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់") (ការគូសបញ្ជាក់បន្ថែម)។ វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង (តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ "ត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃ*ជនជាប់ចោទ*" ... និង កំណត់ប្រភេទបទល្មើស និង ប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ) (ការគូសបញ្ជាក់បន្ថែម)។ វិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុង (ចែងថា

Blunk មិនបានចោទប្រកាន់លោក មាស មុត ទាក់ទងនឹងអង្គហេតុណាមួយឡើយ នៅមុនពេលបិទការស៊ើបអង្កេតរួមគ្នានៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[239] សេចក្ដីជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួររបស់ពួកគាត់ មិនត្រូវបានចាត់ទុកជាមោឃៈ[240] ហើយ ស.ច.ស.ជ. មិនបានចោទប្រកាន់លោក មាស មុត ជាមួយ ស.ច.ស.អ. Harmon[241] ឬ ស.ច.ស.អ. Bohlander នោះឡើយ[242]។

៥៤. *ជារួម* ស.ច.ស.ជ. មិនត្រូវបានតម្រូវឱ្យកំណត់ប្រភេទបទចោទ និង ទម្រង់នៃការទទួលខុសត្រូវតាមច្បាប់ ដើម្បីធ្វើការសម្រេចលើយុត្តាធិការបុគ្គលនោះទេ។ ក្រោយពេលសម្រេចទៅតាមការតម្រូវឱ្យមាន លើអង្គហេតុទាំងអស់ដែលខ្លួនបានទទួល ដីកាសម្រេចលើកលែងការចោទប្រកាន់បានផ្ដល់ហេតុផលគ្រប់គ្រាន់សម្រាប់ឱ្យ អ.ប.ជ. ពិនិត្យឡើងវិញលើការសម្រេចរបស់ ស.ច.ស.ជ. ថា អ.វ.ត.ក. គ្មានយុត្តាធិការបុគ្គលលើលោក មាស មុត។ ដោយខកខានមិនបានបង្ហាញឱ្យឃើញកំហុសអង្គច្បាប់នៅក្នុងសេចក្ដីសម្រេចរបស់ ស.ច.ស.ជ. ដែលមិនកំណត់ប្រភេទបទចោទ និង ទម្រង់នៃការទទួលខុសត្រូវតាមច្បាប់ ដែលនាំឱ្យមោឃភាពការសម្រេចលើយុត្តាធិការបុគ្គល ឬ សេចក្ដីសម្រេចរបស់ ស.ច.ស.ជ. មិនកំណត់ប្រភេទបទចោទតាមច្បាប់ មានភាពអយុត្តិធម៌ ឬ មិនសមហេតុផល បង្កើតឱ្យមានការបំពានឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថាតើ ស.ច.ស.ច. បានប្រព្រឹត្តកំហុសអង្គច្បាប់ ឬ ការបំពានឆន្ទានុសិទ្ធិ ជារួម ឬ ដោយឡែក ដោយរបៀបណា។ គួរច្រានចោល ផ្នែកមូលដ្ឋាន "ក" និង មូលដ្ឋាន "គ" ដែលនៅសេសសល់។

---

ស.ច.ស. "ត្រូវចេញដីកាលើកលែងចោទប្រកាន់ ... [*ក្នុងចំណោមនោះ* នៅពេល] ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្ដន្ទាទោស *ជនត្រូវចោទ*" (ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* Droit et pratique de l'instruction préparatoire (Dalloz), Christian Guéry and Pierre Chambon, Ordonnances de règlement (ឆ្នាំ២០១៨-២០១៩) កថាខណ្ឌ ៦១៤.១៤៖ "Les ordonnances de règlement indiquent la qualification légale du fait imputé à la *personne mise en examen*, et de façon précise, les motifs pour lesquels il existe ou non des charges suffisantes [pour ordonner un renvoi]." [ការបកប្រែក្រៅផ្លូវការ៖ "ដីកាដំណោះស្រាយត្រូវកំណត់ប្រភេទបទល្មើសទៅលើអង្គហេតុនានាប្រឆាំងនឹង *ជនត្រូវចោទ* និង មានលក្ខណៈច្បាស់លាស់ថា តើមាន ឬមិនមានភស្តុតាងគ្រប់គ្រាន់ [ដើម្បីបញ្ជូនរឿងទៅជំនុំជម្រះ]"] (ការគូសបញ្ជាក់បន្ថែម) (ឯកសារភ្ជាប់ ១១)។

239 *សូមមើល* កថាខណ្ឌ ៣២ *ខាងលើ*។

240 *សូមមើល* កថាខណ្ឌ ៣៣-៣៨ *ខាងលើ*។

241 *សូមមើល* ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

242 *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174។

### ឃ. ចម្លើយតបទៅនឹងមូលដ្ឋាន "ឃ"៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់ ឬ អង្គហេតុ នៅពេលពិចារណាលើការបង្ខិតបង្ខំ ការគៀបសង្កត់ និង បញ្ជាថ្នាក់លើ ក្នុងការសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត

៥៥. ស.ព.អ. បកស្រាយខុសនូវច្បាប់ជាធរមាននៅពេលជំនុំជម្រះ និង ច្បាប់ជាធរមាននៅពេលសម្រេចលើយុត្តាធិការបុគ្គល ដោយបានអះអាងថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ និង អង្គហេតុនៅពេលពិចារណាថា លោក មាស មុត បានធ្វើសកម្មភាពក្រោមការបង្ខិតបង្ខំ ការគៀបសង្កត់ និង បញ្ជារបស់ថ្នាក់លើ នៅពេលសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់គាត់[243]។ ស.ច.ស. ទាំងពីរបានពិចារណានៅក្នុងការវិភាគអំពីយុត្តាធិការបុគ្គលថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ សេចក្តីសម្រេចធ្វើឡើងនៅថ្នាក់កំពូល ហើយអនុវត្តនៅថ្នាក់ក្រោមៗ កម្មាភិបាលថ្នាក់ក្រោមៗ ដែលមានភារកិច្ចផ្សព្វផ្សាយ និង/ឬ អនុវត្តគោលនយោបាយ មានឆន្ទានុសិទ្ធិចង្អៀតនៅក្នុងការអនុវត្តការងារ ការខកខានមិនអនុវត្តបញ្ជានឹងនាំឱ្យមានផលវិបាកធ្ងន់ធ្ងរ ហើយប្រព័ន្ធរាយការណ៍ និងស្វ័យទិះទៀន បានបង្កើត "បរិយាកាសមិនទុកចិត្តគ្នាទៅវិញទៅមក"[244]។ ស.ច.ស.ជ. បានពិចារណាយ៉ាងត្រឹមត្រូវលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ដោយផ្អែកលើមុខតំណែង និង តួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខណៈដែលការបង្ខិតបង្ខំ ការគៀបសង្កត់ និង បញ្ជាថ្នាក់លើ មិនមែនជាសិទ្ធិការពារខ្លួនចំពោះ *ការទទួលខុសត្រូវព្រហ្មទណ្ឌ*[245]

---

[243] កថាខណ្ឌ ៨៣ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៧-៩៨, ១២១, ១៦៦-៦៧, ២១២, ២១៦, ២២៦, ២៣២, ២៤៨, ២៥២, ២៥៧, ២៧៧, ៣០៥, ៣១៦, ៣២២, ៣៨៦-៨៧, ៤១២, ៤១៥-១៦, ៤១៨, ៤២០, ៤២៤, ៤២៥ (លោក មាស មុត ត្រឹមតែទទួលភារកិច្ចអនុវត្ត និង ផ្សព្វផ្សាយគោលនយោបាយ ប.ក.ក. តែប៉ុណ្ណោះ)។ កថាខណ្ឌ ៩៨, ១០០, ២៥៦, ២៨៤, ៣៨៦, ៤១២, ៤១៥, ៤២០ (លោក មាស មុត ធ្វើសកម្មភាពក្រោមប្រព័ន្ធបែបបង្ខិតបង្ខំដែល ប.ក.ក. បានបង្កើតឡើង)។

[244] *សូមមើល* កថាខណ្ឌ ៣៨៦-៨៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ* កថាខណ្ឌ ៤២០ នៃដីកាសម្រេចលើកលែងចោទប្រកាន់៖ "កម្មាភិបាលគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមគោលនយោបាយបក្ស ...។ ជនដែលមិនអនុវត្តតាម ឬរិះគន់គោលនយោបាយ នឹងត្រូវបានគេចោទថាជាជនក្បត់ និងត្រូវបានកម្ទេច"។ *សូមមើលផងដែរ* កថាខណ្ឌ ៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់កថាខណ្ឌ ៤០-៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[245] *សូមមើល* កថាខណ្ឌ ៨៥-៨៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

កត្តាទាំងនេះអាចត្រូវបានពិចារណាសម្រាប់គោលបំណងផ្សេង ដូចជា ការកំណត់ទោស[246] និង យុត្តាធិការបុគ្គល[247]។

៥៦. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយសំអាងលើ *ទស្សនៈទៅក្រម* របស់អង្គជំនុំជម្រះតុលាការកំពូល ដែលកត់សម្គាល់ថា ការវាយតម្លៃលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កម្មាភិបាលខ្មែរក្រហម គឺ "មានន័យស្មើនឹងការបង្កើតឱ្យមានមធ្យោបាយការពារដោយប្រយោល ដោយមូលហេតុបញ្ជារបស់ថ្នាក់លើ" ហើយប៉ះពាល់ដល់មាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[248]។ ស.ច.ស. បានច្រានចោលយ៉ាងត្រឹមត្រូវ នូវការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូល[249]។ ខណៈដែលមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា "តួនាទី ឬ ឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពី *ការទទួលខុសត្រូវព្រហ្មទណ្ឌ*" មាត្រានេះអនុវត្តតែចំពោះអ្នកដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ប៉ុណ្ណោះ។ មាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនមានចែងអ្វីទាល់តែសោះអំពីអ្នកដែល *មិន* ស្ថិតនៅក្រោមយុត្តាធិការ អ.វ.ត.ក.។ ផ្ទុយទៅនឹងការអះអាងរបស់គាត់ ស.ព.អ. ទទួលស្គាល់ថា "ឋានន្តរសក្តិរបស់លោក មាស មុត... រួមទាំង... ថ្នាក់ឋានានុក្រមនៅពីលើគាត់" គឺជាកត្តាពាក់ព័ន្ធនៅក្នុងការសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់គាត់[250]។

៥៧. ស.ព.អ. ធ្វើឱ្យច្របូកច្របល់ ដោយអះអាងថា ប្រសិនបើការអនុវត្តតាមបញ្ជាថ្នាក់លើមិនរាប់បញ្ចូលជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ គ្មាននរណាម្នាក់អាចត្រូវបាននាំមកកាត់ទោសនោះឡើយ ដោយសារអ្នកគ្រប់គ្នាអាចអះអាងថា ប៉ុល ពត នៅពីលើពួកគេ ហើយមិនអត់

---

ក្នុងការសម្រេចផ្តន្ទាទោស ឌុច អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា គាត់ខកខានមិនបានបង្ហាញពីបទបញ្ជាថ្នាក់លើ និង ការបង្ខិតបង្ខំ ជាស្ថានសម្រាលទោស តែបានផ្តល់ទម្ងន់តិចតួចទៅលើ "បរិយាកាសបង្ខិតបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិប តេយ្យ និង តួនាទីតាមឋានានុក្រមរបស់គាត់នៅក្នុង ប.ក.ក."។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 ("សាលក្រមរឿងក្តី ០០១") កថាខណ្ឌ ៥៥៨, ៦០៧-០៨។

[247] *សូមមើល* កថាខណ្ឌ ៣៨៦-៨៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់កថាខណ្ឌ ៤០-៤១ នៃដីកាដំណោះស្រាយ។

[248] *សូមមើល* កថាខណ្ឌ ៨៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៦២ នៃសាលដីការឿងក្តី ០០១។

[249] កថាខណ្ឌ ៩ ជើងទំព័រ ៧ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១ ដែលដកស្រង់កថាខណ្ឌ ៦២ នៃសាលដីការឿងក្តី ០០១ និង ចោទសួរអំពី "ភាពត្រឹមត្រូវនៃការយោងទៅមាត្រា ២៩ [នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.] នៅក្នុងបរិបទនេះ"។

[250] កថាខណ្ឌ ១១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

ខិនអ្នកប្រឆាំងនឹងខ្លួននោះឡើយ[251]។ នួន ជា និង ខៀវ សំផន បានចូលរួមពាក់ព័ន្ធក្នុង *ការបង្កើតគោលនយោបាយ ប.ក.ក.*[252]។ អ្នកទាំងពីរមានសិទ្ធិអំណាចខ្លាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ នួន ជា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង ជាអនុលេខានៃ ប.ក.ក.[253] ហើយ ខៀវ សំផន គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និង ជាប្រធាននៃគណៈប្រធានរដ្ឋ[254]។ ឌុច មានឋានៈខុសពីនេះ។ ទោះបីជាគាត់មិនកាន់តំណែងជាអ្នកដឹកនាំនៅក្នុង ប.ក.ក. ក៏ដោយ ក៏គាត់បានសារភាពអំពីឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១ ត្រូវបានឃុំខ្លួននៅពន្ធនាគារតុលាការយោធា[255] និង ត្រូវបាននាំខ្លួនមកជំនុំជម្រះ។ ការខកខានមិនបានបញ្ជូន ឌុច មកជំនុំជម្រះ អាចនឹងបង្កើតជាបញ្ហាចោទ[256]។

៥៨. ស.ព.អ. ថ្លែងអំពីដីកាសម្រេចលើកលែងចោទប្រកាន់ខុស ដោយបានអះអាងថា ស.ច.ស.ជ. បានដកស្រង់សេចក្តីថ្លែងការណ៍មួយរបស់លោក មាស មុត ដែលគាំទ្រការអះអាងដែលថា គាត់បានធ្វើសកម្មភាពក្រោមការបង្ខិតបង្ខំ ឬ ការគៀបសង្កត់ នៅពេលអនុវត្តបញ្ជា[257]។ ការរកឃើញរបស់ ស.ច.ស.ជ. ដែលថា កម្មាភិបាលគ្រប់ថ្នាក់ត្រូវអនុវត្តតាមគោលនយោបាយបក្ស[258] គឺសំអាងលើភ័ស្តុតាងនៃកិច្ចប្រជុំស្វ័យទិះទៀន[259] ទម្រង់ផ្សេងទៀតសម្រាប់ការអនុវត្តទណ្ឌកម្ម នៅពេលទាហានមានកំហុស[260] និង សក្ខីកម្មដែលថា "មេបញ្ជាការដែលមិនគោរពបញ្ជា ឬ ត្រូវបានគេចាត់ទុកថា

[251] កថាខណ្ឌ ៨៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[252] កថាខណ្ឌ ៩០៣, ៩១៦-១៨, ៩៣៦, ១១៦៥, ១១៧៣, ១១៩២ នៃដីកាដំណោះស្រាយរឿងក្តី ០០២។

[253] កថាខណ្ឌ ៨៧០-៧១ នៃដីកាដំណោះស្រាយរឿងក្តី ០០២។

[254] កថាខណ្ឌ ១១៣១, ១១៣៥ នៃដីកាដំណោះស្រាយរឿងក្តី ០០២។

[255] ឧបសម្ព័ន្ធ I កថាខណ្ឌ ១ នៃសាលក្រមលើរឿងក្តី ០០១។

[256] *សូមមើល* Heder យុត្តាធិការបុគ្គល ទំព័រ ២៧។

[257] កថាខណ្ឌ ៨៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[258] កថាខណ្ឌ ៤២០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[259] កថាខណ្ឌ ២២៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ គីន ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D4.1.504, របាយការណ៍ចំណងជើង "បទឧទ្ទេសនាមរបស់សមមិត្តលេខា ក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រី លើកទី១" ថ្ងៃទី ២២ ខែមេសា ឆ្នាំ ១៩៧៦ ឯកសារ D4.1.739។

[260] កថាខណ្ឌ ២២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៨ ឯកសារ D4.1.1138, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០០៨ ឯកសារ D4.1.1151។

ក្បត់ នឹងត្រូវបានចាប់ខ្លួន និង ក្រោយមកត្រូវបានសម្លាប់"[261]។ ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា ស.ច.ស.ជ. មិនបានលើកឡើងផ្នែកមួយនៃសេចក្តីថ្លែងការណ៍របស់លោក មាស មុត[262] ដែលក្នុងនោះគាត់បាននិយាយថា មិនខុសពី ឌុច និង Herman Göring គាត់ត្រូវអនុវត្តតាមបញ្ជា[263]។ ការអះអាងរបស់ ស.ព.អ. បានត្រឹមតែអនុញ្ញាតឱ្យធ្វើការប្រៀបធៀបមិនពាក់ព័ន្ធ រវាងលោក មាស មុត ឌុច និង Göring ដើម្បីឱ្យមានឥទ្ធិពលលើផ្លូវអារម្មណ៍ប៉ុណ្ណោះ។

៥៩. ស.ព.អ. បកស្រាយខុសនូវសេចក្តីថ្លែងការណ៍ផ្សេងទៀតរបស់លោក មាស មុត ដោយអះអាងថា សេចក្តីថ្លែងការណ៍ទាំងនោះ "បង្ហាញការប្តេជ្ញាចិត្តដាច់ខាត និង ភាពស្មោះត្រង់របស់គាត់ចំពោះបក្ស"[264]។ ស.ច.ស. ទាំងពីរបានរកឃើញថា សុន សេន បានណែនាំបុគ្គលិកថ្នាក់ក្រោមអំពីមាគ៌ា និង គោលនយោបាយបក្ស[265]។ មាស មុត បានស្ងូត្រតាមមាគ៌ាបក្ស ពីព្រោះថាប្រសិនបើធ្វើផ្ទុយពីនេះ នឹងនាំឱ្យគេចាត់ទុកគាត់ថាជាអ្នកប្រឆាំងបដិវត្តន៍[266]។ ស.ច.ស. ទាំងពីរបានពិចារណាថា ខ្សែសង្វាក់បញ្ជារបស់ ប.ក.ក. និង គោលការណ៍រក្សាការសម្ងាត់ មិនបានអនុញ្ញាត លើកទឹកចិត្ត ឬ សម្របសម្រួល "ការផ្លាស់ប្តូរតាមលក្ខណៈសមភាពនៃខ្សែទទឹង" នូវព័ត៌មានដោយកម្មាភិបាលនៅក្រោមមេដឹកនាំជាន់ខ្ពស់នោះឡើយ[267] ហើយថាប្រព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ "មានវិបត្តិទាំង

---

[261] កថាខណ្ឌ ២២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408។

[262] ប្រតិចារឹក ដែលមានចំណងជើងថា "កិច្ចសម្ភាសន៍ មាស មុត ជាអតីតលេខាធិការគណៈកម្មាធិការមជ្ឈិមសម្រាប់កងពលធំ ១៦៤" ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០១ ឯកសារ D1.3.33.16។

[263] កថាខណ្ឌ ៨៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[264] កថាខណ្ឌ ៩០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់ទូរលេខរបស់ មាស មុត ដែលមានចំណងជើងថា "ទូរលេខ ០០៖ ៣៥៤ ខ្ទង់៖ គោរពជូនគណៈម.៨៧០" ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60 ERN 00001325។ កំណត់ហេតុនៃការប្រជុំផ្នែកយោធា ដែលមានចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ" ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 ERN 00052411។ Erika Kinetz និង យន់ សាមាន អ្វីដែលវាហួសឲ្យវាហួសទៅ (Let Bygones be Bygones) សារព័ត៌មានកម្ពុជាឌេលី ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០០៨ ឯកសារ D1.3.7.8 ERN 00165821 (ភាសាអង់គ្លេស)។

[265] *សូមមើល* កថាខណ្ឌ ១៦៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៧៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[266] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D4.1.520 ERN 00340575-00340576។ *សូមមើលផងដែរ* កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[267] កថាខណ្ឌ ៤១ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

ផ្នែកខាងក្រៅ ក៏ដូចជាផ្នែកខាងក្នុង ដោយមានការគ្រប់គ្រងដោយការភ័យខ្លាច និង ភាពរន្ធត់ តាមរយៈការប្រើប្រាស់ដោយចេតនានូវអំពើហិង្សា និង ភាពសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ"[268]។

៦០. ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា ការរកឃើញរបស់ ស.ច.ស.ជ. នៅក្នុងរឿងក្តី ០០១ "ផ្តល់ការបដិសេធទាំងស្រុងចំពោះការអះអាងដែលថា ទង្វើដែលបានធ្វើឡើងតាមបញ្ជាថ្នាក់លើ ធ្វើឱ្យជនណាម្នាក់រួចផុតពីប្រភេទដែល 'ទទួលខុសត្រូវខ្ពស់បំផុត'"[269] ដោយបានដកស្រង់ផ្នែកនៃដីកាបញ្ជូន ឌុច ទៅជំនុំជម្រះ ដែលមិនមែនជាការរកឃើញរបស់ ស.ច.ស. ប៉ុន្តែ ជាសេចក្តីថ្លែងការណ៍របស់ ឌុច ដើម្បីប្រយោជន៍ខ្លួនឯង[270]។ នៅពេលសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ស.ច.ស. បានពិចារណា *នៅក្នុងចំណោមនោះ* ថា ឌុច បានជ្រើសរើសកម្មាភិបាលក្រោមបង្គាប់របស់ខ្លួន[271] ថា ឌុច បានសម្រេចផ្លាស់ប្តូរអ្នកទោសទៅកាន់ទីតាំងមន្ទីរ ស-២១ ក្នុងពេលបច្ចុប្បន្ន[272] ថា តាំងពីពេលនោះមក ឌុច បានក្លាយជាប្រធានមន្ទីរ ស-២១ "រាល់សេចក្តីណែនាំនានា ដែលធ្វើឡើងចំពោះមន្ទីរ ស-២១ ឬ ចេញមកពីមន្ទីរ ស-២១ ហើយដែលទាក់ទងទៅនឹងការងារសន្តិសុខត្រូវតែឆ្លងកាត់គាត់សិន"[273] ថា ឌុច ខ្លួនឯង បានដើរតួនាទីនៅក្នុងការសម្រេចចាប់ខ្លួន[274] ថា ឌុច "បានទទួលស្គាល់ថា គាត់បានបញ្ជាឱ្យមានការធ្វើទារុណកម្មលើអ្នកទោសទៅតាមកម្រិតខុសៗគ្នា"[275] ហើយថា មាន "ការបញ្ជាដោយប្រយោល" ពី ឌុច ឱ្យសម្លាប់អ្នកទោសនៅមន្ទីរ ស-២១[276]។

៦១. ស.ព.អ. ខកខានមិនបានបង្ហាញសំអាងគាំទ្រការអះអាងរបស់ខ្លួនដែលថា លោក មាស មុត បានប្រព្រឹត្តឧក្រិដ្ឋកម្មដោយស្ម័គ្រចិត្ត និង យ៉ាងពេញចិត្ត ដោយមិនចាំបាច់មានការចាប់បង្ខំ ឬ ការគៀបសង្កត់[277]។ ស.ច.ស. ទាំងពីរបានយល់ឃើញថា លោក មាស មុត ទទួលបញ្ជាពី សុន សេន

---

[268] កថាខណ្ឌ ៣២៤ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[269] កថាខណ្ឌ ១០៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[270] កថាខណ្ឌ ១០៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៣១, ៣៣, ៤៤, ៥១-៥៣, ៦៨, ៧០, ៨៥, ៩៩, ១១១ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[271] កថាខណ្ឌ ២៩ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[272] កថាខណ្ឌ ២៧ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[273] កថាខណ្ឌ ៤២ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[274] កថាខណ្ឌ ៥៥-៥៩ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[275] កថាខណ្ឌ ៩៨ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[276] កថាខណ្ឌ ១០៧ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[277] កថាខណ្ឌ ៩២-៩៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

និង អគ្គសេនាធិការ[278] សេចក្តីសម្រេចត្រូវបានអនុវត្តដោយកម្មាភិបាលថ្នាក់ក្រោម ដោយមានផលវិបាកបុគ្គលក្នុងករណីមិនគោរពតាម[279] ហើយការពិភាក្សាដោយបើកចំហអំពីការណែនាំរបស់ថ្នាក់លើ "អាចត្រូវបានពិចារណាដោយថ្នាក់លើថា ជាវិធីដំបូងក្នុងការយកអំណាចដោយថ្នាក់ក្រោម"[280]។

៦២. ស.ព.អ. ខកខានមិនបានផ្តល់សំអាងគាំទ្រការអះអាងរបស់ខ្លួនដែលថា សុន សេន បានប្រតិភូកម្មសិទ្ធិអំណាចឱ្យលោក មាស មុត ធ្វើការចាប់ខ្លួន និង កម្ទេចចោល[281]។ មិនមាន ស.ច.ស. ណាម្នាក់រកឃើញថា សុន សេន បានធ្វើប្រតិភូកម្មសិទ្ធិអំណាចឱ្យទៅលោក មាស មុត ឡើយ។ ខណៈដែលនៅក្នុងការកំណត់ប្រភេទបទចោទតាមច្បាប់ ស.ច.ស.អ. បានថ្លែងថា លោក មាស មុត "មានអំណាចដែលត្រូវបានប្រគល់ឱ្យជាពិសេស ដើម្បីធ្វើការបោសសម្អាតកងពលធំ ១១៧"[282] គាត់មិនបានបង្ហាញការរកឃើញអង្គហេតុដែលគាំទ្រសេចក្តីសន្និដ្ឋាននេះទេ។ ជំនួសវិញ គាត់បានសម្រេចថា លោក មាស មុត ត្រូវបាន "*ចាត់តាំងដោយ សុន សេន* ឱ្យទៅជួយ ឬ បញ្ជាប្រតិបត្តិការយោធាជាក់លាក់មួយចំនួនសម្រាប់សេនាធិការ"[283]។ គ្មានភស្តុតាងណាមួយដែលដកស្រង់ដោយ ស.ច.ស.អ. នៅក្នុងការរកឃើញនេះ គាំទ្រសេចក្តីសន្និដ្ឋានដែលថា សុន សេន បានធ្វើប្រតិភូកម្មសិទ្ធិអំណាចឱ្យទៅលោក មាស មុត នោះឡើយ មានតែ សុន សេន *ប្រគល់ភារកិច្ច* ឱ្យទៅលោក មាស មុត[284]។

---

[278] កថាខណ្ឌ ១២១, ១៦៦, ២១២, ២១៦, ២២៦, ២៥២, ២៥៧, ៣១៦, ៣២២, ៤១៥, ៤២៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥០, ១៥៧, ២៧០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[279] កថាខណ្ឌ ៣៨៦-៨៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ កថាខណ្ឌ ៣៧-៤១ នៃដីកាដំណោះស្រាយរឿងក្តី 00៤/១។

[280] កថាខណ្ឌ ៣៨៦-៨៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ កថាខណ្ឌ ៣៩ នៃដីកាដំណោះស្រាយរឿងក្តី 00៤/១ ។

[281] កថាខណ្ឌ ៩៨-១០២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[282] កថាខណ្ឌ ៥៧៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[283] កថាខណ្ឌ ១៦៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ការគូសបញ្ជាក់បន្ថែម)។

[284] *សូមមើល* កថាខណ្ឌ ១៦៣ ជើងទំព័រ ៣៣៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡួន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឆ.១៣៖ ("ខ្ញុំទើបតែដឹងអំពីមុខងារថ្មី [របស់ មាស មុត] ជាជំនួយការសេនាធិការ នៅពេលដែលជិតវៀតណាមចូលមកហើយ"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឆ.២២, ឆ.២៥ (ឆ.២២៖ "តាមដែលខ្ញុំដឹង មាស មុត ជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន", ឆ.២៥៖ "តាមខ្ញុំដឹង ក្នុងនាមគាត់ជាអគ្គសេនាធិការរង ដូច្នេះគាត់ត្រូវតែទៅពិនិត្យស្ថានការណ៍នៅកន្លែងដែលមានជម្លោះនៅតាមព្រំដែន")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែ

៦៣. ស.ព.អ. ខកខានមិនបានគាំទ្រការអះអាងរបស់គាត់ដែលថា លោក មាស មុត បានបង្កើត និង បាន ចូលរួមនៅក្នុងយន្តការកំណត់អត្តសញ្ញាណអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំង និង បានបញ្ជាឱ្យ ចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១[285]។ មិនមាន ស.ច.ស. ណាម្នាក់ បានរកឃើញថា លោក មាស មុត មានសិទ្ធិអំណាចឯករាជ្យធ្វើការចាប់ខ្លួន និង បញ្ជូនទៅមន្ទីរ ស-២១ ឡើយ។

៦៤. *ជារួម* ស.ច.ស.ជ. បានពិចារណាយ៉ាងត្រឹមត្រូវលើកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុត ដោយផ្អែកលើមុខតំណែង និង តួនាទីរបស់គាត់ នៅក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បើទោះបីជា អ.ប.ជ. អនុវត្តកត្តាបញ្ជូនមិនពាក់ព័ន្ធរបស់សាលាក្តី ICTY ដែលស្នើដោយ ស.ព.អ. ដើម្បីសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ក៏ដោយ[286] ក៏យុត្តិសាស្ត្រស្តីពីការផ្ទេរសមត្ថកិច្ចនេះគាំទ្រការវិភាគរបស់ ស.ច.ស.ជ. ដែរ[287]។ ស.ច.ស.ជ. បាន វិភាគមុខតំណែងរបស់លោក មាស មុត នៅក្នុងខ្សែសង្វាក់នៃអ្នកទទួលខុសត្រូវទាំងមូល[288] ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម រវាងគាត់ជាមួយនឹងកម្មាភិបាលផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា សុន សេន[289] កម្រិតនៃសិទ្ធិអំណាចរបស់គាត់[290] មិនថាគាត់បានរៀបចំ ឬ ត្រឹមអនុវត្តបញ្ជា

---

មេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.៧៣-៧៥ (លើកឡើងថា សារឿន បានប្រាប់គាត់ថា លោក មាស មុត ទៅស្រុកមេមុត ក្នុងខេត្តកំពង់ចាមតាមបញ្ជារបស់ សុន សេន ហើយថា សុន សេន បានបញ្ជាលោក មាស មុត ឲ្យដឹកនាំទ័ពទៅបង្ក្រាបពួកបះបោរនៅភូមិភាគបូព៌ា)។

[285] កថាខណ្ឌ ១០៣-០៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[286] កថាខណ្ឌ ១១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[287] កថាខណ្ឌ ៤០៩-៣០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[288] *សូមមើល* កថាខណ្ឌ ១១១, ១១៧, ១២១, ១៤៣, ១៥៣, ១៦៣, ១៨៧-៨៨, ៤១៦, ៤២០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Rašević និង Todović* សំណុំរឿងលេខ IT-97-25/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធ I និង II សម្ងាត់ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។

[289] *សូមមើល* កថាខណ្ឌ ១៥៣, ៤១៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kovačević* សំណុំរឿងលេខ IT-01-42/2-I សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ និង តែភាគីម្ខាង ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Rašević និង Todović* សំណុំរឿងលេខ IT-97-25/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធ I និង II សម្ងាត់ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។

[290] *សូមមើល* កថាខណ្ឌ ១២២, ១៤១, ១៦៩, ១៨៧-៨៨, ៤១៦, ៤១៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* សំណុំរឿងលេខ IT-98-29/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី

របស់អ្នកផ្សេង[291] ព្រមទាំងតួនាទីជាក់ស្តែង និង កម្រិតនៃការចូលរួមរបស់គាត់ នៅក្នុងឧក្រិដ្ឋកម្ម ដែលចោទប្រកាន់[292]។ ដោយខកខានមិនបានបង្ហាញឱ្យឃើញកំហុសអង្គច្បាប់ នៅក្នុងការពិចារណា របស់ ស.ច.ស.ជ. លើការបង្ខិតបង្ខំ ការគៀបសង្កត់ និង បញ្ជារបស់ថ្នាក់លើ ដែលធ្វើឱ្យមោឃភាពការសម្រេចលើយុត្តាធិការបុគ្គល ដែលធ្វើឱ្យ ស.ច.ស.ជ. ធ្វើសេចក្តីសម្រេចលើអង្គហេតុណាមួយ ដែលគ្មាន ស.ច.ស. សមហេតុផលណាម្នាក់សម្រេចដូច្នេះ ដែលនាំឱ្យមានកំហុសនៅក្នុងការស្វែងរកយុត្តិធម៌ ឬ ដែលការវិភាគរបស់ ស.ច.ស.ជ. លើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត មិនមានភាពយុត្តិធម៌ ឬ មិនសមហេតុផល នាំឱ្យមានការបំពានលើឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ ជារួម ឬ ដោយឡែក ដោយរបៀបណា។ គួរច្រានចោល មូលដ្ឋាន “ឃ”។

---

អនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić* សំណុំរឿងលេខ IT-98/32/1-AR11*bis*.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទិននឹងការបញ្ជូនរឿងក្តី ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២១។

[291] *សូមមើល* កថាខណ្ឌ ៤១៦, ៤២០, ៤២២, ៤២៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២០។

[292] *សូមមើល* កថាខណ្ឌ ២២០-២៥, ៤២៥-២៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić* សំណុំរឿងលេខ IT-98/32/1-AR11*bis*.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទិននឹងការបញ្ជូនរឿងក្តី ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ademi និង Norac* សំណុំរឿងលេខ IT-04-78-PT សេចក្តីសម្រេចបញ្ជូនរឿងក្តីទៅអាជ្ញាធរសាធារណរដ្ឋក្រូអាស៊ី អនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ២៨, ៣០។

### ង. ចម្លើយតបនឹងមូលដ្ឋាន "ង"៖ ស.ច.ស.ជ. មិនមានកំហុសអង្គច្បាប់ ឬ អង្គហេតុ នៅពេលពិចារណាលើការចូលរួមផ្ទាល់របស់ មាស មុត នៅក្នុង និង កៀកកិតនឹងឧក្រិដ្ឋកម្ម នៅក្នុងការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវ

៦៥. ស.ព.អ. ដកស្រង់ដោយនាំឱ្យយល់ខុស នូវយុត្តិសាស្ត្រមិនពាក់ព័ន្ធ អំពីច្បាប់ស្តីពីទម្រង់នៃការទទួលខុសត្រូវ នៅពេលសវនាការ[293] ដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ និង អង្គហេតុ នៅពេលពិចារណាអំពីការចូលរួមដោយផ្ទាល់នៅក្នុង និង កៀកកិតនឹងឧក្រិដ្ឋកម្ម នៅពេលកំណត់កម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត[294]។ ស.ច.ស.ជ. បានពិចារណាដោយត្រឹមត្រូវ លើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ដោយផ្អែកលើការចូលរួមជាក់ស្តែងនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ខណៈដែលការចូលរួមក្នុងឧក្រិដ្ឋកម្ម មិនតម្រូវឱ្យមានភាពកៀកកិតជាក់ស្តែងនោះ ការចូលរួមជាក់ស្តែងរបស់ជនត្រូវចោទ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ពោលគឺអំពើជាមូលដ្ឋាន និង ការប្រព្រឹត្តិរបស់ជនត្រូវចោទ គឺជាកត្តាពាក់ព័ន្ធមួយដែលត្រូវពិចារណានៅក្នុងការសម្រេចលើយុត្តាធិការបុគ្គល[295] ហើយក៏ដូចគ្នាផងដែរក្នុងការកំណត់ទោសទណ្ឌ[296]។

៦៦. ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា "អំពើដែលចូលរួមចំណែកក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិ អាចមិនមែនជាអំពើប្រព្រឹត្តដោយផ្ទាល់តាមភូមិសាស្ត្រ និង ពេលវេលាទេ ហើយជារឿយៗចំពោះជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត"[297]។ ខណៈដែលមិនតម្រូវឱ្យមានការចូលរួម

---

[293] កថាខណ្ឌ ១១៥ ជើងទំព័រ ៤៦២-៦៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[294] កថាខណ្ឌ ១១៣-១៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[295] *សូមមើល* កថាខណ្ឌ ៣៨ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១ ។

[296] *សូមមើល* កថាខណ្ឌ ៥៩៦ នៃសាលក្រមលើរឿងក្តី ០០១ (ក្នុងការវាយតម្លៃអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋាន អង្គជំនុំជម្រះ "គួរពិចារណាអំពីតួនាទីរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ")។ *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E313 ("សាលក្រមសំណុំរឿង ០០២/០១") កថាខណ្ឌ ១០៦៧ ("ការផ្តន្ទាទោសត្រូវតែមានលក្ខណៈឯកត្តបុគ្គល និង សមាមាត្រទៅនឹងអំពើដែលឆ្លុះបញ្ចាំងពីពិរុទ្ធភាពរបស់ជនជាប់ចោទ និង ត្រូវផ្អែកលើការវិភាគដែលមានលក្ខណៈជាសត្យានុម័ត មានហេតុផលសមរម្យ និង មានការថ្លឹងថ្លែងត្រឹមត្រូវ ទាំងទៅលើអំពើរបស់ជនជាប់ចោទ និង ទាំងទៅលើព្យសនកម្មនានា ដែលជាផលវិបាកនៃការប្រព្រឹត្តិអំពើទាំងនោះ។ គោលការណ៍ទាំងនោះក៏ត្រូវបានទទួលស្គាល់ និង អនុវត្តនៅក្នុងច្បាប់កម្ពុជាផងដែរ")។

[297] កថាខណ្ឌ ១១៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

ដោយផ្ទាល់ សម្រាប់ការចោទប្រកាន់នៅក្រោមទម្រង់នៃការទទួលខុសត្រូវភាគច្រើន នេះមិនមែនជាមូលដ្ឋានដែល ស.ច.ស.ជ. យកមកសំអាង នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។ ក្រៅពីរកឃើញថាលោក មាស មុត មិនមានវត្តមាននៅទីតាំងឧក្រិដ្ឋកម្មជាច្រើននោះ[298] ស.ច.ស.ជ. បានផ្តោតលើ "វិសាលភាពនៃសកម្មភាពផ្ទាល់ [របស់លោក មាស មុត] *និង អនុភាពនៃអំពើទាំងនោះ*"[299] "អនុភាពនៅក្នុងឋានានុក្រម" និង "កម្រិតនៃការចូលរួមចំណែករបស់គាត់ ក្នុងការសម្រេចលើគោលនយោបាយ និង/ឬ អនុវត្តគោលនយោបាយ"[300]។ ស.ច.ស.ជ. បានរកឃើញថា លោក មាស មុត ទទួលបន្ទុកកិច្ចការនយោបាយជាចម្បង ហើយសកម្មភាពរបស់គាត់រួមមានការផ្សព្វផ្សាយគោលនយោបាយ ប.ក.ក.[301]។

៦៧. ស.ព.អ. បកស្រាយខុសនូវដីកាសម្រេចលើកលែងចោទប្រកាន់ ដោយអះអាងថា ស.ច.ស.ជ. បានបង្កើត "ការញែកដោយខុសច្បាប់" រវាងមេដឹកនាំជាន់ខ្ពស់ និង អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត[302]។ ស.ច.ស.ជ. បានរកឃើញ ស្របតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល[303] ថា មេដឹកនាំជាន់ខ្ពស់ "ដែលមិនចូលរួមយ៉ាងសកម្ម" នៅក្នុងសកម្មភាពឧក្រិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ អាចមិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ផ្ទុយមកវិញ "បុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងឋានានុក្រមថ្នាក់ក្រោម អាចត្រូវបានចាត់ទុកថាជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត អាស្រ័យលើការចូលរួមចំណែកដោយឡែកៗរបស់បុគ្គលនោះចំពោះអំពើឃោរឃៅ"[304]។ ស.ច.ស.ជ. ក៏មិនមែន "មិនយកចិត្តទុកដាក់លើគោលការណ៍ដែលត្រូវបានទទួលស្គាល់" ដែលថា ក្នុងការវាយតម្លៃលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត "ឋានានុក្រម ឬ មុខតំណែងរបស់គាត់... ត្រូវតែយកមកពិចារណា"[305]។

---

[298] កថាខណ្ឌ ២៩៧, ៣០៥, ៣១១ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[299] កថាខណ្ឌ ៣៦៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ (ការគូសបញ្ជាក់បន្ថែម)។

[300] កថាខណ្ឌ ៣៦៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[301] កថាខណ្ឌ ៤១៦, ៤២២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[302] កថាខណ្ឌ ១១៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[303] កថាខណ្ឌ ៥៧ នៃសាលដីការឿងក្តី ០០១។

[304] កថាខណ្ឌ ៣៦៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើលផងដែរ* កថាខណ្ឌ ៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលដកស្រង់កថាខណ្ឌ ៣៨-៣៩ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[305] កថាខណ្ឌ ១១៧ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើល* កថាខណ្ឌ ៦៤ *ខាងលើ* ។

៦៨. ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា ការរកឃើញរបស់ ស.ច.ស.ជ. លើយុត្តាធិការបុគ្គលក្នុងរឿងក្តី ០០២ គឺផ្ទុយគ្នាពីការរកឃើញរបស់ខ្លួននៅក្នុងរឿងក្តី ០០៣ ពីព្រោះថា ស.ច.ស. មិនបានរកឃើញថា ជនត្រូវចោទទាំងបួននាក់ បានចូលរួមដោយផ្ទាល់ក្នុងឧក្រិដ្ឋកម្មនោះឡើយ[306]។ ដូចដែល ស.ព.អ. ទទួលស្គាល់ ស.ច.ស. បានរកឃើញថា ជនត្រូវចោទក្នុងរឿងក្តី ០០២ គឺជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត "អាស្រ័យទៅតាម *ការចូលរួមជាបុគ្គលរបស់អ្នកទាំងនោះនៅក្នុងការអនុវត្ត* ផែនការរួមរបស់ ប.ក.ក"[307]។ កាន់តែច្បាស់ជាងនេះទៀតនោះ ស.ច.ស. បានរកឃើញថា ជនត្រូវចោទក្នុងរឿងក្តី ០០២ បានចូលរួមក្នុង *ការបង្កើតគោលនយោបាយ ប.ក.ក.* ដែលធ្វើឱ្យចេញជារូបរាងនូវឧក្រិដ្ឋកម្មទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ[308] ។ ជាការរកឃើញដែលមិនមែនធ្វើឡើងដោយ ស.ច.ស. ណាម្នាក់ ទាក់ទងនឹងលោក មាស មុត។ ស.ច.ស. ផ្តោតស្រដៀងគ្នាទៅលើ "អំណាចឋានានុក្រមផ្លូវការ និង ប្រកបដោយប្រសិទ្ធភាព និងការចូលរួមដោយផ្ទាល់" របស់ ឌុច នៅក្នុងឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១ ពោលគឺ "វត្តមាន និង ការចូលរួមរបស់គាត់នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការមន្ទីរ ស-២១" ក្នុងការរកឃើញថា ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[309]។

៦៩. ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា "គ្មានសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់សាលាក្តី ICTY ដែលជននោះត្រូវបានបញ្ជាក់ថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត មិនបានឱ្យតម្លៃខ្លាំងទៅលើការកៀកកិតនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ ការចូលរួមដោយផ្ទាល់នោះទេ"[310]។ ស.ព.អ. លុបចោលសេចក្តីសម្រេចផ្សេងទៀតរបស់ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចដែលពិចារណាលើ "តួនាទីជាក់ស្តែងរបស់ជនជាប់ចោទ និង កម្រិតនៃការចូលរួមរបស់ជននោះនៅ

---

[306] កថាខណ្ឌ ១១៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[307] កថាខណ្ឌ ១៣២៧-២៨ នៃដីកាដំណោះស្រាយរឿងក្តី ០០២ (ការគូសបញ្ជាក់បន្ថែម)។

[308] *សូមមើល* កថាខណ្ឌ ៥៧ ជើងទំព័រ ២៥ *ខាងលើ*, កថាខណ្ឌ ៨៧ ជើងទំព័រ ៣៧៣ *ខាងក្រោម* ។

[309] កថាខណ្ឌ ១២៩, ១៦០ នៃដីកាដំណោះស្រាយរឿងក្តី ០០១។

[310] កថាខណ្ឌ ១១៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* សំណុំរឿងលេខ IT-98-29/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២១-២៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić* សំណុំរឿងលេខ IT-98/32/1-AR11bis.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទិននឹងការបញ្ជូនរឿងក្តី ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២១-២៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delić* សំណុំរឿងលេខ IT-04-83-PT សេចក្តីសម្រេចលើសំណើសុំការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២០-២៥។

ក្នុងឧក្រិដ្ឋកម្មនីមួយៗ”[311] ក្នុងនោះរួមមាន ការចូលរួមជាក់ស្តែងរបស់ជនជាប់ចោទ នៅក្នុងសហឧក្រិដ្ឋកម្មរួម (ជាអាទិ៍ អំពើ និង ការប្រព្រឹត្តិជាមូលដ្ឋានរបស់ពួកគេ)[312]។

៧០. ស.ព.អ. ខកខានមិនបានផ្តល់សំអាងគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា មាស មុត មានតួនាទីដោយផ្ទាល់ និង សកម្មនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[313]។ មិនមាន ស.ច.ស. ណាម្នាក់ បានរកឃើញថា លោក មាស មុត មានតួនាទីដោយផ្ទាល់ ឬ សកម្មនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ[314]។ ស.ច.ស.អ. ដែលសម្រេចបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ បានរកឃើញថា លោក មាស មុត អវត្តមានពីទីតាំងឧក្រិដ្ឋកម្ម និង ហេតុការណ៍ឧក្រិដ្ឋជាច្រើន ដែលបានចោទប្រកាន់នៅក្នុងរឿងក្តី ០០៣[315]។

៧១. *ជារួម* ស.ច.ស.ជ. បានពិចារណាយ៉ាងត្រឹមត្រូវ ទៅលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ដោយផ្អែកលើការចូលរួមរបស់គាត់ដោយផ្ទាល់នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ដោយខក

---

[311] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២០។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić* សំណុំរឿងលេខ IT-98/32/1-AR11*bis*.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទិននឹងការបញ្ជូនរឿងក្តី ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ademi និង Norac* សំណុំរឿងលេខ IT-04-78-PT សេចក្តីសម្រេចបញ្ជូនរឿងក្តីទៅអាជ្ញាធរសាធារណរដ្ឋក្រូអាស៊ី អនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ២៨។

[312] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ademi និង Norac* សំណុំរឿងលេខ IT-04-78-PT សេចក្តីសម្រេចស្តីពីការបញ្ជូនរឿងក្តីទៅឱ្យអាជ្ញាធរនៃសាធារណរដ្ឋក្រូអាស៊ី ដោយអនុលោមតាមវិធាន ១១*ស្ទួន* ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ៣០។

[313] កថាខណ្ឌ ១២១-៣៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[314] កថាខណ្ឌ ៤២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣០៣, ៣១៥, ៤២៥, ៤៣៥, ៤៤៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[315] កថាខណ្ឌ ៣០៣, ៣១៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (លោក មាស មុត ពុំមាន “ការចូលរួមដោយផ្ទាល់” នៅក្នុងការបោសសម្អាតកងពលធំលេខ ៥០២ ឬ កងពលធំលេខ ៣១០” នោះទេ), កថាខណ្ឌ ៣៥៤ (យល់ឃើញថា មិនមានភ័ស្តុតាងបញ្ជាក់ថា លោក មាស មុត បានចុះទៅបិតត្រាំងទេ ប៉ុន្តែ គាត់បានចុះទៅកេងកង), កថាខណ្ឌ ៤២៥ (“ពុំមានភ័ស្តុតាងគួរឱ្យជឿជាក់ដែលបញ្ជាក់ថា មាស មុត បានចុះទៅពិនិត្យទីតាំងនោះដោយផ្ទាល់ទេ”), កថាខណ្ឌ ៤៣៥ (យល់ឃើញថា ភ័ស្តុតាងតែមួយគត់ដែលផ្តល់តម្រុងថា មាស មុត ខ្លួនគាត់បានចូលរួមនៅក្នុងការសួរចម្លើយនៅឯវត្តឥន្ទញាណនោះ គឺជាបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនស្របគ្នា និង ដែលមិនអាចឱ្យជឿជាក់បានទេ), កថាខណ្ឌ ៤៤៣ (មិនមានភ័ស្តុតាងគួរឱ្យជឿជាក់បានថា លោក មាស មុត បានចុះដល់វត្តឥន្ទញាណនេះទេ), កថាខណ្ឌ ៤៥៥ (យល់ឃើញថា ពុំមានភ័ស្តុតាងបញ្ជាក់ថា លោក មាស មុត បានដឹកនាំការរៀបការ ឬចូលរួមក្នុងពិធីរៀបការទេ)។

ខានមិនបានបង្ហាញឱ្យឃើញកំហុសអង្គច្បាប់ណាមួយនៅក្នុងការពិចារណារបស់ ស.ច.ស.ជ. លើការចូលរួមនៅក្នុង និង ភៀកកិតនឹងឧក្រិដ្ឋកម្ម ដែលធ្វើឱ្យមោឃភាពការសម្រេចលើយុត្តាធិការបុគ្គលរបស់គាត់ ដែលធ្វើឱ្យ ស.ច.ស.ជ. ធ្វើសេចក្តីសម្រេចលើអង្គហេតុណាមួយ ដែលគ្មាន ស.ច.ស. សមហេតុផលណាម្នាក់សម្រេចដូច្នេះ ដែលនាំឱ្យមានកំហុសនៅក្នុងការស្វែងរកយុត្តិធម៌ ឬ ដែលការវិភាគរបស់ ស.ច.ស.ជ. លើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត មិនមានភាពយុត្តិធម៌ ឬ មិនសមហេតុផល នាំឱ្យមានការបំពានលើឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ ជារួម ឬ ដោយឡែក ដោយរបៀបណា។ គួរច្រានចោល មូលដ្ឋាន "ង"។

### ច. ចម្លើយតបទៅនឹងមូលដ្ឋាន "ច"៖ ស.ច.ស.ជ. មិនបានធ្វើសេចក្តីសម្រេចលើអង្គហេតុដោយមានកំហុស ដែលមានឥទ្ធិពលជាកត្តាកំណត់លើបញ្ហាយុត្តាធិការបុគ្គល

៧២. ស.ព.អ. ខកខានមិនបានផ្តល់សំអាងគាំទ្រការអះអាងរបស់ខ្លួនដែលថា ដោយមិនអើពើនឹងភស្តុតាងដែលប្រមូលបាននៅមុន និង ក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ស.ច.ស.ជ. បានធ្វើសេចក្តីសម្រេចលើអង្គហេតុ "មិនសមហេតុផលមួយចំនួន" ដែល "បានដើរតួនាទីសំខាន់" នៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល[316]។ ស.ច.ស.ជ. មិនធ្វើសេចក្តីសម្រេចលើអង្គហេតុដោយមានកំហុសដែលមានឥទ្ធិពលជាកត្តាកំណត់លើការសម្រេចពីយុត្តាធិការបុគ្គលរបស់ខ្លួន ដែលជាលទ្ធផលនៃការខកខានណាមួយក្នុងការវាយតម្លៃភស្តុតាងឡើយ[317]។ គ្មានការអះអាងណាមួយរបស់ ស.ព.អ. នៅក្នុងមូលដ្ឋាន "ច" បង្ហាញឱ្យឃើញថា លោក មាស មុត មានតំណែង ឬ កម្រិត ឬ សិទ្ធិអំណាចខ្ពស់ជាងអ្វីដែលរកឃើញដោយ ស.ច.ស.អ. ឡើយ។

៧៣. ***ស.ច.ស.ជ. មិនមានកំហុសអង្គហេតុក្នុងការកំណត់តំណែងរបស់លោក មាសមុត ជាមេបញ្ជាការកងពលធំ ១៦៤ ឬ លេខាតំបន់ស្វយ័តកំពង់សោមឡើយ*** ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ស.ច.ស.ជ. មានកំហុសអង្គហេតុក្នុងការរកឃើញថា លោក មាស មុត បានក្លាយជាមេបញ្ជាការកងពលធំ ១៦៤ "យ៉ាងហោចណាស់រវាងខែមករា ឆ្នាំ ១៩៧៦ ដល់ខែមេសា ឆ្នាំ ១៩៧៨ និង ជា

[316] កថាខណ្ឌ ១៣៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[317] កថាខណ្ឌ ៥៨, ១៣៥, ១៥៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

ប្រធានគណៈកម្មាធិការតំបន់កំពង់សោមផងដែរ"[318]។ ស.ច.ស.ជ. មិនបានសន្និដ្ឋានថា លោក មាស មុត គឺជាមេបញ្ជាការកងពលធំ ១៦៤ និង ជាលេខាតំបន់ស្វយ័តកំពង់សោម *នៅត្រឹមតែ* រវាង ខែមករា ឆ្នាំ ១៩៧៦ ដល់ខែមេសា ឆ្នាំ ១៩៧៨ នោះឡើយ។ បើទោះបីជា ស.ច.ស.ជ. មានកំហុស ក្នុងការកំណត់អំឡុងរយៈពេលដែលលោក មាស មុត កាន់តំណែងទាំងនេះក៏ដោយ ក៏ ស.ព.អ. ខក ខានមិនបានបង្ហាញថា តើកំហុសនេះជាកត្តាកំណត់ជាមូលដ្ឋាន ទៅលើការសម្រេចលើយុត្តាធិការ បុគ្គលរបស់ ស.ច.ស.ជ. ដោយរបៀបណាដែរ។

៧៤. ដោយស្រង់ឯកសារផ្លូវការរបបកម្ពុជាប្រជាធិបតេយ្យមកសំអាង ជាអាទិ៍ "ទូរលេខដែលនៅសល់ទី មួយរបស់ មាស មុត និង សារតាមទូរស័ព្ទដែលបានកត់ត្រាចុងក្រោយរបស់គាត់"[319] ស.ច.ស.ជ. បានពិចារណាឃើញថា លោក មាស មុត គឺជាលេខាកងពលធំ ១៦៤ នៅកំពង់សោម "*យ៉ាងហោច ណាស់* រវាងខែមករា ឆ្នាំ ១៩៧៦ ដល់ខែមេសា ឆ្នាំ ១៩៧៨"[320]។ ពាក្យថា "យ៉ាងហោចណាស់" បង្ហាញថា ស.ច.ស.ជ. មិនបានសន្និដ្ឋានដោយជាក់លាក់ថា លោក មាស មុត គឺជាមេបញ្ជាការ កងពលធំ ១៦៤ ត្រឹមតែក្នុងអំឡុងពេលនេះទេ។ ផ្ទុយទៅវិញ ការរកឃើញផ្សេងទៀតនៅក្នុងដីកា សម្រេចលើកលែងចោទប្រកាន់បង្ហាញថា ស.ច.ស.ជ. បានរកឃើញថា លោក មាស មុត បានកាន់ តំណែងរបស់ខ្លួនជាមេបញ្ជាការកងពលធំ នៅមុនឆ្នាំ ១៩៧៥ និង បន្តបញ្ជាកងពលធំនេះ នៅក្រោយ ខែមេសា ឆ្នាំ ១៩៧៨។

៧៥. ស.ច.ស.ជ. ក៏ដូចជា ស.ច.ស.អ. បានរកឃើញថា លោក មាស មុត គឺជាមេបញ្ជាការកងពលធំ ៣ នៅមុនខែមេសា ឆ្នាំ ១៩៧៥[321] កងពលធំ ៣ ប្តូរឈ្មោះទៅជាកងពលធំ ១៦៤ នៅក្រោយពេល ផ្លាស់ប្តូរទីតាំងទៅកំពង់សោម[322] និង ថា លោក មាស មុត គឺជាមេបញ្ជាការនៅពេលដែលកងពល

---

[318] កថាខណ្ឌ ១៣៧-៤១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ កថាខណ្ឌ ១៨៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[319] កថាខណ្ឌ ១៣៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ១៨៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ របាយការណ៍ ដែលមានចំណងជើងថា៖ "សេចក្តីរាយការណ៍ពី មាស មុត សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2។ របាយការណ៍ ដែលមានចំណងជើងថា៖ "ទូរស័ព្ទសំងាត់ពី មាស មុត" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D1.3.30.25។ របាយការណ៍ ដែលមានចំណងជើងថា៖ "របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ផ្ញើមកពីទាញ" ចុះថ្ងៃទី ៤ ខែមករា ឆ្នាំ១៩៧៦ ERN 00160081 ឯកសារ D1.3.12.1។

[320] កថាខណ្ឌ ១៨៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ (ការគូសបញ្ជាក់បន្ថែម)។

[321] កថាខណ្ឌ ១៨២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥៦ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[322] កថាខណ្ឌ ១៨៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ធំ ៣ បានក្លាយជាកងពលធំ ១៦៤[323]។ ស.ច.ស.ជ. រកឃើញថា កងពលធំ ៣ បានក្លាយជាកងពលធំ ១៦៤ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៧៥[324] ដូចការលើកឡើងរបស់ ស.ព.អ. នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[325]។ ស.ព.អ. ទទួលស្គាល់ថា "ភ័ស្តុតាងដែលដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែក ដើម្បី... កំណត់សំអាងហេតុទាំងនេះ ទទួលស្គាល់យ៉ាងច្បាស់ថា មាស មុត គឺជាលេខាកងពលលេខ ៣/កងពលធំ ១៦៤ យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ ១៩៧៤"[326]។ ការណ៍ដែលថា "ចំណុចនេះត្រូវបានគាំទ្រដោយភ័ស្តុតាងដទៃៗយ៉ាងច្រើន" ដែលត្រូវបានប្រមូលនៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[327] បញ្ជាក់ថា លោក មាស មុត គឺជាមេបញ្ជាការកងពលធំ ៣ មុនពេលក្លាយជាមេបញ្ជាការកងពលធំ ១៦៤ គឺមានទម្ងន់លុបលើការអះអាងរបស់ ស.ព.អ. ដែលថា ការខកខានណាមួយមិនបានពិចារណាលើភ័ស្តុតាងបាននាំ ស.ច.ស.ជ. ទៅរកការសម្រេចដែលមានកំហុស។

៧៦. ខណៈដែល ស.ច.ស.ជ. មិនបានបញ្ជាក់កាលបរិច្ឆេទនៃការបញ្ចប់តំណែងរបស់លោក មាស មុត ជាមេបញ្ជាការកងពលធំ ១៦៤ ស.ច.ស.ជ. បានធ្វើការសម្រេចដែលបង្ហាញថា លោក មាស មុត បន្តបញ្ជាកងពលធំ ១៦៤។ ក្នុងការរៀបរាប់សមាសភាពកងពលធំ ១៦៤ ស.ច.ស.ជ. បានរកឃើញថា វរសេនាធំលេខ ១៦២ របស់កងពលធំ ១៦៤ ត្រូវបានបញ្ជូនទៅព្រំដែនវៀតណាមនៅក្រោយឆ្នាំ ១៩៧៨[328] ហើយថា ឈ្មោះ ហាន ដែលបញ្ជាកងវរសេនាតូចលេខ ១៤៤ របស់កងពលធំ ១៦៤ ត្រូវបានតំឡើងតំណែងជាប្រធានវរសេនាធំលេខ ១៤០ នៅពាក់កណ្តាលឆ្នាំ ១៩៧៨[329]។ ស.ច.ស.ជ. មិនបានរកឃើញថា លោក មាស មុត (ឬ កងពលធំ ១៦៤) មិនគ្រប់គ្រងកងវរសេនាធំ ឬ កងវរសេនាតូចទាំងនេះ នៅក្រោយខែមេសា ឆ្នាំ ១៩៧៨ ឡើយ។

---

[323] កថាខណ្ឌ ១៨៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥៦ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[324] កថាខណ្ឌ ១៨៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[325] កថាខណ្ឌ ៦០ នៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ.៖ "នៅក្រោយការប្រកាសអំពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា នៅខែកក្កដា ឆ្នាំ១៩៧៥ កងពលលេខ ៣ របស់ **មាស មុត** ត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ និង បានក្លាយជាកងពលមជ្ឈិម ដែលរាយការណ៍ដោយផ្ទាល់ទៅសេនាធិការ។ កងពលលេខ ៣ ត្រូវបានរួមបញ្ចូលគ្នាជាមួយកងកម្លាំងផ្សេងទៀត និង បានប្តូរឈ្មោះទៅជាកងពល ១៦៤ ..." (អក្សរដិតក្នុងសំណៅដើម)។

[326] កថាខណ្ឌ ១៣៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[327] កថាខណ្ឌ ១៣៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[328] កថាខណ្ឌ ១៩៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[329] កថាខណ្ឌ ២០០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

៧៧. ស.ព.អ. ខកខានមិនបានពន្យល់ថា បើទោះបីជា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស នៅក្នុងការរកឃើញថា លោក មាស មុត គឺជាមេបញ្ជាការកងពលធំ ១៦៤ និង ជាលេខាតំបន់ស្វយ័តកំពង់សោម *ត្រឹមតែ* រហូតដល់ខែមេសា ឆ្នាំ១៩៧៨ ក្តី តើភាពខុសគ្នាចំនួនប្រាំបួនខែនៅក្នុងក្របខ័ណ្ឌពេលវេលានេះ (ខែមេសា ឆ្នាំ ១៩៧៨ ដល់ខែមករា ឆ្នាំ ១៩៧៩) គឺជាកត្តាកំណត់ជាមូលដ្ឋានទៅលើការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ. ដោយរបៀបណា។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ មិនមានចំណុចណាមួយដែល ស.ព.អ. ពន្យល់អំពីសារៈសំខាន់នៃក្របខ័ណ្ឌពេលវេលានេះ ថាតើក្របខ័ណ្ឌពេលវេលានេះអាចបានធ្វើឱ្យប្រែប្រួលដល់ការវាយតម្លៃរបស់ ស.ច.ស.ជ. ទៅលើតួនាទី និង តំណែងរបស់ មាស មុត នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ សមត្ថភាពរបស់ មាស មុត ក្នុងការបង្កើត និង/ឬ អនុវត្តគោលនយោបាយ ប.ក.ក. ឬ ស្ថានទម្ងន់នៃអំពើ និង ការប្រព្រឹត្តិរបស់លោក មាស មុត ដោយរបៀបណាឡើយ[330]។

៧៨. គ្មាន ស.ច.ស. ណាម្នាក់ បានធ្វើការសម្រេចជាក់លាក់លើកាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់នៃតំណែងរបស់លោក មាស មុត ជាលេខាតំបន់ស្វយ័តកំពង់សោមឡើយ[331]។ ខណៈដែល ស.ច.ស.អ. បានរកឃើញថា គ្មានភ័ស្តុតាងបង្ហាញថា លោក មាស មុត ធ្លាប់ផ្លាស់ប្តូរតំណែងរបស់គាត់ជាលេខាតំបន់ស្វយ័តកំពង់សោមនោះ[332] គ្មាន ស.ច.ស. ណាម្នាក់ បានចាត់ទុកតំណែងរបស់លោក មាស មុត ជាលេខាតំបន់ស្វយ័តកំពង់សោមថា ជាតំណែងខ្ពស់នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យឡើយ នៅក្នុងការកំណត់កម្រិតការទទួលខុសត្រូវរបស់លោក មាស មុត នោះ[333]។

៧៩. ***ស.ច.ស.ជ. មិនមានកំហុសអង្គហេតុ នៅក្នុងការកំណត់តំណែង និង តួនាទីរបស់លោក មាស មុត នៅក្នុងសេនាធិការ*** ស.ព.អ. ខកខានមិនបានបង្ហាញសំអាងគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ស.ច.ស.ជ. មានកំហុសអង្គហេតុ ក្នុងការរកឃើញថា លោក មាស មុត មិនមែនជា

---

[330] *សូមមើល* កថាខណ្ឌ ៨ *ខាងលើ*។

[331] កថាខណ្ឌ ១៨៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៥៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[332] កថាខណ្ឌ ១៦៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[333] កថាខណ្ឌ ៤១៦-២០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៤៥៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ស.ច.ស.អ. បានពិចារណាថា លោក មាស មុត បានកាន់កាប់តំណែងជាន់ខ្ពស់នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ ពីព្រោះគាត់ជាមេបញ្ជាការកងពលលេខ ១៦៤ ទទួលខុសត្រូវចំពោះបូរណភាពដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ជាសមាជិកបម្រុងនៃគណៈកម្មាធិការអគ្គសេនាធិការដ្ឋាន និង ជាអនុប្រធានមួយរូបក្នុងចំណោមអនុប្រធានរបស់ សុន សេន ហើយចាប់ពីចុងឆ្នាំ ១៩៧៨ មក គឺជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម។

សមាជិកនៃគណៈកម្មាធិការសេនាធិការ ហើយថា បើទុកជាលោក មាស មុត បានក្លាយជាសមាជិក ឬ អនុប្រធានគណៈកម្មាធិការសេនាធិការ នៅឆ្នាំ ១៩៧៨ ក្តី ក៏តំណែងរបស់គាត់បានត្រឹមតែរយៈពេលចំនួន ៥០ ថ្ងៃប៉ុណ្ណោះ[334]។ ស.ច.ស.ជ. មិនមានកំហុសនៅក្នុងការសម្រេចនេះឡើយ។ បើទោះបីជា ស.ច.ស.ជ. មានកំហុសក្នុងការសម្រេចនេះក៏ដោយ ក៏ ស.ព.អ. ខកខាន មិនបានបង្ហាញថា កំហុសនេះ គឺជាកត្តាកំណត់ជាមូលដ្ឋានទៅលើការកំណត់យុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ. ដោយរបៀបណាដែរ។

៨០. ស.ច.ស.ជ. បានពិចារណាលើភ័ស្តុតាងដែលបង្ហាញថា លោក មាស មុត *អាច* ត្រូវបានតែងតាំងជា *ជំនួយការ* នយោបាយនៃសេនាធិការនៅក្នុងសន្និបាតបក្សឆ្នាំ ១៩៧៥ ដែលនៅពេលនោះ សុន សេន ត្រូវចាត់តាំងឱ្យបង្កើតកងទ័ពជើងទឹក និង កងទ័ពអាកាស[335]។ ដោយផ្អែកលើឯកសាររបបកម្ពុជាប្រជាធិបតេយ្យមួយ ដែលចេញនៅត្រឹមតែរយៈពេលចំនួន ២ ខែ មុនពេលរបបនោះដួលរលំ (សន្និបាតបក្សលើកទី ៥ ដែលបង្ហាញសមាសភាពសេនាធិការ នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨ និង ដែលមិនមានរាយឈ្មោះលោក មាស មុត[336] ផងនោះ) ស.ច.ស.ជ. បានសន្និដ្ឋានថា មាន "វិមតិសង្ស័យច្រើន" ទាក់ទងនឹងសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការសេនាធិការ[337]។ ផ្អែកលើវិមតិសង្ស័យនេះ និង អវត្តមាននៃភ័ស្តុតាងផ្ទុយដែលគួរឱ្យជឿជាក់បាន ស.ច.ស.ជ. បានអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ*[338] នៅក្នុងការសន្និដ្ឋានថា លោក មាស មុត មិនមែនជាសមាជិកនៃគណៈកម្មាធិការសេនាធិការ[339]។

៨១. ស.ច.ស.ជ. ក៏ដូចជា ស.ច.ស.អ. ដែរ គឺពឹងផ្អែកលើសក្ខីកម្មរបស់ ឌុច ដែលថា លោក មាស មុត អាចបានក្លាយជាអនុប្រធានសេនាធិការក្នុងឆ្នាំ ១៩៧៨[340]។ ខណៈដែល ស.ច.ស.អ. បានរកឃើញ

[334] កថាខណ្ឌ ១៤២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ១៦៣, ៤១៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[335] កថាខណ្ឌ ១៦២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[336] កថាខណ្ឌ ១៦៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[337] កថាខណ្ឌ ១៦៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[338] *សូមមើល* ជើងទំព័រ ៧៤ *ខាងលើ* ។

[339] កថាខណ្ឌ ១៦៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[340] កថាខណ្ឌ ១៦៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៦២ ជើងទំព័រ ៣៣៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ថា លោក មាស មុត ក៏ជាអនុប្រធានរបស់ សុន សេន ផងដែរចាប់ពីការបង្កើតកងទ័ពជើងទឹក[341] ស.ច.ស.អ. មិនបានរកឃើញអំពីសិទ្ធិអំណាចរបស់គាត់នៅក្នុងតំណែងនេះឡើយ ក្រៅតែពីរកឃើញថា លោក មាស មុត *"ត្រូវបាន សុន សេន ចាត់តាំង"* ឱ្យធ្វើប្រតិបត្តិការឃោធាជាក់លាក់សម្រាប់សេនាធិការ[342]។ បើទោះបីជា លោក មាស មុត ជាសមាជិក ឬ អនុប្រធានគណៈកម្មាធិការសេនាធិការក្នុងឆ្នាំ ១៩៧៨ ក៏ដោយ ក៏ ស.ព.អ. ខកខានមិនបានបង្ហាញថា តើការកាន់តំណែងខ្ពស់ក្នុងរយៈពេលចំនួន ៥០ ថ្ងៃ មានឥទ្ធិពលយ៉ាងដូចម្ដេចទៅលើការកំណត់យុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ.។ ការទទួលបានតំណែងខ្ពស់មួយក្នុងរយៈពេលចំនួន ៥០ ថ្ងៃ ក្នុងអំឡុងពេលវឹកវរធ្ងន់ធ្ងរ ខណៈដែលរបបនោះហៀបនឹងដួលរលំ មិនមែនជាការបង្ហាញថា មានសិទ្ធិអំណាចកម្រិតខ្ពស់ឡើយ[343]។

៨២. ***ស.ច.ស.ជ. មិនមានកំហុសអង្គហេតុនៅក្នុងការរកឃើញថា លោក មាស មុត មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម*** ស.ព.អ. ខកខានមិនបានបង្ហាញសំអាងគាំទ្រការអះអាងរបស់ខ្លួនដែលថា ស.ច.ស.ជ. មានកំហុសអង្គហេតុក្នុងការរកឃើញថា លោក មាស មុត គឺជា *ជំនួយការ* គណៈកម្មាធិការមជ្ឈិម ដែលគ្មានសិទ្ធិបោះឆ្នោត ឬ ចូលរួមនៅក្នុងគណៈកម្មាធិការមជ្ឈិម[344] ដោយផ្ដល់ទឡ្ហីករណ៍ថា ស.ច.ស.ជ. មិនបានផ្អែកលើចម្លើយរបស់ ខៀវ សំផន[345] ដោយមិនបានពន្យល់ថាហេតុអ្វីបានជា ការរកឃើញរបស់ ស.ច.ស.ជ. មិនអាចឈរលើមូលដ្ឋាននៃភ័ស្តុតាងផ្សេងទៀត[346]។ ដូចដែល ស.ព.អ. ទទួលស្គាល់ គេសន្មតថា ស.ច.ស. បានវាយតម្លៃយ៉ាងត្រឹមត្រូវលើភ័ស្តុតាងទាំង

---

[341] កថាខណ្ឌ ១៦២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[342] កថាខណ្ឌ ១៦៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ការគូសបញ្ជាក់បន្ថែម)។

[343] *សូមមើល* កថាខណ្ឌ ៣១៦ នៃដីកាដំណោះស្រាយរឿងក្ដី ០០៤/១។

[344] កថាខណ្ឌ ១៤៨ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ១០៨-១៥, ១១៧-២២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[345] កថាខណ្ឌ ១៤៨-៤៩ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[346] *សូមមើល* កថាខណ្ឌ ៩០ នៃសាលដីកាលើរឿងក្ដី ០០២/០១ ដែលដកស្រង់ *ក្នុងចំណោមនោះ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Strugar* សំណុំរឿងលេខ IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ២១-២២។ *សូមមើល ផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

អស់[347] ហើយ ស.ច.ស. មាន “ឆន្ទានុសិទ្ធិសម្រេចថាភស្តុតាងណាខ្លះ មានភាពគួរឱ្យជឿជាក់បានជាងភស្តុតាងផ្សេងទៀត”[348]។ អាស្រ័យហេតុនេះ អ.ប.ជ. គួរបដិសេធការអះអាងនេះភ្លាមៗ។

៨៣. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា សមាជិកភាពរបស់លោក មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម “ត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយប្រភពដែលគួរឱ្យជឿជាក់បំផុត ចំពោះបញ្ហាមួយនេះ” គឺ ខៀវ សំផន[349]។ ខៀវ សំផន ថ្លែងដោយស្មាក់ស្មើរថា មេបញ្ជាការកងពលធំនោះរួមទាំងលោក មាស មុត ផង គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម[350] ដោយមិនបានបង្ហាញថា តើដោយរបៀបណា ឬ នៅពេលណាដែលគាត់បានដឹងរឿងនេះ តើសមាជិកភាពនេះនាំមកនូវអ្វីខ្លះ ឬ អំពីកម្រិតដែលលោក មាស មុត អាចចូលរួមនៅក្នុងការពិភាក្សា ឬ ធ្វើសេចក្តីសម្រេចនៅក្នុងគណៈកម្មាធិការនោះ។

៨៤. ស.ច.ស. ទាំងពីរពឹងផ្អែកលើ ឌុច ជាជាង ខៀវ សំផន ក្នុងការសម្រេចថា លោក មាស មុត គឺជាជំនួយការគណៈកម្មាធិការមជ្ឈិម ស្ថិតក្នុងលំដាប់ទី ៤ នៃ ប.ក.ក.[351]។ ឌុច បានរក្សាជំហរដដែល

---

[347] កថាខណ្ឌ ១៣៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៣០៤ នៃសាលដីកាលើរឿងក្តី ០០២/០១។

[348] កថាខណ្ឌ ១៣៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Muvuny* សំណុំរឿងលេខ ICTR-2000-55A-A សាលដីកា ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១១៤។

[349] កថាខណ្ឌ ១៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[350] កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 ERN 00156619។

[351] កថាខណ្ឌ ១១ ជើងទំព័រ ២៩៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ (ដែលដកស្រង់កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7។ កំណត់ហេតុនៃការស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ D1.3.33.13។ កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០២ ឯកសារ D4.1.948។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12) កថាខណ្ឌ ១១៧ ជើងទំព័រ ៣១២ (ដែលដកស្រង់កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7។ កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13។ រឿងក្តី កាំង ហ្កេកអ៊ាវ សំណុំរឿងលេខ 001/18-07-2007-ECCC/TC ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៩ E1/29.1 ERN 00339538។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12)។ កថាខណ្ឌ ១៥០ ជើងទំព័រ ២៩៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលដកស្រង់កំណត់ហេតុនៃការស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ D1.3.33.10។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/158។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159) ជើងទំព័រ ២៩៦ (ដែលដកស្រង់

ចាប់តាំងពីត្រូវបានឃុំខ្លួននៅតុលាការយោធាកម្ពុជា ក្នុងឆ្នាំ ១៩៩៩[352] ថា លោក មាស មុត ធ្លាប់ត្រឹមតែជាជំនួយការនៃគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ[353]។ ជាពិសេស ឌុច បានរក្សាជំហរថាជំនួយការអាចត្រឹមតែចូលរួមប្រជុំគណៈកម្មាធិការមជ្ឈិម ទទួលការណែនាំ និង មិនមានសិទ្ធិចូលរួម ឬ បោះឆ្នោតឡើយ[354]។ ឌុច បានបញ្ជាក់ច្បាស់អំពីប្រភពនៃការដឹងរបស់គាត់៖ គាត់ត្រូវបានតាមឃ្លាំមើលជានិច្ចជាកាល ដោយជំនួយការម្នាក់នៃគណៈកម្មាធិការមជ្ឈិម ឈឹម សំអោក (ហៅ ប៉ង់) ដែល "ស្ថិតក្នុងលំដាប់លេខ ១ ក្នុងចំណោមជំនួយការមជ្ឈិមបក្ស"[355]។ ស.ព.អ. ខកខានមិនបានបង្ហាញថាតើភ័ស្តុតាងណាមួយដែលបន្ថែមទៅក្នុងសំណុំរឿងនៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ អាចផ្លាស់ប្តូរការរកឃើញរបស់ ស.ច.ស.ជ. ដោយរបៀបណា។ កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច នៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ត្រឹមតែបញ្ជាក់ចម្លើយរបស់គាត់នៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ទាក់ទងនឹងតំណែងរបស់លោក មាស មុត ជាជំនួយការគណៈកម្មាធិការមជ្ឈិម និង សិទ្ធិអំណាចមានកម្រិតរបស់ជំនួយការប៉ុណ្ណោះ[356]។

៨៥. ស.ព.អ. ធ្វើឱ្យច្របូកច្របល់ ដោយអះអាងថា ស.ច.ស.ជ. គ្មាន "ហេតុផលសត្យានុម័ត" ឡើយក្នុងការមិនពឹងផ្អែកលើ ខៀវ សំផន ក្នុងការកំណត់សមាជិកភាពរបស់លោក មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិមនោះ នៅពេលដែល ស.ច.ស.ជ. បានធ្វើដូច្នេះសម្រាប់សមាជិកផ្សេងទៀត

---

កំណត់ហេតុសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២00៧ ឯកសារ D1.3.33.13។ កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២00៧ ឯកសារ D1.3.33.11)។

[352] តុលាការយោធា កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 ERN 00089675។

[353] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២00៧ ឯកសារ D1.3.33.13 ERN 00154927។

[354] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២00៨ ឯកសារ D4.1.1119។ កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២00៧ ឯកសារ D1.3.33.11។ កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២00៧ ឯកសារ D1.3.33.13 ERN 00154927។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ 001/18-07-2007/ECCC-TC សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយរបស់ជនត្រូវចោទ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២00៩ ឯកសារ D10.1.64 កថាខណ្ឌ ៥៧។ *រឿងក្តី កាំង ហ្គេកអ៊ាវ* ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២00៩ E1/29.1 ERN 00339538។

[355] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២00៧ ឯកសារ D1.3.33.3 ERN 00146481។

[356] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/158 ឆ.៣២, ឆ.៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ឯកសារ D114/159 ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឆ.១០។

នៃគណៈកម្មាធិការមជ្ឈិម[357]។ ខណៈដែល ខៀវ សំផន អាចថាគួរឱ្យជឿជាក់បាន ឬ អាចបញ្ជាក់ជាភ័ស្តុតាងបន្ថែមទាក់ទងនឹងបុគ្គលផ្សេងទៀត ការអះអាងរបស់ ខៀវ សំផន ទាក់ទងនឹង មាស មុត មិនត្រូវបានគាំទ្រដោយភ័ស្តុតាងផ្សេងទៀតឡើយ[358]។ ការណ៍ដែលមិនមាន "បញ្ជីឈ្មោះនៃសមាជិកទាំងអស់របស់គណៈកម្មាធិការមជ្ឈិម" ដែលនៅសល់[359] មិនអាចបកស្រាយឱ្យខូចប្រយោជន៍ដល់លោក មាស មុត ឡើយ តាមគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* នោះ[360]។ "ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់ៗខ្លះ... អាចបាត់បង់... គឺពុំមែនជាការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តី នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬ នាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬ ការផ្តន្ទាទោសនោះឡើយ"[361]។

៨៦. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ស.ច.ស.ជ. បានសង្កត់ធ្ងន់ហួសហេតុលើការបដិសេធរបស់លោក មាស មុត ថាខ្លួនមិនមែនជាសមាជិកនៅក្នុងគណៈកម្មាធិការមជ្ឈិម ដើម្បីបង្រួមតួនាទីរបស់គាត់ឱ្យនៅតូចបំផុត[362]។ ស.ច.ស.ជ. បានពិចារណាលើចម្លើយរបស់លោក មាស មុត ជាមួយនឹងសក្ខីកម្មផ្ទុយរបស់ ឌុច ខៀវ សំផន និង សាក្សីផ្សេងទៀត[363] រចនាសម្ព័ន្ធរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ[364] និង ការពិនិត្យលើភ័ស្តុតាងឯកសារ ដែលបង្ហាញពីសមាសភាពនៃគណៈកម្មាធិការមជ្ឈិម[365]។

---

[357] កថាខណ្ឌ ១៤៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[358] មិនមានកំណត់ហេតុនៃប្រជុំគណៈកម្មាធិការមជ្ឈិម ឬ ឯកសារដទៃទៀតរបស់បក្សបង្ហាញថា មាស មុត ជាសមាជិកនៃគណៈកម្មាធិការនេះ ឬ ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយទេ។

[359] កថាខណ្ឌ ១៥០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[360] *សូមមើល* ជើងទំព័រ ៧៤ *ខាងលើ* ។

[361] កថាខណ្ឌ ៣៦ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១ ។

[362] កថាខណ្ឌ ១៥០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[363] កថាខណ្ឌ ១១១, ១១៣, ១១៥, ១១៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *ជាពិសេស សូមមើល* កថាខណ្ឌ ១១៥ ជើងទំព័រ ៣១០ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[364] កថាខណ្ឌ ១១៦, ១២១ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *ជាពិសេស សូមមើល* កថាខណ្ឌ ១១៦ ជើងទំព័រ ៣១១, កថាខណ្ឌ ១១៩ ជើងទំព័រ ៣២២ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[365] កថាខណ្ឌ ១១៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

៨៧. ស.ព.អ. បកស្រាយខុសនូវដីកាដំណោះស្រាយរឿងក្ដី ០០២ ដោយអះអាងដោយមិនសមហេតុផលថា អៀង ធីរិទ្ធ មានឋានៈទាបជាងលោក មាស មុត នៅក្នុងឋានានុក្រម ប.ក.ក. ពីព្រោះ អៀង ធីរិទ្ធ មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម[366]។ ខណៈដែល ស.ច.ស. បានរកឃើញថា អៀង ធីរិទ្ធ មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ ឬ គណៈមជ្ឈិម[367] ស.ច.ស.ជ. និង ស.ច.ស.អ. Lemonde បានរកឃើញថា អៀង ធីរិទ្ធ គឺជាមេដឹកនាំជាន់ខ្ពស់ ឬ ជាជម្រើសម្យ៉ាងទៀត គឺជាជនដែលទទួលខុសត្រូវខ្ពស់បំផុត[368] ដោយផ្អែកលើសិទ្ធិអំណាចដ៏ធំដែលគាត់មាននៅក្នុងតំណែងរបស់គាត់ជារដ្ឋមន្ត្រីសង្គមកិច្ច[369] និង ទទួលបន្ទុកវប្បធម៌ សង្គមកិច្ច និង កិច្ចការបរទេស[370] ការចូលរួមរបស់គាត់ "ពេញមួយរបបនេះ នៅក្នុងសកម្មភាពរបស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក"[371] អំពើ និង ការចូលរួមរបស់ អៀង ធីរិទ្ធ ក្នុងគោលនយោបាយ ប.ក.ក.[372] និង ជាពិសេស ការចូលរួមរបស់ អៀង ធីរិទ្ធ នៅក្នុង *ការបង្កើត* គោលនយោបាយរបស់ ប.ក.ក.[373]។

៨៨. *ជារួម* ស.ច.ស.ជ. បានវាយតម្លៃយ៉ាងត្រឹមត្រូវលើតំណែងរបស់លោក មាស មុត នៅក្នុងការកំណត់យុត្តាធិការបុគ្គល។ ដោយខកខានមិនបានផ្ដល់ភ័ស្តុតាងគាំទ្រការអះអាងរបស់ខ្លួនដែលថា ការខកខានណាមួយមិនបានពិចារណាលើភ័ស្តុតាង បានជះឥទ្ធិពលលើការសម្រេចលើអង្គហេតុរបស់ ស.ច.ស.ជ. ដែល ស.ច.ស.ជ. ធ្វើសេចក្ដីសម្រេចលើអង្គហេតុណាមួយ ដែលគ្មាន ស.ច.ស. សមហេតុផលណាម្នាក់សម្រេចដូច្នេះ ឬ ដែលការសម្រេចរបស់ ស.ច.ស.ជ. លើតំណែងរបស់

[366] កថាខណ្ឌ ១៥៣ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[367] កថាខណ្ឌ ១២០៧ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[368] កថាខណ្ឌ ១៣២៧ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[369] កថាខណ្ឌ ១២០៩-២១ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[370] កថាខណ្ឌ ១២២២-២៣ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[371] កថាខណ្ឌ ១២២៦ នៃដីកាដំណោះស្រាយរឿងក្ដី ០០២។

[372] កថាខណ្ឌ ១២២៧-៣៤ នៃដីកាដំណោះស្រាយរឿងក្ដី ០០២ (ការផ្លាស់ទីលំនៅប្រជាជន), កថាខណ្ឌ ១២៣៥-៤៦ (ការបង្កើតការដ្ឋាន និងសហករណ៍), កថាខណ្ឌ ១២៤៧-៨៧ (ការអប់រំកែប្រែសមាសភាពអាក្រក់ និង សម្លាប់ខ្មាំង), កថាខណ្ឌ ១២៨៨-៩២ (ការកំណត់គោលដៅចំពោះក្រុមមនុស្សជាក់លាក់), កថាខណ្ឌ ១២៩៣-៩៥ (បទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍)។

[373] កថាខណ្ឌ ១២៣៦-៣៩ នៃដីកាដំណោះស្រាយរឿងក្ដី ០០២ (យល់ឃើញថា អៀង ធីរិទ្ធ "បានជួយរៀបចំផែនការ" ស្ដីពីគោលនយោបាយរបស់ ប.ក.ក. ក្នុងការបង្កើតសហករណ៍ និង ការដ្ឋាននានា តាមរយៈតួនាទីរបស់គាត់នៅក្នុងគណៈរដ្ឋមន្ត្រី និង ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច), កថាខណ្ឌ ១២៤៨-៥០ (យល់ឃើញថា អៀង ធីរិទ្ធ "បានជួយរៀបចំផែនការ" ស្ដីពីគោលនយោបាយរបស់ ប.ក.ក. នៅក្នុងការអប់រំកែប្រែ "សមាភាពអាក្រក់" និង សម្លាប់ "ខ្មាំង" ទាំងខាងក្នុងជួរ និង ខាងក្រៅជួរបក្ស)។

លោក មាស មុត មិនមានភាពយុត្តិធម៌ ឬ មិនសមហេតុផល ដែលបង្កើតបានជាការបំពានឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុសអង្គហេតុ ឬ ការបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិ ជារួម ឬ ដោយឡែក ដោយរបៀបណា។ គួរច្រានចោល មូលដ្ឋាន "ច" ។

ឆ. ចម្លើយតបទៅនឹងមូលដ្ឋាន "ឆ"៖ ស.ច.ស.ជ. មិនមានកំហុសអង្គហេតុនៅក្នុងការ**ពិចារណា**របស់ខ្លួនលើជនរងគ្រោះ

៨៩. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ស.ច.ស.ជ. បានធ្វើការសម្រេចលើអង្គហេតុដោយមានកំហុស ដែលនាំឱ្យគាត់វាយតម្លៃទាបខ្លាំង ទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម[374] ពីព្រោះគាត់បានខកខានមិនបានពិចារណាលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ធ្វើសេចក្តីសម្រេចដែលតម្រូវឱ្យមាន និង កំណត់ប្រភេទបទចោទតាមច្បាប់[375]។ ស.ច.ស.ជ. បានពិចារណាយ៉ាងត្រឹមត្រូវលើជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅក្នុងការវិភាគយុត្តាធិការបុគ្គលរបស់ខ្លួន។ ខណៈដែលភស្តុតាងមុន និង ក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដែល ស.ព.អ. អះអាងថា ស.ច.ស.ជ. មិនបានពិចារណានោះ អាចបានបន្ថែមទីតាំងឧក្រិដ្ឋកម្ម និង ជនរងគ្រោះនៃឧក្រិដ្ឋកម្មថែមទៀត[376] ចំនួនជនរងគ្រោះត្រូវតែបានពិចារណាដោយផ្អែក "ទៅលើបរិបទនៃព្យសនកម្មទាំងអស់ ដែលបណ្តាលមកពីការអនុវត្តគោលនយោបាយរបស់របបនេះ"[377] ហើយការកំណត់ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម តម្រូវឱ្យមាន "ការពិចារណាលើកាលៈទេសៈពិសេសនៃរឿងក្តី ព្រមទាំងទម្រង់ និង កម្រិតនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនោះ"[378]។

[374] កថាខណ្ឌ ១៥៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[375] កថាខណ្ឌ ៥៨-៦២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (មូលដ្ឋាន ខ), កថាខណ្ឌ ២៦-៣៤ (មូលដ្ឋាន ក), កថាខណ្ឌ ៧០-៨២ (មូលដ្ឋាន គ)។

[376] *សូមមើល* កថាខណ្ឌ ១៥៦, ១៥៨-៧០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[377] កថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[378] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៣៤៩។ *សូមមើល ផងដែរ* កថាខណ្ឌ ១១០៧ នៃសាលដីកាលើរឿងក្តី ០០២/០១។ កថាខណ្ឌ ៥៩៦ នៃសាលក្រមលើរឿងក្តី ០០១។ កថាខណ្ឌ ១០៧៣ នៃសាលក្រមសំណុំរឿង ០០២/០១។

៩0. ស.ព.អ. នាំឱ្យយល់ខុស ដោយអះអាងថា ស.ច.ស.ជ. បានសន្និដ្ឋានថា "ចំនួនជនរងគ្រោះនៃអំពើផ្ទាល់របស់ មាស មុត មានភាពខុសគ្នាឆ្ងាយណាស់ រវាងផលវិបាកនៃអំពើផ្ទាល់នៃទង្វើរបស់ឌុច" ពីព្រោះគាត់មិនបានពិចារណាលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ធ្វើការសម្រេចដែលតម្រូវឱ្យមាន និង កំណត់ប្រភេទបទចោទតាមច្បាប់[379]។ ស.ច.ស.ជ. បានធ្វើការសម្រេចលើអង្គហេតុដែលតម្រូវ និង មិនត្រូវបានតម្រូវឱ្យកំណត់ប្រភេទបទចោទឡើយ[380]។ ពាក្យថា "អំពើដោយផ្ទាល់" នៅក្នុងសំអាងហេតុរបស់ ស.ច.ស.ជ. បង្ហាញថា គាត់បានពិចារណាលើអានុភាពនៃ *អំពើ និង ទង្វើជាមូលដ្ឋាន*របស់ ឌុច ដោយប្រៀបធៀបទៅនឹងអំពើ និង ទង្វើជាមូលដ្ឋានរបស់លោក មាស មុត[381] ដែល ស.ច.ស.ជ. បានរកឃើញថា "មិនសកម្ម មិនជុំកំភួន និង មិនកៀកកិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[382]។ បើទោះបីជា ស.ច.ស.ជ. រកឃើញថា អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមបានកើតឡើងនៅតាមបណ្តាតំបន់ក្រោមសិទ្ធិអំណាចរបស់លោក មាស មុត ក៏ដោយ[383] ក៏ប្រការនេះ មិនអាចផ្លាស់ប្តូរការវិភាគរបស់គាត់លើស្ថានទម្ងន់ដែរ បើគិតពីការផ្តោតរបស់គាត់ទៅលើអំពើ និង ទង្វើ ជាមូលដ្ឋានរបស់លោក មាស មុត នោះ[384]។

៩១. អ.ប.ជ. គួរតែច្រានចោលភ្លាមៗនូវចំនួនជនរងគ្រោះដែល ស.ព.អ. លើកឡើងសាជាថ្មីពីដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[385] ដែលមិនត្រូវបានទទួលយកដោយ ស.ច.ស. ណាម្នាក់[386]។ ស.ច.ស.អ. ដែលជាអ្នករកឃើញថាលោក មាស មុត ជាជនទទួលខុសត្រូវខ្ពស់បំផុត[387] បានទទួលស្គាល់ថា

[379] កថាខណ្ឌ ១៥៥ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៤២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[380] *សូមមើល* កថាខណ្ឌ ៤៥-៥៤ *ខាងលើ*។

[381] *សូមមើល* កថាខណ្ឌ ៣៧១-៧៤, ៤២៧-២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[382] *សូមមើល* កថាខណ្ឌ ៤២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[383] *សូមមើល* កថាខណ្ឌ ៦០-៦២ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[384] កថាខណ្ឌ ៤២១-២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[385] *សូមមើល* កថាខណ្ឌ ១៦៣-៦៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ), កថាខណ្ឌ ១៦៥-៦៦ (ស្ទឹងហាវ), កថាខណ្ឌ ១៦៧-៨ (វត្តឥន្ទញាណ), កថាខណ្ឌ ១៦៩-៧០ (មន្ទីរសន្តិសុខ ស-២១) ដែលដកស្រង់ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ.។

[386] *សូមមើល* កថាខណ្ឌ ២០ នៃសាលដីកាលើរឿងក្តី 00១។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Stanišić* *និង* *Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២0១៥ កថាខណ្ឌ ២២។ គួរឱ្យកត់សម្គាល់ ស.ព.អ. ដកស្រង់តែចំនួនជនរងគ្រោះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងចំនួនពលករនៅការដ្ឋានតំបន់រាមប៉ុណ្ណោះ។ *សូមមើល* កថាខណ្ឌ ១៥៨ ជើងទំព័រ ៦៣៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[387] កថាខណ្ឌ ៤៥៦, ៤៦0 នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ការគណនារបស់គាត់ គឺគ្រាន់តែជាការប៉ាន់ប្រមាណប៉ុណ្ណោះ ដោយមិនអាចគណនាចំនួនជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅក្នុងកម្រិតជាក់លាក់ឡើយ[388]។

ក. *ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ* ស.ច.ស.អ. បានទទួលស្គាល់ថា “ការប៉ាន់ស្មានដែលផ្តល់ដោយអតីតសមាជិកកងពលធំ ១៦៤ ត្រឹមបានកម្រិតដោយពេលវេលា និង ទីតាំងខ្លះៗនៃកន្លែងបំពេញការងារខ្លួន” និង ថា ការព្យាយាមស្វែងរកកិច្ចសហការពីសំណាក់ប្រទេសវៀតណាម និង ប្រទេសថៃ នៅក្នុងការកំណត់ចំនួនជនរងគ្រោះ គឺទទួលបរាជ័យ[389]។

ខ. *ចម្ការក្ងួរវេន* ស.ច.ស.អ. បានរកឃើញថា “មិនមានការបំភ្លឺដោយសាក្សីដែលបានឃើញផ្ទាល់ភ្នែក ចំពោះព្រឹត្តិការណ៍ជាក់ស្តែងនៃការសម្លាប់ទេ” និង ថា ភ័ស្តុតាងទាំងអស់គឺជា “ការនិយាយតគ្នាមួយ ឬ និយាយតគ្នា ពីរតក៏មាន”[390]។

គ. *ការបោសសម្អាតកងពលធំ ១៦៤ កងពលធំ ១១៧ កងពលធំ ៥០២ និង កងពលធំ ៣១០* ស.ច.ស.អ. មិនបានរកឃើញចំនួនជនរងគ្រោះដែលលើកឡើងដោយ ស.ព.អ.[391] ឬ ដាក់លោក មាស មុត ឱ្យទទួលខុសត្រូវចំពោះសមាជិក *ទាំងអស់* នៃកងពលមជ្ឈិម កងវរសេនាធំឯករាជ្យ និង បុគ្គលិកសេនាធិការនៃ ក.ប.ក. ឡើយ[392]។

---

[388] កថាខណ្ឌ ៣៤១, ៤២៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[389] កថាខណ្ឌ ២៤៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[390] កថាខណ្ឌ ២៦៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[391] *សូមមើល* កថាខណ្ឌ ៧៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៥៥០-៥១, ៨៦១, ៨៦៨-៦៩ នៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ. (ដែលចោទប្រកាន់ថា ជនរងគ្រោះ ៣២ នាក់ មកពីកងពលធំ ១១៧ និង តំបន់ ៥០៥ ត្រូវបានបោសសម្អាត និង សម្លាប់នៅ ស-២១), កថាខណ្ឌ ៨០ ដែលដកស្រង់កថាខណ្ឌ ១៧២, ៥៥២ នៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ. (ដែលចោទប្រកាន់ថា កម្មាភិបាលចំនួន ៣៥៧ នាក់ មកពីកងពលធំ ៥០២ និងចំនួន ១.១១៧ នាក់ មកពីកងពលធំ ៣១០ ត្រូវបានបញ្ជូនទៅ ស-២១), កថាខណ្ឌ ៨១ ដែលដកស្រង់កថាខណ្ឌ ១៧២, ៥៥២ នៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ. (ដែលចោទប្រកាន់ថា បន្ថែមលើកងពលធំ ១៦៤, ១១៧, ៥០២ និង កងពលធំ ៣១០ លោក មាស មុត ក៏គួរទទួលខុសត្រូវផងដែរចំពោះកម្មាភិបាល ក.ប.ក. ចំនួន ៣.៣៣០ នាក់ផ្សេងទៀត ដែលបានបញ្ជូនទៅ ស-២១)។ *ប្រៀបធៀប* កថាខណ្ឌ ៤៦៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលយល់ឃើញថា កម្មាភិបាលកងពលធំ ១៦៤ ចំនួន ៧១៩ នាក់, កម្មាភិបាលកងពលធំ ៥០២ ចំនួន ៤៧៨, កម្មាភិបាលកងពលធំ ៣១០ ចំនួន ៩២៨ នាក់ និងកម្មាភិបាលកងពលធំ ១១៧ ចំនួន ២៧ នាក់ ត្រូវបានបញ្ជូនទៅ ស-២១ ក្នុងអំឡុងពេលបោសសម្អាតនេះ)។

[392] កថាខណ្ឌ ១៧០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ កថាខណ្ឌ ៤៦៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ឃ. *ការដ្ឋានតំបន់រាម* ស.ច.ស.អ. បានរកឃើញថា "មិនអាចកំណត់ចំនួនកម្មករពិតប្រាកដបានទេ" ដោយសារថា ការដ្ឋានទាំងនេះបានដំណើរការនៅពេលផ្សេងគ្នា ចំនួនកម្មករតែងតែប្រែប្រួលជានិច្ច និង "មិនអាចកំណត់ពីទីតាំង និង ព្រំដែនការដ្ឋានពិតប្រាកដ... ដែលសាក្សីនានាបានលើកឡើង ហើយជារឿយៗប្រាប់ពីចំនួនការដ្ឋាន ឬកងរបស់ខ្លួន តែមិនប្រាប់ពីទីតាំងទេ"[393]។

ង. *ស្ទឹងហាវ* ស.ច.ស.អ. បានរកឃើញថា ការរៀបរាប់របស់សាក្សីអំពីព្រឹត្តិការណ៍ដំណើររឿង "មិនមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីអាចទាញសេចក្តីសន្និដ្ឋានសមស្របបានឡើយ" និង ថា ដូច្នេះ "គេមិនអាចសន្និដ្ឋានជាក់លាក់ពីចំនួនមនុស្សដែលធ្វើការ" នៅការដ្ឋាននោះបានឡើយ[394]។

ច. *ទឹកសាប* ស.ច.ស.អ. បានរកឃើញថា "យើងមិនអាចកំណត់ចំនួនប្រាកដនៃអ្នកជាប់ឃុំខ្លួននៅទឹកសាបបានទេ"[395]។ នៅពេលដែលអ្នកស៊ើបអង្កេតសិក្សាទីតាំងនៃរណ្តៅកប់សពនៅទឹកសាប ក្នុងឆ្នាំ ២០១៥ ទីតាំងនោះត្រូវបានឈូសឆាយ ហើយអ្នកស៊ើបអង្កេតមិនអាចរកឃើញសាកសពមនុស្ស ឬ អ្វីដែលបញ្ជាក់អំពីរណ្តៅសពនៅទីនោះទេ[396]។

ឆ. *វត្តឥន្ទញាណ* ស.ច.ស.អ. បានរកឃើញថា "មិនមានភ័ស្តុតាងពីសាក្សីផ្ទាល់ភ្នែកបញ្ជាក់ពីការសម្លាប់មនុស្សនៅទីតាំងនេះនៅសម័យកម្ពុជាប្រជាធិបតេយ្យទេ"[397] មិនមានភាពស៊ីសង្វាក់គ្នានៅក្នុងភ័ស្តុតាងទាក់ទងនឹងសាកសពដែលបានរកឃើញនៅទីតាំងនោះ នៅពាក់កណ្តាលឆ្នាំ ១៩៧៩ ឡើយ[398] និង ថាភាពត្រឹមត្រូវនៃការគណនាចំនួនសាកសពដោយសាក្សីនៅទីតាំងនោះ "អាចមានមន្ទិល"[399]។

ជ. *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ស.ច.ស.អ. មិនបានគណនាចំនួនជនរងគ្រោះ និង បានកត់សម្គាល់ថា "សក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែកអំពីការរៀបការដោយបង្ខំនៅកំពង់សោម ពុំមានច្រើន"[400]។

---

[393] កថាខណ្ឌ ៣៤១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[394] កថាខណ្ឌ ៣៦៨, ៣៧០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[395] កថាខណ្ឌ ៤១៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[396] កថាខណ្ឌ ៤២៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[397] កថាខណ្ឌ ៤៣៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[398] កថាខណ្ឌ ៤៤០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[399] កថាខណ្ឌ ៤៤១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[400] កថាខណ្ឌ ៤៥០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៩២. *ជារួម* ស.ច.ស.ជ. បានពិចារណាយ៉ាងត្រឹមត្រូវ លើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ដោយផ្អែកលើអំពើ និង ទង្វើជាមូលដ្ឋានរបស់លោក មាស មុត[401]។ បើទោះបីជា អ.ប.ជ. ត្រូវអនុវត្តតាមកត្តាបញ្ជូន មិនពាក់ព័ន្ធរបស់សាលាក្តី ICTY ដែល ស.ព.អ. ស្នើឡើង ដើម្បីកំណត់កម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ក៏ដោយ[402] ក៏យុត្តិសាស្ត្រដែលយោង គាំទ្រការវិភាគរបស់ ស.ច.ស.ជ. ដែរ[403]។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់សាលាក្តី ICTY បានយល់ឃើញថា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មមិនរារាំងការបញ្ជូនឡើយ បើទោះជាជនជាប់ចោទត្រូវបានចោទពីបទចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមពីរដាច់ដោយឡែកពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក៏ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ[404] ពីព្រោះ "មិនមានឋានានុក្រមជាប់មកជាមួយ នៅក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយដែលសាលាក្តីមានយុត្តាធិការនោះទេ។ ផ្ទុយមកវិញ អង្គជំនុំជម្រះត្រូវពិនិត្យមើលទង្វើជាមូលដ្ឋានដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្ម ក៏ដូចជាកាលៈទេសៈជុំវិញ ដើម្បីកំណត់អំពីស្ថានទម្ងន់របស់ឧក្រិដ្ឋកម្មនោះ"[405]។ ដោយខកខានមិនបានបង្ហាញថា ស.ច.ស.ជ. បានធ្វើការសម្រេចលើអង្គហេតុ ដែលគ្មាន ស.ច.ស. ដែលមានហេតុផលណាធ្វើដូច្នេះ ឬ ការពិចារណារបស់ ស.ច.ស.ជ. លើអំពើ និង ទង្វើជាមូលដ្ឋានរបស់លោក មាស មុត ក្នុងការវាយតម្លៃលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម មិនមានភាពយុត្តិធម៌ ឬ មិនសមហេតុផល ដែលនាំឱ្យមានការបំពានឆន្ទានុសិទ្ធិ ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញ ថាតើ ស.ច.ស.ជ. បានប្រព្រឹត្តកំហុសអង្គហេតុ ឬ ការបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិ ដោយរបៀបណា។ គួរច្រានចោល មូលដ្ឋាន "ឆ"។

---

[401] កថាខណ្ឌ ៤១៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[402] កថាខណ្ឌ ១១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[403] *សូមមើល* កថាខណ្ឌ ៤២១-២៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[404] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១ *ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ១១-១២, ២៤។

[405] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Trbić* សំណុំរឿងលេខ IT-05-88/1-PT សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១ *ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ១៩, ២៤។

*ជ. ចម្លើយតបទៅនឹងមូលដ្ឋាន "ជ"៖ ស.ច.ស.ជ. មិនបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់*

៩៣. ស.ព.អ. បកស្រាយខុសនូវដីកាសម្រេចលើកលែងចោទប្រកាន់ ដោយអះអាងថា "មូលដ្ឋានជម្រើសមួយ" សម្រាប់រកឃើញថា លោក មាស មុត មិនមែនជាជនទទួលខុសត្រូវខ្ពស់បំផុតគឺ ថា ស.ច.ស.ជ. បានកំណត់ដោយ "*ផ្អែកលើការប៉ាន់ប្រមាណ* និង ចំពោះបញ្ហាអង្គច្បាប់" ថាជនដែលទទួលខុសត្រូវខ្ពស់បំផុត "អាចអនុវត្តបាន *ចំពោះតែ* ឌុចម្នាក់គត់"[406]។ ស.ច.ស.ជ. មិនដែលបានសម្រេចថា ឌុច គឺជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់ ឬ សំអាងបែបនេះនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។ ផ្ទុយទៅវិញ ស.ព.អ. ទទួលស្គាល់ថា ស.ច.ស.ជ. "បានគូសបញ្ជាក់ត្រឹមត្រូវជាច្រើនលើកថា បញ្ហាថាតើនរណាអាចស្ថិតនៅក្នុងចំណោម 'ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត' ពុំត្រូវបានធ្វើបុរេវិនិច្ឆ័យឡើយ"[407]។ អ.ប.ជ. គួរច្រានចោលភ្លាមៗមូលដ្ឋាន"ជ"ដោយហេតុថាស.ព.អ. លើកទឡ្ហីករណ៍ជំទាស់សំអាងហេតុដែល ស.ច.ស.ជ. មិនយកជាមូលដ្ឋានក្នុងការកំណត់យុត្តាធិការបុគ្គល[408]។

៩៤. ស.ព.អ. ផ្តល់ព័ត៌មានខុស ដោយអះអាងថា ស.ច.ស.ជ. មានសម្រេចផ្ទុយទៅនឹង[409] ការសម្រេចរបស់ ស.ច.ស. ក្នុងរឿងក្តី ០០៤/០១ ដែលថា ប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក. បង្ហាញថាមិនមានការយល់ឃើញរួមគ្នា និង ដែលមានចំណងគតិយុត្តិ ថា មានតែចំនួនជាក់លាក់នៃបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយ នឹងត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក.[410]។ ស.ច.ស.ជ. ដែលបានពិនិត្យមើលប្រវត្តិចរចាដូចគ្នា និង ដែលបានបញ្ជាក់ច្បាស់ និង បានអនុវត្តកត្តាដូចគ្នាសម្រាប់កំណត់អត្តសញ្ញាណជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ដូចនឹង

[406] កថាខណ្ឌ ១៧១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. (ការគូសបញ្ជាក់បន្ថែម)។

[407] កថាខណ្ឌ ១៩០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ដែលដកស្រង់កថាខណ្ឌ ៣៦៤, ៣៦៨, ៤០៥ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើល* កថាខណ្ឌ ៣៦៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់៖ "ការកំណត់លក្ខណៈវិនិច្ឆ័យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាទម្រង់នៃអំណាចឆន្ទានុសិទ្ធិនៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងការស៊ើបអង្កេតឯករាជ្យពីសំណាក់សហចៅក្រមស៊ើបអង្កេត"។

[408] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A សាលដីកា ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

[409] កថាខណ្ឌ ១៨៩ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[410] កថាខណ្ឌ ៣៧ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

ស.ច.ស.អ. Bohlander[411] បានសម្រេចថា ពាក្យទទួលខុសត្រូវខ្ពស់បំផុត គឺសំដៅលើ *ប្រភេទ* នៃបុគ្គល[412]។

៩៥. ខណៈដែល ស.ច.ស.ជ. និយាយខុសថា ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានដាក់បញ្ចូលក្នុងច្បាប់ អ.វ.ត.ក. ដោយសារតែ ឌុច[413] និង ថា ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ "នឹងមិនរាលដាលដល់កម្មាភិបាលនៅថ្នាក់ក្រោមក្រៅពី ឌុច ដែលមានឈ្មោះនៅក្នុងគំនិតអ្នកធ្វើច្បាប់"[414] នេះមិនមែនជាមូលដ្ឋាននៃការកំណត់យុត្តាធិការបុគ្គលរបស់គាត់ឡើយ។ ពាក្យថា ទទួលខុសត្រូវខ្ពស់បំផុត មិនមានបំណងសំដៅលើ ឌុច ឬ មានន័យថា ឌុច គួរត្រូវបានប្រើជាខ្នាតក្នុងការកំណត់ថា តើជនផ្សេងទៀត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណានោះឡើយ។ ត្រូវបានសន្មត នៅក្នុងអំឡុងពេលនៃការចរចាទាំងមូលថា ឌុច នឹងបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក.[415]។ ឌុច បានសារភាពអំពីឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១[416] ជាទីតាំងដែលទទួលការចាប់អារម្មណ៍ពីសំណាក់ក្រុមអ្នកជំនាញ[417] និង បានត្រៀមលក្ខណៈជាស្រេចសម្រាប់ការជំនុំជម្រះ។ "ប្រសិនបើគាត់មិនត្រូវបានបញ្ជូនទៅជំនុំ

---

[411] កថាខណ្ឌ ១៩ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។ *សូមមើល ផងដែរ* កថាខណ្ឌ ៨ *ខាងលើ*។

[412] កថាខណ្ឌ ៣៩៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់៖ "ខណៈដែលបុគ្គលទាំងពីរប្រភេទនេះត្រូវបានចាត់ចូលជាជនស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំងពាក្យថា "**ជាន់ខ្ពស់**" និង "**ខ្ពស់បំផុត**" សុទ្ធតែឆ្លុះបញ្ចាំងឲ្យឃើញថា មានចំនួនមេដឹកនាំតិចតួចបំផុត ដែលអាចស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"។ (អក្សរដិតក្នុងសំណៅដើម)។

[413] កថាខណ្ឌ ៣៩៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[414] កថាខណ្ឌ ៤០១ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[415] *សូមមើល* David Scheffer *ប្រវត្តិចរចាលើបញ្ហាយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.* អ្នកឃ្លាំមើលតុលាការកម្ពុជា ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ទំព័រ ៤។

[416] *សូមមើល* Christophe Peschoux កិច្ចសម្ភាសន៍ជាមួយ កាំង ហ្គេកអ៊ាវ ដែលគេស្គាល់ឈ្មោះថា ឌុច ផងដែរ ប្រធានមន្ទីរសន្តិសុខ ស-២១ ថ្ងៃទី ២៨-២៩ ខែមេសា ឆ្នាំ ១៩៩៩ ភូមិតាសាញ ថ្ងៃទី ៤-៦ ខែឧសភា ឆ្នាំ១៩៩៩ ខេត្តបាត់ដំបង ទំព័រ ១-១០ (ឯកសារភ្ជាប់ ១២)។

[417] *សូមមើល* កថាខណ្ឌ ៥៥ នៃរបាយការណ៍ក្រុមអ្នកជំនាញ ៖ "ចំពោះកំណត់ត្រាឯកសារដែលបញ្ជាក់យ៉ាងច្បាស់អំពីតួនាទីរបស់បុគ្គលជាក់លាក់មួយចំនួនជាអ្នកចូលរួមដោយផ្ទាល់ ឬ ជាមេដឹកនាំ វាហាក់ដូចជាទូលំទូលាយមែនទែនសម្រាប់អំពើសម្លាប់រង្គាលខ្លះ គួរឲ្យកត់សម្គាល់បំផុត គឺ ប្រតិបត្តិការនៃកន្លែងសួរចម្លើយនៅទួលស្លែង។ សម្រាប់អំពើសម្លាប់រង្គាលខ្លះទៀត ឯកសារភស្តុតាងដែលជាប់ពាក់ព័ន្ធផ្ទាល់នឹងបុគ្គលទាំងឡាយ ថាតើស្ថិតនៅកម្រិតរដ្ឋាភិបាលជាន់ខ្ពស់ ឬកម្រិតតំបន់ ឬកម្រិតមូលដ្ឋាន ឬយ៉ាងណានោះ នាពេលបច្ចុប្បន្ន គឺមិនមានទេ ហើយអាចរកពុំឃើញនោះឡើយ" (ឯកសារភ្ជាប់ ១២)។

ជម្រះនោះទេ គឺពិតជានាំមកនូវបញ្ហាចោទ"[418]។ ប្រសិនបើ ស.ច.ស.ជ. មានគំនិតគិតទុកជាមុន ថា មានតែ ឌុច ម្នាក់គត់ដែលជាជនដែលទទួលខុសត្រូវខ្ពស់បំផុតមែននោះ ស.ច.ស.ជ. នឹងមិនមានហេតុផលក្នុងការពិនិត្យមើលប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក. ច្បាប់ និង យុត្តិសាស្ត្រអំពីយុត្តាធិការបុគ្គល[419] ឬ ពិនិត្យមើលភ័ស្តុតាងនៅក្នុងការវិភាគរបស់ខ្លួនទៅលើយុត្តាធិការរបស់ អ.វ.ត.ក. លើ អ៊ឹម ចែម[420] អោ អាន[421] ឬ លោក មាស មុត[422] ដើម្បីផ្តល់សំអាងហេតុរបស់ខ្លួននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។

៩៦. *ជារួម* ដោយបានបកស្រាយខុសនូវដីកាសម្រេចលើកលែងចោទប្រកាន់ និង បានជំទាស់ទៅនឹងការសម្រេច ដែលដីកាសម្រេចលើកលែងចោទប្រកាន់មិនយកធ្វើជាមូលដ្ឋាន ស.ព.អ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុសអង្គច្បាប់ ឬ ការបំពានឆន្ទានុសិទ្ធិដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការធ្វើសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។ គួរច្រានចោល មូលដ្ឋាន "ជ" ភ្លាមៗ។

## V. សេចក្តីសន្និដ្ឋាន

៩៧. ដោយខកខានមិនបានបង្ហាញឱ្យឃើញថា តើកំហុសដែលគាត់បានលើកឡើង ជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. ក្នុងការកំណត់ថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើលោក មាស មុត ជារួម ឬ ដោយឡែក ដោយរបៀបណានោះ ស.ព.អ.៖

ក. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ដោយមិនបានពិចារណាលើភ័ស្តុតាងដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ដើម្បីកំណត់ពីយុត្តាធិការបុគ្គល។

ខ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ក្នុងការពិចារណា និង ចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ក្នុងវិសាលភាពនៃរឿងក្តី ០០៣។

---

[418] *សូមមើល* Heder យុត្តាធិការបុគ្គល ទំព័រ ២៧ ដែលដកស្រង់សម្តី Thomas Hammarberg ឆ្លើយទៅ Ralph Zacklin ចុះថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៩៩។

[419] កថាខណ្ឌ ៣៦១-៧៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់។

[420] កថាខណ្ឌ ១៤០-២៨០ នៃដីកាដំណោះស្រាយរឿងក្តី ០០៤/១។

[421] កថាខណ្ឌ ៧៧-៤៨៤ នៃដីកាសម្រេចលើកលែងចោទប្រកាន់រឿងក្តី ០០៤/២។

[422] កថាខណ្ឌ ៥៥-៣៥៣ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើល ផងដែរ* កថាខណ្ឌ ៥២-៦០ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

គ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ក្នុងការផ្តល់សំអាងហេតុក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ដោយខកខានមិនបានសម្រេចលើអង្គហេតុដែលតម្រូវ និង កំណត់ប្រភេទបទចោទតាមច្បាប់។

ឃ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ឬ អង្គហេតុនៅក្នុងការពិចារណាអំពីការបង្ខំ ការគៀបសង្កត់ និង ការបញ្ជាពីថ្នាក់លើ នៅពេលកំណត់ពីកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត។

ង. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ ឬ អង្គហេតុនៅក្នុងការពិចារណាអំពីការចូលរួមដោយផ្ទាល់របស់លោក មាស មុត នៅក្នុង និង នៅជៀកកិតនឹងឧក្រិដ្ឋកម្ម នៅពេលកំណត់ពីកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត។

ច. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. បានធ្វើការសម្រេចលើអង្គហេតុដោយមានកំហុស ដែលមានឥទ្ធិពលកំណត់លើបញ្ហាយុត្តាធិការបុគ្គល។

ឆ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គហេតុក្នុងការពិចារណាលើជនរងគ្រោះ។ និង

ជ. ខកខានមិនបានបង្ហាញឱ្យឃើញថា ស.ច.ស.ជ. មានកំហុសអង្គច្បាប់ក្នុងការសម្រេចថា ឌុច គឺជាជនទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់។

៩៨. ដោយគ្មានការសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដីកាសម្រេចលើកលែងចោទប្រកាន់មិនអាចត្រូវបានច្រានចោលឡើយ ហើយហេតុដូច្នេះ គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ* កំណត់ឱ្យ អ.ប.ជ. ច្រានចោលរឿងក្តីប្រឆាំងនឹងលោក មាស មុត។ បើទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានច្រានចោល ដោយសំឡេងភាគច្រើនលើសលប់ក៏ដោយ ក៏ អ.ប.ជ. នៅតែត្រូវសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលប់ដែរ ដើម្បីបញ្ជូនរឿងក្តីទៅជំនុំជម្រះនៅក្នុងសវនាការនោះ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុដូចបានជម្រាបជូនខាងលើ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ក៏ដូចជា រឿងក្តីប្រឆាំងនឹងលោក មាស មុត គួរត្រូវបានច្រានចោល។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **២៤** ខែ **មិថុនា** ឆ្នាំ **២០១៩**

សហមេធាវីការពារក្តីលោក មាស មុត

____________________ ____________________

អាង ឧត្តម Michael G. KARNAVAS